សេចក្តីព្រាងដែលបានត្រួតពិនិត្យរួចហើយ
មិនមែនជាឯកសារសំរាប់ផ្សព្វផ្សាយ

# ការបើកទ្វារទទួលលិទ្ធិប្រជាធិបតេយ្យ

## វិមជ្ឈការ និង វិសហមជ្ឈការ នៅកម្ពុជា

ចូអែល រ៉ូខាម៉ូរ៉ា ឧសភា ២០០៧

ឆ្នាំ ២០០៧ គឺជាឆ្នាំបង្ហាញនូវបដាព្រោងព្រាត សំរាប់ វិមជ្ឈការ និង វិសហមជ្ឈការ (D&D) នៅប្រទេសកម្ពុជា។ ឆ្នាំ ២០០៧ ក៏ជាឆ្នាំត្រៀមរៀបចំដែលច្បាប់រៀបចំអង្គការថ្មី ស្តីពី វិមជ្ឈការ និង វិសហមជ្ឈការ ត្រៀមខ្លួនជាចុងក្រោយដើម្បីដាក់ជូនសភា។ ច្បាប់រៀបចំអង្គការ គឺជាច្បាប់ដែលនឹងផ្តល់នូវមូលដ្ឋានខាងផ្លូវច្បាប់សំរាប់ អង្គភាពរដ្ឋាភិបាលមូលដ្ឋាន ដែលនៅពីលើថ្នាក់ឃុំ។ បញ្ហាប្រឈមសំរាប់ច្បាប់រៀបចំអង្គការថ្មីនេះ គឺការផ្តោតការយកចិត្តទុកដាក់ទៅលើវិសមជ្ឈការ។ ទីភ្នាក់ងារខ្សែបណ្តោយនៅថ្នាក់ជាតិ នឹងត្រូវលះបង់មុខងារ ព្រមទាំងថវិការឆ្លើយតបទៅដល់ខេត្ត និងស្រុក។ ច្បាប់រៀបចំអង្គការក៏នឹងធ្វើការរៀបចំកែលំអផងដែរ នូវរចនាសម្ព័ន្ធអង្គការលេខសំរាប់កិច្ចប្រតិបត្តិការដំណើរការវិមជ្ឈការ និងវិសហមជ្ឈការដ៏ស្មុកស្មាញនេះ។ ការសំខាន់ដូចគ្នានេះដែរ ក្របខ័ណ្ឌថ្មីមួយ សំរាប់ការចូលរួមពាក់ព័ន្ធរបស់ម្ចាស់ជំនួយនៅក្នុងការងារវិមជ្ឈការ និងវិសហមជ្ឈការនឹងត្រូវបានអនុវត្តឡើងជាមួយនឹងការរំសាយជាជំហាន១នៃរចនាសម្ព័ន្ធ PLG/សីលា។ ជាអកុសល សេចក្តីព្រាងច្បាប់រៀបចំអង្គការនៅមិនទាន់បានដាក់ជូនទៅសភានៅឡើយ នៅខែមិថុនានេះ ហេតុដូច្នេះហើយ អាចនឹងត្រូវរុញច្រានកាលកំណត់ច្រើនខែទៅមុខទៀត។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទីពីរ ត្រូវបានធ្វើឡើងកាលពីខែមេសា ឆ្នាំ ២០០៧ កន្លងមកនេះ។ ដូចការរំពឹងទុក គណបក្សប្រជាជនកម្ពុជា (CPP) ដែលកំពុងកាន់អំណាច បានទទួលសម្លេងគាំទ្ររហូតដល់ ៦០.៨២ ភាគរយយ៉ាងស្រួល (ចំនួនសមាជិកក្រុមប្រឹក្សា ៥០៩២ រូប) នៃសម្លេងឆ្នោតសរុប។ គណបក្សសម រង្ស៊ី (SRP) បានទទួលសម្លេងឆ្នោតគាំទ្រលំដាប់ទីពីរ ស្មើនឹង ២៥.១៩ ភាគរយ (ចំនួនសមាជិកក្រុមប្រឹក្សា ១២៦៦រូប) តាមពីក្រោយដោយ គណបក្ស

ទើបបង្កើតថ្មី គឺគណបក្ស នរោត្តម រណឫទ្ធិ (NRP) ដោយទទួលបានសម្លេងឆ្នោតចំនួន ៨.១១ ភាគរយ (ចំនួនសមាជិកក្រុមប្រឹក្សា ៦២រូប) និងចុងក្រោយបង្អស់គឺ គណបក្សហ្វុនស៊ីនប៉ិច ដោយទទួលបានសម្លេងឆ្នោតចំនួន ៥.៣៦ ភាគរយ (ចំនួនសមាជិកក្រុមប្រឹក្សា ៧០ រូប)។ ទោះជាយ៉ាងនេះក៏ដោយ នៅក្នុងការបោះឆ្នោតជ្រើសតាំងប្រធានក្រុមប្រឹក្សាឃុំដ៏មានសារសំខាន់ គណបក្សប្រ-ជាជនកម្ពុជា ទទួលបានតំណែងជាប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន១៥៩១ឃុំ សង្កាត់ និង ចំនួន៣០ឃុំ សង្កាត់ទៀតដែលនៅសល់ គឺបានទៅលើគណបក្សសម រង្ស៊ី ចំនួន២៨ឃុំ សង្កាត់ និងគណបក្សហ្វុនស៊ីនប៉ិច ចំនួន ២ឃុំ សង្កាត់។ សំរាប់តំណែងអនុប្រធានទីមួយក្រុមប្រឹក្សាឃុំ សង្កាត់ គណបក្សប្រជាជនកម្ពុជា ទទួលបានចំនួនពីរភាគបី នៃតំណែងអនុប្រធានទីមួយឃុំ សង្កាត់ទាំងអស់ស្មើនឹង ១១២៥ តំណែង ចំណែកគណបក្សសម រង្ស៊ី ទទួលបានតែ ៤០៣ តំណែង គណបក្សហ្វុន-ស៊ីនប៉ិច ទទួលបាន ៤៧ តំណែង និងគណបក្ស នរោត្តម រណឫទ្ធិ ទទួលបានតែ ៤៦ តំណែងប៉ុណ្ណោះ។ ការធ្លាក់ចុះនៃចំនួនអ្នកចូលរួមបោះឆ្នោតពី ៨៧.៤៨ ភាគរយ នៅឆ្នាំ ២០០២ មកនៅត្រឹម ៦៧.៨៧ ភាគរយនៅឆ្នាំនេះ ជាបុព្វហេតុគួរអោយព្រួយបារម្ភ (គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ២០០៧)។

ការងារវិមជ្ឈការ មិនមែនជាការងារងាយស្រួលនោះទេ។ ប្រសិនបើនិយាយជាទូទៅ វិមជ្ឈការគឺជាការធ្វើអនុប្បទាន/ការបាត់បង់អំណាច របស់មនុស្សមួយក្រុម ទៅអោយក្រុមមនុស្សដទៃផ្សេងទៀត ដែលជារដ្ឋាភិបាលនៅថ្នាក់ក្រោម។ ជាញឹកញាប់ ពិតជាមានភាពស្មុកស្មាញយ៉ាងខ្លាំងមែន ហើយភាពស្មុកស្មាញនៃដំណើរការនោះ គឺត្រូវបានកំណត់ដោយកម្លាំងនៃការតស៊ូ/ភាពរឹងទទឹងរបស់អ្នកដែលត្រូវបាត់បង់អំណាច ហើយនឹងសម្ពាធដែលប្រមូលគៀរគចេញពីថ្នាក់ក្រោមរបស់អ្នកដែលនឹងទទួលបានអំណាច។ នៅកម្ពុជា មានការកំណត់ខាងផ្នែកនយោបាយដ៏ចំបងចំនួនបី: (១) គណបក្សកំពុងកាន់អំណាច គឺគណបក្សប្រជាជនកម្ពុជា (CPP) កាលពីអតីតៈកាល គឺជាគណបក្សកុម្មុយនីស្ដដែលបានលះបង់មនោគមវិជ្ជាលទ្ធិម៉ៅនិយម ប៉ុន្តែនៅរក្សាទុកអង្គការរបស់ខ្លួនតាមបែប មជ្ឈការ-ឡេនីន ដែលនិយមថ្នាក់កណ្តាលយ៉ាងខ្លាំង។ (២) សង្គ្រាមជាច្រើនទសវត្សរ៍ បានរារាំងដល់ការអភិ-វឌ្ឍន៍ស្ថាប័ននយោបាយ ជាពិសេសនៅថ្នាក់មូលដ្ឋាន។ (៣) សង្គ្រាមត្រូវបានបញ្ចប់ដោយសារមានអន្តរាគមន៍របស់បរទេស ហើយ អន្តរាគមន៍នេះ នៅបន្តរហូតដល់សព្វថ្ងៃ ដោយគ្រាន់តែមានការថមថយប៉ុណ្ណោះ។ ជាលទ្ធផល ការបង្កើតគោលនយោបាយវិមជ្ឈការ"... ត្រូវបានគេធ្វើឡើងនៅពី

ក្រោយទ្វាបិទជិត ដោយមានការគ្រប់សង្កត់ដោយម្ចាស់ជំនួយបរទេស និងមន្ត្រីកម្ពុជាមួយចំនួន គឺមិនបានធ្វើឡើងដោយអ្នកនយោបាយ និងមេដឹកនាំនៃស្ថាប័ននានារបស់កម្ពុជានោះឡើយ”។
(Biddulph 2003:10)

ការពង្រឹងការត្រួតត្រាខាងផ្នែកនយោបាយនៅឆ្នាំ២០០៦ របស់គណបក្សប្រជាជនកម្ពុជា គួរតែជួយសម្រួលដល់កិច្ចការអន្តរកាលទាំងអស់នេះ បើនិយាយដោយឡែក គឺការអនុម័តច្បាប់រៀបចំអង្គការដោយសភា។ កាលពីឆ្នាំកន្លងទៅ មេដឹកនាំគណបក្សប្រជាជនកម្ពុជា គឺលោក ហ៊ុន សែន បានធ្វើឱ្យសំរេចបានទៅលើកម្លាំងដ៏សំខាន់ពីរ តាមរយៈភាពរហ័សរហួនខាងផ្នែកនយោបាយ ដោយធ្វើអោយមានការគាំទ្រត្រឡប់មកវិញពីគណបក្សសម រង្ស៊ី ហើយបន្ទាប់មកបានប្រើប្រាស់គណបក្សសម រង្ស៊ី លើកវារៈ ទាក់ទិនវិធានរបស់សភាក្នុងការបង្កើតរដ្ឋាភិបាលដែលគួរធ្វើការផ្លាស់ប្តូរ ពីពីរភាគបីនៃសមាជិកសភា មកត្រឹមមតិភាគច្រើនជាសាមញ្ញធម្មតាវិញ គឺ ៦២អាសនៈ នៃអាសនៈទាំងអស់ចំនួន ១២៣។ តាមវិធានចាស់ អាសនៈទទួលបានដោយគណបក្សប្រជាជនកម្ពុជាចំនួន ៧៣ អាសនៈ នៅក្នុងការបោះឆ្នោតទូទៅក្នុងឆ្នាំ ២០០៣ ពិតជាមិនគ្រប់គ្រាន់ដើម្បីបង្កើតរដ្ឋាភិបាលតែម្នាក់ឯងបានឡើយ ក្រៅពីរដ្ឋាភិបាលចម្រុះ ដោយសារលក្ខខណ្ឌតម្រូវ គឺ ៨២ អាសនៈ/សម្លេង។ អស់រយៈពេល ១១ ខែ ក្រោយការបោះឆ្នោតទូទៅនៅក្នុងឆ្នាំ២០០៣ គេនៅមិនទាន់បង្កើតបានរដ្ឋាភិបាលនៅឡើយ ដោយសារតែវិធាននេះ។ ថាតើ អំណាចកាន់តែធំធេងរបស់គណបក្សប្រជាជនកម្ពុជា នឹងជួយពន្លឿនដល់ការងារវិមជ្ឈការ និងវិសហមជ្ឈការដែរឬយ៉ាងណា តែទោះជាយ៉ាងណាក៏ដោយ វាមិនទាន់ដល់ពេលធ្វើសេចក្តីសន្និដ្ឋានទុកជាមុនបាននៅឡើយទេ។

ដោយលើកលែងតែប្រទេសទីម័រខាងកើតចេញ ប្រទេសកម្ពុជា បានចាប់ផ្តើមដំណើរការកសាងរដ្ឋបច្ចុប្បន្នរបស់ខ្លួន ដោយមានបញ្ហាជាច្រើនជាងប្រទេសណាៗទាំងអស់ នៅអាស៊ីអគ្នេយ៍នេះ។ ប្រសិនបើយើងលើកយកការបោះឆ្នោតឆ្នាំ១៩៩៣ ជាការចាប់ផ្តើមកសាងរដ្ឋ យើងគួរត្រឡប់ថយ-ក្រោយយ៉ាងហោចណាស់២០ឆ្នាំ គឺចាប់ពីសម័យសង្គ្រាមទម្លាប់គ្រាប់បែកដ៏ច្រើនសន្ធឹកសន្ធាប់របស់អាមេរិកក្នុងឆ្នាំ ១៩៧៣ របបជ័យជំនះរបស់ខ្មែរក្រហមក្នុងឆ្នាំ១៩៧៥ ហើយនឹងការចាប់ផ្តើម របបវាលពិឃាតសម្លាប់រង្គាលរយៈពេលបួនឆ្នាំ ការឈ្លានពានរបស់វៀតណាមក្នុងឆ្នាំ១៩៧៩ ហើយនិងសង្គ្រាមស៊ីវិលមួយទសវត្សរ៍ មុននឹងយើងចូលដល់រយៈពេលនៃការអន្តរាគមន៍របស់អង្គការសហប្រ-

ជាជាតិនៅឆ្នាំ១៩៩៣។ "ខណៈដែលកម្ពុជាកំពុងធ្វើអន្តរកាលចេញពីសង្គ្រាមឆ្ពោះទៅរក' ភាពធម្មតាឡើងវិញ កេរ្តិ៍ដំណែលនៃអតីតៈកាលនៅតែជាភស្តុតាងនៅឡើយ"។ ស្ថាប័នអភិបាលកិច្ចនៅត្រូវការការតម្រង់ទិសនៅឡើយក្នុងការធ្វើអោយរបបសង្គមមានស្ថេរភាព ហើយការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ ក៏នៅតែមានលក្ខណៈស្លូចស្តើងនៅឡើយ។ រដ្ឋាភិបាលនៅទន់ខ្សោយទាក់ទិននឹងលទ្ធភាពរបស់ខ្លួន ដើម្បីបង្កើតភក្តីភាពរវាងកម្មករនយោជិត និងអ្នកតំណាងរបស់ខ្លួន ទៅលើក្រម និង វិធានច្បាប់ផ្លូវការផ្សេងៗ ដើម្បីរក្សាចង្វាក់នៃប្រតិបត្តិការជុំវិញគោលបំណងនៃគោល-នយោបាយថ្នាក់ជាតិ ដើម្បីការពារពលរដ្ឋរបស់ខ្លួនពីការកេងប្រវ័ញ្ចដោយមន្ត្រីរដ្ឋាភិបាល ឬ ដោយភ្នាក់ងារពាណិជ្ជកម្ម ឬដើម្បីធានាថា វិវាទ ទាំងនៅក្នុងចំណោមប្រជាជន និងរវាងប្រជាពលរដ្ឋនិងរដ្ឋាភិបាល ត្រូវបានលើកឡើង និងដោះស្រាយដោយយុត្តិធម៌ និងមានប្រសិទ្ធភាព"។
(ការសិក្សាឯករាជ ២០០៦:១២)

ជាដំបូង ការទម្លុះចូលទៅក្នុងការងារវិមជ្ឈការនៅប្រទេសកម្ពុជា ត្រូវបានជំរុញឡើងដោយឥទ្ធពលរបស់ម្ចាស់ជំនួយ។ ការងារវិមជ្ឈការបានក្លាយទៅជាបែបផែនដ៏មានប្រជាប្រិយ៍ភាព របស់ម្ចាស់-ជំនួយនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០ នៅពេលដែលអង្គការសហប្រជាជាតិ និងទីភ្នាក់ងារម្ចាស់ជំនួយទាំងឯកជន និងសាធារណៈ បានចូលមកដល់ប្រទេសកម្ពុជា។ ដោយមិនចង់អោយជំនួយរបស់ខ្លួនធ្លាក់ទៅលើគណបក្សដែលកំពុងគ្រប់គ្រងទីភ្នាក់ងាររដ្ឋាភិបាលកណ្តាល ម្ចាស់ជំនួយត្រូវការទីភ្នាក់-ងាររដ្ឋាភិបាលមូលដ្ឋានក្នុងការផ្តល់សេវាទាំងនោះ ដោយសារពួកគេនៅកៀកទៅនឹងអ្នកទទួលផលដែលជាការជួយសម្រួលដល់ គណនេយ្យភាព និងបង្កើតអោយមានដំណើរការតាមបែបប្រជាធិប-តេយ្យនៅថ្នាក់ក្រោមបង្អស់។ ដូចដែល "ការងារវិមជ្ឈការ" ត្រូវបានបង្ហើបឱ្យដឹងដោយម្ចាស់ជំនួយត្រូវតែអមទៅជាមួយនឹង "សង្គមស៊ីវិល" ហើយទីភ្នាក់ងារផ្តល់មូលនិធិឯកជនបាននាំមកជាមួយនូវជំនួយដ៏មានសារសំខាន់ផងនោះ ដូច្នេះតួនាទីរបស់អង្គការក្រៅរដ្ឋាភិបាល នៅក្នុងដំណើរការនេះត្រូវបានធានាសន្តិសុខក្នុងការចាប់យក ការងារវិមជ្ឈការ។

ប៉ុន្តែការនេះមិនមែនមានន័យថា អ្នកនយោបាយរបស់កម្ពុជា ត្រូវបានគេបញ្ចុះបញ្ចូលដោយងាយ-ស្រួលនោះទេ។ ផលប្រយោជន៍ជាក់លាក់ខាងផ្នែកនយោបាយ និងការតតាំងរបស់រដ្ឋាភិបាលថ្នាក់កណ្តាលដែលដឹកនាំការងាររបស់ខ្លួនតាមបែបការិយាធិបតេយ្យ បានបង្ហាញភស្តុតាងនៅក្នុងដំណើរ

ការវិមជ្ឈការ និងការបង្កើតគំរោងការ។ វិមជ្ឈការបានកើតឡើងនៅក្នុងរដ្ឋាភិបាលនៅថ្នាក់ក្រោម-បង្អស់ គឺថ្នាក់ភូមិ និងថ្នាក់ឃុំ។ ប៉ុន្តែនៅថ្នាក់ខ្ពស់ជាងនេះបន្ទាប់គឺថ្នាក់ស្រុក និងថ្នាក់ខេត្ត នៅរក្សាភាពជាឧបករណ៍នៃ រដ្ឋាភិបាលថ្នាក់កណ្តាលដដែល។ ឃុំ សង្កាត់មិនត្រឹមតែមានភាពទន់ខ្សោយក្នុងការងាររដ្ឋបាល និងហិរញ្ញវត្ថុប៉ុណ្ណោះទេ សូម្បីតែកម្លាំងបុកទម្លាយតាមបែបប្រជាធិបតេយ្យរបស់ខ្លួន ក្នុងនាមជារដ្ឋាភិបាលមូលដ្ឋានដែលជាប់ឆ្នោតតាមការបោះឆ្នោតជាសកលក៏ដោយ ក៏ការនេះត្រូវបានបញ្ឈប់ដោយថ្នាក់ស្រុកយ៉ាងមានប្រសិទ្ធិភាព។ ការកំរិតដ៏ធ្ងន់ធ្ងរមួយផ្សេងទៀតគឺថា ក្រុម-ប្រឹក្សាឃុំ គ្មានអំណាចក្នុងការដោះស្រាយវិវាទជុំវិញ "បញ្ហាប្បញ្ញត្តិកម្ម" ផ្សេងៗ ដូចជា បញ្ហាដីធ្លី លទ្ធភាពទទួលបានទឹកសំរាប់ស្រោចស្រព ការតវ៉ាជុំវិញរឿងនេសាទ្រ និងព្រៃឈើ ជាដើម។ មានបញ្ហាផ្សេងទៀត ដែលអាចដោះស្រាយបានតាមរយៈ "យុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ" ដែលជាប្រធានបទនៃការចចារយ៉ាងតឹងតែងបំផុតនៅទីក្រុងភ្នំពេញចាប់តាំងពីឆ្នាំ ២០០៥ មក។

មុនការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅឆ្នាំ ២០០២ បើនិយាយដោយរឹតត្បិតបំផុតនៅកម្ពុជាមិនទាន់មានរដ្ឋាភិបាលមូលដ្ឋាននៅឡើយទេ។ ជោគជ័យនៃការបោះឆ្នោត ការបង្វែរមូល-និធិអភិវឌ្ឍន៍ដ៏មានសារសំខាន់តាមរយៈក្រុមប្រឹក្សាឃុំ និងការបោះឆ្នោតម្តងទៀតនៅខែមេសា ក្នុងឆ្នាំនេះ រួមផ្តុំបង្កើតបានជា សមិទ្ធិផលធំៗនៃការងារវិមជ្ឈការ នៅក្នុងប្រទេសកម្ពុជា។ "ជាលើកដំបូងហើយដែលច្បាប់វិមជ្ឈការ បានផ្តល់អំណាចអោយបុរស ស្ត្រី ចូលរួមនៅក្នុងអង្គភាពតំណាងនៅមូលដ្ឋានក្នុងការអនុវត្តន៍ការធ្វើផែនការ និងការរៀបចំថវិកា ជាអចិន្ត្រៃយ៍ និងគ្រប់គ្រងដោយរដ្ឋាភិបាលខ្លួនឯងផ្ទាល់ និងប្រកបដោយគណនេយ្យភាពក្នុងការសំរេចពីរបៀបរបបធនធានសាធារ-ណៈដែលត្រូវបែងចែកដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ខ្លួន ក្នុងការផ្តល់សិទ្ធិទៅលើការងារសង្គមកិច្ច សេដ្ឋកិច្ច រដ្ឋបាល និងនយោបាយជាមូលដ្ឋាន"។ (ការសិក្សាឯករាជ ទំព័រទី ៦) ទាំងនេះគឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំមួយ ហើយការរីកចំរើនបន្ថែមទៀតនៅក្នុងការងារវិមជ្ឈការ និងវិសហមជ្ឈការតាមរយៈការអនុម័តច្បាប់រៀបចំអង្គការថ្មី នឹងបោះយុថ្កាជាប់យ៉ាងរឹងមាំខ្លាំងក្លាថែមទៀតជាមិនខាន។ សមិទ្ធិផលទាំងនេះអាចត្រូវបានគេមើលឃើញថា មានលក្ខណៈតិចតួចស្តួចស្តើងតាមបទដ្ឋានអន្តរជាតិ ប៉ុន្តែបើវាស់វែងធៀបនឹងលក្ខខណ្ឌផ្នែកនយោបាយដែលមានក្នុងពេលសព្វថ្ងៃឃើញថា សំខាន់គួរសមដែរ។ គ្មានទីកន្លែងណាដែល "លទ្ធិប្រជាធិបតេយ្យសឹងតែលិចលុងបាត់ទៅហើយ ហើយការបើកទ្វាទទួលយកលិទ្ធិប្រជាធិបតេយ្យជាការប្រះស្រាំនោះទេ"។

យុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការដែលបានឯកភាពគ្នាកាលពីឆ្នាំ២០០៥ ហើយនឹងរបាយការណ៍ស្ដីពី សេចក្ដីព្រាងច្បាប់រៀបចំអង្គការ បង្កើតស្រុក និងខេត្ត ទៅជាអង្គភាពរដ្ឋាភិបាលមូលដ្ឋាន ដែលជាការនាំយកស្រុក និងខេត្ត ឆ្ងងអោយផុតពីឋានៈមិនពិតប្រាកដរបស់គេ ដែលសព្វថ្ងៃគ្រាន់តែជាការិយាល័យនៅមូលដ្ឋានរបស់ក្រសួងមហាផ្ទៃនោះ។ ការនេះអាចធ្វើទៅបានតាមរយៈការបោះឆ្នោតតាមប្រភេទណាមួយតែប៉ុណ្ណោះ ដែលនឹងភ្ជាប់ស្រុក និងខេត្តទៅនឹងប្រជាពលរដ្ឋនៅក្នុងតំបន់របស់ខ្លួន និងការបង្កើតនូវ រចនាសម្ព័ន្ធជាតំណាងមួយ។ ទោះជាយ៉ាងណាក៏ដោយ អ្វីដែលជាការសញ្ជឹងគិតទុកសំរាប់ថ្នាក់ទាំងពីរ គឺនឹងមានក្រុមប្រឹក្សាជាប់ឆ្នោតដោយការបោះឆ្នោតជាអសកល។ សេចក្ដីព្រាងច្បាប់រៀបចំអង្គការចុងក្រោយ ត្រូវបានគេសម្ងត់ថា នឹងបានដាក់ជូនសភា នៅចុងឆ្នាំ ២០០៦។ ត្រង់ចំណុចនេះ យើងមិនប្រាកដថា តើនៅពេលណាវានឹងកើតឡើងនោះឡើយ។ ហេតុផលមួយក្នុងចំណោមហេតុផលផ្សេងៗទៀត ដែលសេចក្ដីព្រាងច្បាប់រៀបចំអង្គការ ត្រូវបានពន្យាពេលគឺថា ពុំទាន់មានការឯកភាពគ្នានៅឡើយមកទល់ពេលនេះ ទាក់ទិននឹងតួនាទី និងមុខងាររបស់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ (ឧ. ក្រុមប្រឹក្សាស្រុក ប្រៀបធៀបក្រុមប្រឹក្សាខេត្ត នឹងការទំនាក់ទំនងទៅកាន់ក្រុមប្រឹក្សាឃុំ សង្កាត់) តួនាទី និងការទំនាក់ទំនងរបស់ក្រុមប្រឹក្សា និងអភិបាល ហើយនឹងប្រធានស្រុក ព្រមទាំងការចាត់តាំង និងការផ្ទេរមុខងារចេញពីក្រសួងផ្សេងៗ ទៅថ្នាក់ក្រោមជាតិណាមួយ។ សេចក្ដីព្រាងច្បាប់រៀបចំអង្គការចែងអំពីដំណើរការសំរាប់ការងារទាំងនេះ ជាជាងគ្រាន់តែកំណត់ពីអ្វីដែលត្រូវប្រគល់ទាំងស្រុង ទៅកាន់ថ្នាក់ក្រោមជាតិនីមួយៗ។

អ្វីដែលសំរេចបានមកទល់ពេលនេះ គឺលទ្ធផលនៃការគាំទ្ររបស់មន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្ដល់ជូនចំពោះម្ចាស់ជំនួយ និងទីប្រឹក្សាបរទេសក្នុងការជំរុញដំណើរការអោយឆ្ពោះទៅមុខ។ ការគាំទ្រផ្នែកនយោបាយត្រូវបានផ្ដល់ជូនក្នុងកំរិតមួយខ្ពស់បំផុត គឺដោយឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី គឺជាមន្ត្រីមួយរូបដែលមានការទទួលស្គាល់យ៉ាងទំលំទូលាយថាជា បុគ្គលដែលមានអំណាចបំផុតទីពីរនៅក្នុងរដ្ឋាភិបាល និងនៅក្នុងគណបក្សប្រជាជនកម្ពុជា។ ឯកឧត្តម ស ខេង ត្រូវបានគេរាយការណ៍ថា ជាបុគ្គលជិតស្និតជាមួយនឹងអតីតៈលោកប្រធាន ជា ស៊ីម ដែលជាព្រឹទ្ធាចារ្យប្រធាន គណបក្សប្រជាជនកម្ពុជា និងជាប្រធានព្រឹទ្ធសភាដែលជានិមិត្តរូបនៃកម្ពុជា និងជាមេដឹកនាំតែម្នាក់គត់នៃគណបក្សប្រជាជនកម្ពុជាដែលហ៊ានប្រឈមនឹងលោក ហ៊ុន សែន។ កិច្ចការប្រចាំថ្ងៃត្រូវបានដឹកនាំដោយឯក-

ឧត្តម ព្រុំ សុខា រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ។ ឯកឧត្តម ព្រុំ សុខា ជាអ្នកអំពាវនាវអោយមានដំណើរការសេចក្តីព្រាងច្បាប់រៀបចំអង្គការ ដែលកិច្ចការនេះបានជួយពង្រឹងតាមរយៈការវាយតម្លៃដោយអ្នកវិភាគនានាថា គាត់គឺជាមនុស្សម្នាក់ដែលជិតស្និតនឹងលោក ហ៊ុន សែន។ មានមេដឹកនាំសំ-ខាន់ៗផ្សេងទៀត ដូចជាឯកឧត្តម សក់ សេដ្ឋា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ ដែលត្រូវបានគេរាយការណ៍ថា ជាមនុស្សដែលជិតស្និតនឹងលោក ឧបនាយករដ្ឋមន្ត្រី។

ខណៈមានការទទួលស្គាល់នៅក្នុងឯកសារអភិវឌ្ឍន៍ទូទៅថា ជាការជោគជ័យមួយក៏ដោយ ការងារវិមជ្ឈការនៅប្រទេសកម្ពុជា គឺជាការងារដ៏លំបាក។ ដូចឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការនៃក្រសួងមហាផ្ទៃ និងជាស្ថាបនិកដ៏សំខាន់ក្នុងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការនៅប្រទេសកម្ពុជា បានមានប្រសាសន៍ថា: មានការនិយាយសំដៅទៅលើតម្រូវការនូវ "ផែនទីបង្ហាញផ្លូវ" ដែលអាចអោយរដ្ឋាភិបាលកម្ពុជាប្រើប្រាស់ដើម្បីនាំផ្លូវទៅរកការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ....។ "ផែនទីបង្ហាញផ្លូវ" នេះ មានបង្កប់ទៅដោយអត្ថន័យថា មានផ្លូវជាច្រើនផ្សេងៗគ្នា ជាជំរើស ឬសំរាប់ការជ្រើសរើសផ្លូវដ៏ប្រសើរបំផុត ដើម្បីបានទៅដល់ទិសដៅជាក់លាក់ណាមួយ។ ទោះជាយ៉ាងណាក៏ដោយ នៅកម្ពុជា ក៏ដូចជាបណ្តាប្រទេសប្រជាធិបតេយ្យថ្មីៗដទៃទៀតដែរ រឿងដ៏លំបាកបំផុតគឺថា *ពុំទាន់មានផ្លូវទៅកាន់ទីនោះនៅឡើយ* ។ ដូច្នេះ ជាការចាំបាច់ណាស់ ដើម្បីកំណត់អោយបានច្បាស់នូវ គោលដៅ និងទិសដៅរបស់ខ្លួនជាមុនសិន នឹងបន្ទាប់មកទើប *ស្ថាបនាផ្លូវ ស្ពាន ផ្លូវក្រោមដី និង ផ្លូវរៀង ដែលចាំបាច់ទាំងនោះ ។* ជាញឹកញាប់ ការនេះអាចនឹងធ្វើសំរេចបានតាមរយៈកិច្ចការដ៏លំបានបំផុត និងជូនកាលទៀត សឹងតែមិនអាចធ្វើបាន — ដោយសារស្ថាន-ភាពដី"។ (ឯកឧត្តម ព្រុំ សុខា ២០០៧: វគ្គ៩ ទំព័រទី៤)។

## សសរស្តម្ភនៃវិមជ្ឈការ

ការចាប់ផ្តើមនៃដំណើរការវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា បើយើងពិនិត្យមើលឃើញថាបានចាប់ផ្តើមដោយផ្ទាល់តាំងពីឆ្នាំ ១៩៩២មក តាមរយៈអង្គការ UNDP តាមរយៈគំរោង មាតុភូមិ-និវត្ត និងការតាំងទីលំនៅថ្មីនៅកម្ពុជា ដែលហៅកាត់ថា "CARERE "។ គោលបំណងរបស់គំរោងគឺ ដើម្បីគាំទ្រការធ្វើសមាហរណកម្មឡើងវិញនៃជនភៀសខ្លួន ធ្វើមាតុភូមិនិវត្តពីជំរុំនានានៅតាម

ព្រំដែនកម្ពុជាថៃ និងជនភៀសសឹកនៅតាមបណ្តាខេត្តគោលដៅនានា ដែលជាផ្នែកមួយនៃ ដំណើរការស្វែងរកសន្តិភាពនៅកម្ពុជា។ CARERE គាំទ្រសកម្មភាពកំចាត់មីន កែលំអហេដ្ឋារចនាសម្ព័ន្ធ-មូលដ្ឋាន ការផ្គត់ផ្គង់ទឹកនៅតំបន់ជនបទ សកម្មភាពអភិវឌ្ឍន៍កសិកម្ម និងសេវាសង្គមសំខាន់ៗ នៅក្នុងសហគមន៍នានាដែលមានប្រជាជនទៅតាំងទីលំនៅថ្មីនៅទីនោះ។ CARERE បានអនុវត្តសកម្ម-ភាពរបស់ខ្លួននៅក្នុងខេត្តចំនួន៤ នៅភាគពាយ័ព្យនៃកម្ពុជា អំឡុងឆ្នាំ១៩៩២-១៩៩៥។ ដើម្បីសម្រួលដល់ការងារនីតិសម្បទា និងជនភៀសខ្លួនដែលបានអនុវត្តពីដំបូង ដំណើរការតាមបែបចូលរួមក៏ត្រូវបានចាប់ផ្តើមអនុវត្តផងដែរ។ គំរោងនេះ នៅពេលក្រោយមក ក៏បានយកធ្វើជាពិសោធន៍នៅក្នុងការធ្វើផែនការ ការងារហិរញ្ញវត្ថុ និងការអនុវត្តន៍តាមបែបវិមជ្ឈការ នៃការអភិវឌ្ឍន៍នៅមូលដ្ឋាន។

“សកម្មភាព CARERE ទី II/កម្មវិធីសីលា ក៏បានចាប់ផ្តើមអនុវត្តនៅថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ដោយការបង្កើតអោយមានគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (VDC) និង គណៈកម្មាធិការអភិវឌ្ឍន៍ឃុំ (CDC) ដើម្បីគ្រប់គ្រងដំណើរការរៀបចំផែនការ ការសំរេច និងការអនុវត្តន៍តាមបែបវិមជ្ឈការនៃសកម្មភាពអភិវឌ្ឍន៍មូលដ្ឋាន ខណៈក្នុងពេលដូចគ្នានេះដែរនាយកដ្ឋានគាំទ្រខេត្ត លើការងារផ្តល់សេវា ដែលជាកម្មវិធីថ្នាក់ជាតិ សំរាប់ផ្តល់ធនធានហិរញ្ញវត្ថុ និងបច្ចេកទេស ដែលកៀរគឡើងនៅក្រោមកម្មវិធីសីលា ត្រូវបានបែងចែកជាប្រចាំឆ្នាំ ទៅអោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ (NCSC)- ក្រសួងជាសមាជិក និងបណ្តាក្រសួងតាមវិស័យសំខាន់ៗផ្សេងទៀត ដើម្បីគាំទ្រទៅលើការអភិវឌ្ឍន៍គោលនយោបាយ កម្មវិធីបណ្តុះបណ្តាលថ្នាក់ជាតិ និងកិច្ចគាំទ្រថ្នាក់ជាតិ និងសកម្ម-ភាពគ្រប់គ្រងផ្សេងៗទៀត ដើម្បីផ្តល់អោយមានកិច្ចគាំទ្រ និងការគ្រប់គ្រងរបស់ខេត្ត/ក្រុង ទៅលើក្រុមប្រឹក្សាឃុំ សង្កាត់ និងការបង្កើត ព្រមទាំងការអនុវត្តន៍កម្មវិធីវិនិយោគខេត្តប្រចាំឆ្នាំ និងទៅលើក្រុមប្រឹក្សាឃុំ សង្កាត់ តាមរយៈមូលនិធិឃុំ សង្កាត់”។ (Biddulph, 2006:11-13)។

មូលនិធិឃុំ សង្កាត់ គឺជាយន្តការនៃការផ្ទេរសារពើពន្ធអន្តរ-រដ្ឋាភិបាល ដើម្បីគាំទ្រដល់ការអនុវត្តន៍គំរោងវិនិយោគថ្នាក់ឃុំ ដែលបានកំណត់ឡើងតាមរយៈដំណើរការរៀបចំផែនការតាមបែបចូលរួម។ ប្រភពនៃចំណូលផ្ទាល់ខ្លួន និង ប្រព័ន្ធសំរាប់ការអនុវត្តន៍របស់ពួកគេ នៅមិនទាន់បានអភិវឌ្ឍន៍នៅឡើយ។ ដូច្នេះ ក្រុមប្រឹក្សាឃុំ សង្កាត់ពឹងផ្អែកទាំងស្រុងទៅលើ ការផ្ទេរសារពើពន្ធតាមរយៈមូល-និធិឃុំ សង្កាត់នេះ។ នៅឆ្នាំ២០០៤ ថវិការបស់មូលនិធិឃុំ សង្កាត់មានចំនួន ៥៨.០ លានរៀល ឬ

ប្រហែល១៤.៥ លានដុល្លាអាមេរិក ឬសំរាប់ជាមធ្យមស្មើនឹង ២៣.៩លានរៀល ឬស្មើនឹង ៥,៩៧០ ដុល្លាអាមេរិក សំរាប់មួយឃុំ ដែលក្នុងចំនួននេះ រដ្ឋាភិបាលបានចូលរួមបដិភាគចំនួន ១២.០ លានដុល្លាអាមេរិក និងប្រាក់បដិភាគម្ចាស់ជំនួយ (អង្គការ UNDP/DfID/Sida) តាមរយៈកម្មវិធីសីលាស្មើនឹង ២.០ លានដុល្លាអាមេរិក។ ទោះបីមានការកើនឡើងនៃការផ្ទេរប្រាក់បដិភាគរបស់រដ្ឋាភិ-បាលគួរអោយគត់សំគាល់ ទៅក្នុងមូលនិធិឃុំ សង្កាត់នៅក្នុងឆ្នាំ២០០៣ ក៏ដោយ ទំហំជាមធ្យមសំ-រាប់មួយឃុំ គឺនៅមានកំរិតទាប និងមិនទាន់គ្រប់គ្រាន់នៅឡើយទាក់ទិននឹងតម្រូវការរបស់ឃុំ (EU-UNDP, 2006, 7)។ សំរាប់ឆ្នាំ២០០៣ មានគំរោងចំនួន ៤១,៧៥៤ គំរោង ត្រូវបានអនុម័តសំ-រាប់ឃុំ តាមរយៈសិក្ខាសា ស្តីពីការធ្វើសមាហរណកម្មថ្នាក់ស្រុក។ គំរោងទាំងអស់នេះទទួលបានការគាំទ្រ: ៤៦.៣ ភាគរយ (ស្មើនឹង ១៩,០០០) ដោយបណ្តាក្រសួងតាមវិស័យនីមួយៗ ២៤.៤ ភាគរយ (ស្មើនឹង ១០,០០០) ដោយអង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយ និង ២៩.៣ ភាគរយទៀត (ស្មើនឹង ១២,០០០) ដោយ CSF (ការផ្ទេររបស់រដ្ឋាភិបាលថ្នាក់ជាតិ និងមូលនិធិម្ចាស់ជំនួយ) (Rusten, 2005:28-29) ។

សកម្មភាព CARERE បានពង្រីកទំហំដែនដីធ្វើសកម្មភាពរបស់ខ្លួនដោយយឺតៗ។ ការលោតផ្លោះដ៏ធំមួយនៃការពង្រីកសកម្មភាពនេះ បានកើតនៅឆ្នាំ២០០១។ គិតត្រឹមពាក់កណ្តាលឆ្នាំ សកម្មភាព CARERE បានគ្របដណ្តប់ទៅលើឃុំ ចំនួន៣១៨ឃុំ (ស្មើនឹង ២២ ភាគរយ នៃឃុំសរុប) និង ២,៨១៤ ភូមិ (ស្មើនឹង២៣ភាគរយ នៃភូមិសរុប) នៅក្នុងខេត្តចំនួន១១ និងក្រុងមួយ (ក្រុងប៉ៃលិន)។ នៅដើមឆ្នាំ ២០០១ កម្មវិធីបានផ្តល់ទៅដល់មនុស្សចំនួន ២.២ លាននាក់ (ស្មើនឹង ២២ ភាគរយនៃប្រជាជននៅជនបទសរុប)។ (Rudengren, Ojendal, 2002:14) ។ ការពង្រីកនេះ ទំនងជាធ្វើឡើងដើម្បីត្រៀមរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅខែ កុម្ភៈ ឆ្នាំ២០០២។ ការបង្កើតក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស នាំអោយមានតម្រូវការនៃការពង្រីកកម្មវិធីសីលានៅទូទាំងតំបន់។ នៅឆ្នាំ២០០២ ក្រុមការងារកម្មវិធីសីលា បានកៀរគរប្រភពធនធានបន្ថែមទៀត ពីដៃគូម្ចាស់ជំនួយនៅត្រឹមខែ មិនា ឆ្នាំ ២០០៣ ធ្វើអោយកម្មវិធីសីលាអនុវត្តបានទូទាំង ២៤ ខេត្ត ក្រុង ដោយគាំទ្រទៅលើឃុំ សង្កាត់ទាំងអស់ ១,៦២១ ក្រុមប្រឹក្សាឃុំ សង្កាត់នៅទូទាំងប្រទេស។ នៅពេលបច្ចុប្បន្ននេះនៅទូទាំងប្រទេសកម្ពុជា មានខេត្ត ២០ និងក្រុង ៤ រួមមាន ទីក្រុងភ្នំពេញ ក្រុង

ព្រះសីហនុ ក្រុងកែប និងក្រុងប៉ៃលិន និងមានស្រុកសរុបចំនួន ១៧១ស្រុក និងខណ្ឌ១៤ ឃុំ១៥១០ និងសង្កាត់ ១១១ សង្កាត់។

ពីអ្នកធ្វើប្រតិបត្តិការជាម្ចាស់ជំនួយ អង្គការ CARERE បានផ្លាស់ប្តូរដោយយឺតៗ មកជាអ្នកប្រតិបត្តិការរបស់រាជរដ្ឋាភិបាលកម្ពុជាវិញ ដែលជាដំណើរការមួយដែលមានឈ្មោះដូចបានហៅពីខាងលើ គឺកម្មវិធីសីលា (ដោយយកតាមពាក្យខ្មែរ)។ ចលនាឆ្ពោះទៅរក "ភាពជាម្ចាស់នៅថ្នាក់ជាតិ" នៃកម្មវិធិសីលា តម្រូវអោយមានការបង្កើតអង្គការអន្តរក្រសួងមួយដែលមានឈ្មោះថា **ក្រុមការងារកម្មវិធីសីលា** ដើម្បីដឹកនាំដំណើរការទាំងមូលនៅថ្នាក់ជាតិ ។ ការនេះ បានប្រើពេលវេលាមួយចំនួនដើម្បីបង្កើតនូវក្រុមការងារ ដោយសារតែ ស្ថានភាពគានតឹងផ្នែកនយោបាយនៅក្នុងឆ្នាំ ១៩៩៦-១៩៩៧។ ជាចុងក្រោយ ក្រុមការងារនេះ ក៏ត្រូវបានបង្កើតឡើងមែន បន្ទាប់ពីការបោះឆ្នោតនៅឆ្នាំ ១៩៩៨ ក្រោយពីមានការតស៊ូមតិមួយចំនួនពីអភិបាលខេត្ត និងទីភ្នាក់ងារពាក់ព័ន្ធសំខាន់ៗ ដទៃទៀត។ (Biddulph, 2006:122)។ ក្រោយឆ្នាំ២០០១ ការងារសម្របសម្រួល និងការដឹកនាំគោលនយោបាយជាច្រើនរបស់ក្រុមការងារកម្មវិធីសីលា ត្រូវបានផ្ទេរទៅអោយគណៈកម្មាធិការជាតិគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ (NCSC) ដោយមុខងារជាលេខាធិការដ្ឋានត្រូវផ្តល់ទៅអោយនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន (DoLA) នៃក្រសួងមហាផ្ទៃ។

នៅកម្ពុជា មានបញ្ហាក្នុងការសម្របសម្រួល ដោយសារ ការងារវិមជ្ឍការ និងវិសហមជ្ឍការ ត្រូវបានចាត់គេទុកថា ជាកំណែទម្រង់ពីរដាច់ដោយឡែកពីគ្នា ជាជាងកំណែទម្រង់ដែលប្រទាក់គ្នាទៅវិញទៅមក ដែលមានការគ្រប់គ្រងដោយគណៈកម្មាធិការអន្តរក្រសួងពីរដាច់ដោយឡែកពីគ្នា គឺ NCSC និងក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល (CAR) ។ កង្វះនៃការសម្របសម្រួលនេះបានធ្វើអោយមានបញ្ហាបន្ថែមទៀតផងដែរដែលថា កំណែទំរង់ទាំងពីរមានលទ្ធភាពទទួលបានធនធានយ៉ាងច្រើនពីប្រភពមូលនិធិ និងម្ចាស់ជំនួយផ្សេងៗពីគ្នា ដែលប្រភព និងម្ចាស់ជំនួយតែងផ្តោតទៅលើការងារតែមួយ ក្នុងចំណោមការងារទាំងពីរ។ បញ្ហាបង្កការប្រមូលផ្តុំកាន់តែច្រើនថែមទៀត ជាពិសេស បញ្ហាមុខងារសំខាន់ៗក្នុងការផ្តល់សេវាបច្ចេកទេស និងការជួយសម្រួល ដល់ឃុំ សង្កាត់ ដោយរដ្ឋបាលថ្នាក់ខេត្ត និងថ្នាក់ស្រុក ដែលនៅតែបន្តពឹងផ្អែកទៅលើមូលនិធិ តាមរយៈយន្តការកម្មវិធីសីលា។ (Rusten, 2005: 45)។

ភាគច្រើននៃឯកសាររបស់អ្នកស្រាវជ្រាវនៃអង្គការ CARERE/សីលា និយាយថា វាជាជោគជ័យ។ "ដោយគ្មានអ្វីត្រូវឆ្ងល់ នៅពាក់កណ្តាលឆ្នាំ ២០០២ គោលការណ៍វិមជ្ឈការ និងគោលការណ៍ដែលបានចាក់គ្រឹះជាលើកដំបូង ត្រូវបានគេធ្វើការសាកល្បង និងយកលំនាំតាមដោយស្ថាប័នផ្សេងៗនៅពេលបច្ចុប្បន្ននេះ។ ជាងនេះទៅទៀត គោលការណ៍នេះបានបំរើអោយយុទ្ធសាស្រ្តក្នុងការធ្វើផែន-ការ និងកិច្ចការហិរញ្ញវត្ថុតាមបែបវិមជ្ឈការ សំរាប់ការងារអភិវឌ្ឍន៍ ព្រមទាំងបានអភិវឌ្ឍទៅជាគោលនយោបាយជាតិផងដែរ។ បទពិសោធន៍ និងការងារបច្ចេកទេសជាមូលដ្ឋាន សំរាប់ការងារអភិបាលកិច្ចមូលដ្ឋាន និងការអភិវឌ្ឍន៍តាមបែបចូលរួម ត្រូវបានប្រមែប្រមូលចងក្រងបានយ៉ាងល្អទៀតផង។ ដោយធ្វើការប្រៀបធៀបជាមួយនឹងឯកសារគំរោង វាហាក់បីដូចជាបានបង្ហាញអោយឃើញថា គំរោងសកម្មភាព CARERE 2/កម្មវិធីសីលា គឺជាជោគជ័យពិតប្រាកដមែន។ ដូចដែលយើងអាចនឹងពិនិត្យមើលក្នុងរបាយការណ៍ផងដែរ ភាពជោគជ័យយ៉ាងខ្លាំងគឺមានលក្ខណៈជាចរិតដោយផ្តោតទៅលើដំណើរការដោយប្រយោលខុសៗគ្នា នៅក្នុងចំណោមសកម្មភាពផ្សេងៗគ្នា មានដូចជា ការបើកអោយមានកិច្ចសន្ទនាផ្នែកគោលនយោបាយប្រកបដោយតម្លាភាពបន្ថែមទៀត និងការប្រមូលយកបទពិសោធន៍ដើម្បីលើកកំពស់ការគ្រប់គ្រងធនធានធម្មជាតិជាដើម"។ (Rudengren, Ojendal, 2002: 7-8)។

ពាក់ព័ន្ធទំហំនៃមុខងារដែលបានប្រគល់ជូនទៅអោយពួកគេ ការបូកបញ្ចូលគ្នានៃការចំអកឡកឡឺយ និងទុទិដ្ឋិនិយមទាក់ទិនក្រុមប្រឹក្សាឃុំ អាចអោយយល់បាន។ តែប៉ុន្តែ តាមរយៈដំណើរការធ្វើផែនការតាមបែបចូលរួម មិនថាមានការកំរិតប៉ុនណា ហើយការអនុវត្តន៍គំរោងមិនថាអាចជួយកាត់បន្ថយភាពក្រីក្របានប៉ុនណានោះទេ ទាំងអស់នេះសុទ្ធតែបានរួមចំណែកនៅក្នុងការអនុវត្តន៍ជាក់ស្តែងតាមបែបលិទ្ធិប្រជាធិបតេយ្យ ដែលអាចក្លាយទៅជាមូលដ្ឋានមួយសំរាប់ការងារនៅពេលអនាគត។ មានប្រភពសុទិដ្ឋិនិយមចំនួនពីរជាគន្លឹះ :"សមាជិកក្រុមប្រឹក្សាដែលចូលរួមពាក់ព័ន្ធនៅក្នុងការសិក្សានេះហាក់បីដូចជាដឹងអំពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ប៉ុន្តែសំរាប់ពេលនេះ ពួកគេនៅស្ទាក់-ស្ទើរនៅឡើយ ក្នុងការធ្វើសេចក្តីសំរេចចិត្ត ហើយពួកគេពឹងផ្អែកទៅលើជំនួយការរបស់ DFT (បុគ្គលិកថ្នាក់ស្រុក) និងការិយាល័យស្រុក..." (Rusten, 2005: 99)។ ជាការបន្ថែម គេមានភស្តុ-តាងតិចតួចណាស់ទាក់ទិននឹង "ការទាក់ទាញវរជន"។ បើធ្វើការប្រៀបធៀប ដោយសារមូលនិធិមានតិចតួច ហើយដំណើរការបែងចែកមានលក្ខណៈជាចំហរ ធ្វើអោយវរជននៅមូលដ្ឋានពុំសូវមាន

ចំណាប់អារម្មណ៍ប៉ុន្មានទេ។ គារដាក់កំរិតខ្លាំងពេករបស់ក្រុមប្រឹក្សា និងកិច្ចគាំទ្រដែលមានចំពោះពួកគាត់ អាចក្លាយទៅជាមូលដ្ឋានគ្រឹះមួយសំរាប់ពួកគាត់ បញ្ចុះបញ្ចូលដើម្បីដោះស្រាយចំពោះការកំរិតទាំងនេះ។ ប៉ុន្តែមានបញ្ហាធ្ងន់ធ្ងរ។

## ផលប៉ះពាល់

សវនកម្មបច្ចេកទេសដែលបានធ្វើឡើងកាលពីឆ្នាំ២០០៦ គ្របដណ្តប់ទៅលើគំរោងចំនួន១២០ បានធ្វើការសន្និដ្ឋានថា "ជាទូទៅ លទ្ធផលមានភាពវិជ្ជមាន ដោយបានរកឃើញលទ្ធផលនៅនឹងកន្លែង ហើយ៨០ ភាគរយ នៃគំរោង បានទទួលលទ្ធផលផ្នែកគុណភាពដែលអាចមើលឃើញ នៃកិច្ចសន្យា យ៉ាងហោចណាស់ ៩៧.៥ភាគរយ។ ផ្ទុយទៅវិញ ក្រុមការងារក៏បានរកឃើញផងដែរនូវចំណុចតិចតួចបំផុតដែលមានសារសំខាន់របស់គំរោង ទាក់ទិននឹងការបង្កើតគំរោងមិនបានល្អ ឬដោយសារមិនបានអនុវត្តទៅតាមគំរូប្លង់សកម្មភាព ដែលធ្វើអោយមានចំណុចខ្សោយនៅក្នុងគំរោង និងធ្វើឱ្យបាត់បង់គុណតម្លៃដ៏មានសក្តានុពលរបស់គំរោង"។ (Biddulph, 2006: 21)។ ឯកសារអភិវឌ្ឍន៍មិនមានបង្ហាញអំពីកំរិតនៃអំពើពុករលួយសំខាន់ៗណាមួយនោះទេ។ "តាមភស្តុតាងដែលបានបង្ហាញ ការសូកប៉ាន់ ហាក់ដូចជាមានតូចតួចប៉ុណ្ណោះ (ប្រហែល១.៣ភាគរយ) ហើយគេអាចប្រកែកបានថា វាមិនមែនដោយសារតែការស៊ីសំណូកតែមួយនោះទេ ដែលជាហេតុធ្វើអោយមានការបែកបាក់នៅក្នុងទំនាក់ទំនងរវាងអ្វីដែលបានធ្វើកិច្ចសន្យា និងអ្វីដែលបានប្រគល់"។ (Biddulph, 2006: 29)។

ប៉ុន្តែ ផលប៉ះពាល់ទៅលើភាពក្រីក្របានពី ការវិនិយោគនៅលើការអភិវឌ្ឍន៍របស់ឃុំ នៅមានកំរិតនៅឡើយ។ ប្រាក់វិភាគទានរបស់មូលនិធិឃុំ សង្កាត់ គឺប្រហែលស្មើនឹង ១ ដុល្លាអាមេរិក សំរាប់មនុស្សម្នាក់ក្នុងមួយឆ្នាំ ដែលជាការងារដ៏លំបាកមួយដែលចំនួននៃវិភាគទាននេះ មិនអាចនឹងជួយលើកកំពស់អ្វីមួយអោយឃើញធ្លោរនោះបានទេ។ ការវិភាគទានរបស់កម្ពុជាចំពោះហេដ្ឋារចនាសម្ព័ន្ធ ដែលរងនូវភាពខ្ទេចខ្ទាំដោយសារសង្គ្រាមជាច្រើនទសវត្សរ៍គឺជារឿងធំដោយឡែកមួយផ្សេងទៀត។ នៅចុងបញ្ចប់ សង្ឃឹមថា បទពិសោធន៍របស់ក្រុមប្រឹក្សាឃុំ នឹងរួមចំណែកនៅក្នុងការងារអភិបាលកិច្ច ហើយនឹងនៅពេលក្រោយមកទៀត នឹងរួមចំណែកដល់ការអភិវឌ្ឍន៍។ "អត្ថប្រយោជន៍ជាច្រើនដែលរំពឹងទុកក្នុងការកាត់បន្ថយភាពក្រីក្រ មានការពាក់ព័ន្ធទៅនឹងការផ្លាស់ប្តូររយៈពេល

វែងក្នុងការងារអភិបាលកិច្ច និងការបែងចែកអំណាច - ជាមួយនឹងគោលបំណងធ្វើអោយប្រជាពលរដ្ឋបានយល់ដឹងកាន់តែប្រសើរឡើង និងមានតម្រូវការកាន់តែច្រើនឡើងថែមទៀត ដែលចេញពីសកម្មភាពទាំងនេះ រដ្ឋ និងផ្នែកឯកជនគឺជាអ្នកផ្តល់សេវា គ្របដោយការឆ្លើយតប និងគណនេយ្យ-ភាពនាំទៅដល់ការលើកកំពស់ជារួមនៅក្នុងការងារផ្តល់សេវាកម្មទាំងលក្ខណៈតូចតាច និងទាំងនៅក្នុងការគ្រប់គ្រងធនធានធំៗរបស់ប្រទេស។ (Biddulph, 2006: 23)។

## ការធ្វើផែនការ

ដំណើរការធ្វើផែនការអភិវឌ្ឍន៍ ពឹងផ្អែកទាំងស្រុងទាំងលើគំរោងប្លង់ការងារវិមជ្ឈការរបស់កម្មវិធីសីលា។ "ដំណើរការធ្វើផែនការតាមបែបចូលរួម ចាប់ផ្តើមពីកិច្ចប្រជុំធ្វើគំរោងអាទិភាពរបស់ភូមិដែលធ្វើឡើងតាមការកោះហៅរបស់ប្រធានភូមិ នៅរាល់ខែសីហា រៀងរាល់ឆ្នាំនីមួយៗ។ការប្រជុំស្ថិតក្រោមការគ្រប់គ្រង និងក្រោមគណអធិបតីរបស់ប្រធានឃុំ ដោយមានវត្តមានរបស់បុគ្គលិកពីថ្នាក់ស្រុកដែលពាក់ព័ន្ធ។ បន្ទាប់មក ផែនការភូមិត្រូវបានដាក់ជូនកិច្ចប្រជុំសមាហរណកម្មនៅថ្នាក់ស្រុក ដែលនៅទីនេះហើយដែលផែនការអភិវឌ្ឍន៍ឃុំ (CDP) ត្រូវបានបង្កើតឡើង។ បន្ទាប់មកទៀតផែនការអភិវឌ្ឍន៍ឃុំ ត្រូវបានបញ្ជូនទៅ POLA តាមរយៈបុគ្គលិកថ្នាក់ស្រុក (DFT) នឹងចែកចាយទៅតាមនាយកដ្ឋានដែលពាក់ព័ន្ធ។ CDP ក៏បានបញ្ជូនផងដែរទៅកាន់អភិបាល ដែលជាគោលការ-ណ៍ គាត់អាចទទួលយក ឬច្រានចោលផែនការនោះ។ (Rusten, 2005: 80)។ អភិបាល ត្រង់ចំណុចនេះ គាត់គ្មានការត្រួតត្រាច្រើនទេ ទាក់ទិននឹងការចែងចែកធនធានរបស់ទីភ្នាក់ងារពាក់ព័ន្ធ ដែលទីភ្នាក់ងារពាក់ព័ន្ធទាំងនេះ មានការិយាល័យទាំងនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក។ និយាយម្យ៉ាងទៀតថា ចំពោះការធ្វើសេចក្តីសំរេច គឺធ្វើពីលើចុះក្រោម មានន័យថា ថ្នាក់កណ្តាលធ្វើសេចក្តីសំរេចសំរាប់ PRDC, PRDC ធ្វើអោយ DIW ធ្វើបន្តគ្នារហូតដល់ថ្នាក់ភូមិ។

មានចំណុចជាច្រើនដែលអាចលើកមកនិយាយបាន ទាក់ទិននឹងដំណើរការធ្វើផែនការនេះ។ ដំបូងសុចរឹតភាព និងសក្តានុពលនៃការធ្វើលិទ្ធិប្រជាធិបតេយ្យភាវូបនីយកម្ម នៃដំណើរការធ្វើផែនការអភិវឌ្ឍន៍ភូមិ និងផែនការអភិវឌ្ឍន៍ឃុំ អាចធ្វើអោយខ្ពស់ជាអតិបរមាទៅបានដរាបណា ការទទួល-ស្គាល់យ៉ាងពេញលេញរបស់គំរោង មិនតម្រូវអោយពង្រីកដំណើរការហួសពីឃុំនោះទេ។ ដោយ

សារធនធាន និងអំណាចរបស់ឃុំនៅមានកំរិតនៅឡើយ នៅត្រង់ចំណុចនេះពិតជាមិនទាន់អាចធ្វើទៅបាននៅឡើយ។ បញ្ហាមួយក្នុងចំណោមបញ្ហាផ្សេងៗទៀត គឺថា ឃុំភាគច្រើន គ្មានសមត្ថភាព-ផ្នែកបច្ចេកទេស ដើម្បីអនុវត្តគំរោង។ ថ្នាក់ស្រុកមានសមត្ថភាព ប៉ុន្តែជាក់ស្តែង ពុំមានអ្វីច្រើនត្រូវធ្វើនោះទេ។ ដរាបណាច្បាប់រៀបចំអង្គការថ្មីស្តីពី វិសហមជ្ឈការ មិនទាន់បានអនុម័ត តួនាទីរបស់ថ្នាក់ស្រុក នៅតែស្ថិតក្នុងស្ថានភាពរង់ចាំជាបន្ទាន់។ ខេត្តមានតួនាទីដ៏សំខាន់ ប៉ុន្តែ "ផែនការខេត្តរបស់ក្រសួងនៅថ្នាក់ជាតិ នៅកំពុងធ្វើការអភិវឌ្ឍន៍នៅឡើយ ដោយពុំមានការពិភាក្សា និងការសម្របសម្រួលជាមុន ជាមួយឃុំ នោះឡើយ។ ដូច្នេះ ផែនការរបស់ទីភ្នាក់ងារខ្សែបណ្តោយខេត្តត្រូវបានលើកយកមកបង្ហាញនៅក្នុង សិក្ខាសាលាធ្វើសមាហរណកម្មថ្នាក់ស្រុក ដើម្បីអោយឃុំធ្វើការពិចារណា។ ការនេះ នាំឱ្យមានសំណួរទាក់ទិននឹងសារសំខាន់នៃ ដំណើរការធ្វើផែនការតាមបែបចូលរួម។ គោលការណ៍ "ទទួលយក ឬមិនទទួលយក" ត្រូវបានគេជ្រួតជ្រាប ហើយវាហាក់បីដូចជា តំណាងថ្នាក់ខេត្តនៃទីភ្នាក់ងារខ្សែបណ្តោយ មិនបានធ្វើមជ្ឈន្តិកៈទៅលើស្មារតីនៃការងារវិមជ្ឈការនោះឡើយ (NGO Forum, 2004: 8)។

បញ្ហាជាច្រើនបានបង្ហាញអោយឃើញ តាំងពីការចាប់ផ្តើមដំបូងនៃដំណើរការនៅថ្នាក់ភូមិមកម្ល៉េះ។ អ្នកភូមិកម្ពុជា ពុំមានបទពិសោធន៍នៅក្នុងការធ្វើផែនការថ្នាក់ភូមិទេ ធ្វើឱ្យដំណើរការមានការចូលរួមតិចតួច។ ដើម្បីដោះស្រាយបញ្ហាសមត្ថភាព និងដើម្បីអោយមានការចូលរួមនៃជនដែលមានសមត្ថភាពពេញលេញ គេគួររៀបចំអោយមានការណែនាំអំពី ដំណើរការដ៏ល្អិតល្អន់ដោយយកតាមរបៀបនៃការវិភាគស្ថានការតាមបែប PRA រួមជាមួយនឹងគោលការណ៍ណែនាំលំអិតសំរាប់ការធ្វើ-សេចក្តីសំរេចចិត្ត។ វិធានដែលមានស្រាប់មួយចំនួនដែលលើកទឹកចិត្តដល់ការចូលរួម ដូចជា ដំណើរការទាំង១១ នៃការធ្វើផែនការ លក្ខខណ្ឌតម្រូវចំនួន៧០ភាគរយ នៃចំនួនប្រជាជនដែលចូលរួម សុទ្ធតែមានលក្ខណៈការិយាធិបតេយ្យហួសហេតុពេក។ ដោយសារថា ការបរិច្ចាកទៅក្នុងវិភាគទានសហគមន៍គ្មានលក្ខណៈប្រាកដប្រជា មានការសិក្សាមួយបង្ហាញថា "...លើកលែងតែឃុំ សង្កាត់ណាដែលបានប្រមូលវិភាគទានបានពេញលេញហើយប៉ុណ្ណោះ ទើបមានមន្ត្រីមូលដ្ឋាន ឬអ្នកជំនួញបង់វិភាគទានចូលរួម ក្នុងនាមប្រជាពលរដ្ឋ" (Biddulph, 2003: 30)។

ផែនការរបស់ក្រុមប្រឹក្សាក្លាយទៅជាសុទិដ្ឋិនិយមៈ អ្វីដែលបានបង្ហាញឡើងនៅក្នុង CIP គឺជាបញ្ជីបំណងប្រាថ្នាមួយ មិនថា ជាបញ្ជីសំរាប់ចុះឈ្មោះរបស់អ្វីមួយសំរាប់ការសន្យាខាងជំនួយដែល *នឹងបានទទួល* ឬមួយ ជាអ្វីម្យ៉ាងផ្សេងទៀតដែលត្រូវលៃទុកដោយឡែកជាបន្ទាន់ នៅពេលណាមានការផ្តល់ជំនួយថ្មីណាមួយបានមកដល់នោះទេ។ សមាជិកក្រុមប្រឹក្សាដែលធ្លាប់ឆ្លងកាត់ស្ថានភាពបែបនេះ និយាយថា ផែនការ ឬថវិការបស់ពួកគេ គឺ "គ្រាន់តែជាសេចក្តីសង្ខេបខ្ទីច្បាស់លាស់ និងងាយយល់"។ ការទទួលខុសត្រូវបានក្លាយទៅជាច្រើនពេក ដែលជាហេតុធ្វើអោយគណនេយ្យភាពក្លាយទៅជា ស្រពិចស្រពិល និងធ្វើអោយលទ្ធផលកាន់តែខ្សោយទៅៗ។ កិច្ចការធ្វើផែនការ និងការរៀបចំថវិកា ដែលខ្លួនត្រូវមានគណនេយ្យភាពចំពោះកិច្ចការទាំងអស់នេះ បានក្លាយទៅជា ការងារមិនសូវសំខាន់ ជជាងការរៀនសូត្រជំនាញនយោបាយ ក្នុងការអូសទាញការគាំទ្រ ក៏ដូចជា ការងារនយោបាយក្នុងការបំពេញចិត្តសហគមន៍ និងការដោះស្រាយវិវាទដែលកើតចេញពីបញ្ហាទាំងនេះ។ សមាជិកក្រុមប្រឹក្សានៅគាស់ក្រឡ ម្នាក់ទៀតបាននិយាយថា "យើងមិនប្រកួតប្រជែងគ្នាខ្លាំងពេកទេ.... ព្រោះនាំអោយយើងឈ្លោះគ្នា" (ការសិក្សាឯករាជ ២០០៦: ២៤)។

## សមត្ថភាពផ្នែកសារពើពន្ធ

ស្ថានភាពសារពើពន្ធរបស់ឃុំ ដែលសំបូរទៅដោយមុខងារជាច្រើនដែលត្រូវធ្វើ ប៉ុន្តែមានលុយតិចតួចប៉ុណ្ណោះ គឺជាឧបសគ្គដ៏ចំបង។ ឃុំ សង្កាត់ភាពច្រើននៅមិនទាន់មានសូម្បីតែសំភារៈជួយសំរួលសំរាប់ការិយាល័យផ្ទាល់ខ្លួននៅឡើយ ហើយត្រូវយកទីកន្លែងទំនេររបស់គណបក្សនយោបាយ អគារសាលារៀន និងវត្តធ្វើជាកន្លែងធ្វើការរបស់ខ្លួន។ ឃុំ សង្កាត់មិនអនុញ្ញាតអោយប្រើប្រាស់ឥណតានកម្មីសំរាប់កិច្ចអភិវឌ្ឍន៍របស់ខ្លួនចេញពីមូលនិធិឃុំ សង្កាត់ ដើម្បីកសាងអាគារការិយាល័យរបស់ខ្លួននោះឡើយ។ "ជាគោលការណ៍ មូលនិធិជាមធ្យមសំរាប់ក្នុងមួយឃុំ នៅឆ្នាំ២០០៣ មានចំនួន ៥,០០០ ដុល្លាអាមេរិក សំរាប់កិច្ចការអភិវឌ្ឍន៍ និង៣,០០០ ដុល្លាអាមេរិក សំរាប់ការងាររដ្ឋបាល។ ដោយសារការធ្លាក់ចុះប្រមាណ ៥០ភាគរយ និង៤០ភារយ សំរាប់មូលនិធិនីមួយៗសំរាប់ការងារដូចបានពោលពីខាងលើនៃមូលនិធិឃុំ សង្កាត់ ធ្វើអោយចំនួនជាមធ្យមសំរាប់ការអភិវឌ្ឍន៍នៅត្រឹមតែ ២,៥០០ ដុល្លាអាមេរិក សំរាប់មួយឃុំ និងប្រហែល ១,៨០០ ដុល្លាអាមេរិក សំរាប់ការងាររដ្ឋបាល។ ជាមួយនឹងកំណើននៃប្រាក់ចំណូលក្នុងស្រុកនៃចំណែករបស់រដ្ឋាភិបាលនៅមូលដ្ឋាន ពី២ ទៅ ២.៥

ភាគរយ នៅឆ្នាំ២០០៤ និងការរំពឹងទុកថានឹងមានការបែងចែកទៅតាមផែនការ មូលនិធិសំរាប់ការអភិវឌ្ឍន៍ឃុំ គិតជាមធ្យមមានចំនួនប្រហែល ៦,០០០ ដុល្លាអាមេរិក" (Rusten, 2005: 92)។ ដូច្នេះឃើញថា ចំនួនទឹកប្រាក់មានតិចតួចពេក សំរាប់អង្គភាពរបស់រដ្ឋាភិបាលមួយដែលមានការទទួល-ខុសត្រូវរហូតដល់ ២៥០០-៣០០០ ខ្នងផ្ទះ ដែលមានចំនួនមនុស្សប្រមាណពី ១៥,០០០ — ២០,០០០ នាក់ នៅក្នុងភូមិចំនួនចាប់ពី ៨ ទៅ១៥ ភូមិនោះ។

ប្រសាសន៍ធ្ងន់ៗក្នុងសេចក្តីថ្លែងសន្ទរកថាថ្មីៗនេះរបស់ឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ មានប្រសាសន៍ថា "...កង្វះខាតខាងផ្នែកសារពើពន្ធតាមបែបវិមជ្ឈការ គឺជាកត្តា ដ៏ចំបងដែលដាក់កំហិតទៅលើសកម្មភាព និងការរីកចំរើនរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ដោយមានតែ *ឆន្ទានុសិទ្ធិដើម្បីជ្រើសរើស និង កំណត់កិច្ចការអាទិភាព គឺគ្រាន់តែជាអំណាចទទេរ* សំរាប់កិច្ចការ-អភិវឌ្ឍន៍ រួមទាំង ការរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រផងដែរ។ ទោះជាយ៉ាងនេះក្តី ជាដំបូង គេត្រូវបែងចែក *ធនធានថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានអោយបានសមស្រប និងគួរអោយទុកចិត្តបាន*។ ហិរញ្ញប្បទានឃុំ គឺច្បាស់ណាស់ថា *ជាការងារអាទិភាពសំរាប់អនាគតដ៏ឆាប់ៗបំផុត* ដោយចងចាំនៅក្នុងចិត្តថា ប្រភេទ និងវិសាលភាពនៃវិមជ្ឈការសារពើពន្ធ គឺទំនងជាសូចនាករដ៏ល្អប្រសើរបំផុតនៃប្រភេទ និងវិសាលភាពនៃការងារវិមជ្ឈការ និងការប្តេជ្ញាចិត្តពិតប្រាកដរបស់រដ្ឋាភិបាលថ្នាក់ជាតិ" (ព្រុំ សុខា, ២០០៧: ១៩)។

## ការកសាងសមត្ថភាព

នៅចុងបញ្ចប់ ការរួមចំណែកដ៏ធំបំផុតនៃដំណើរការវិមជ្ឈការ នៅត្រង់ចំណុចនេះ ប្រហែលដោយសារបទពិសោធន៍ដ៏ល្អដែលគេបានទទួល និងអ្វីៗដែលមន្ត្រីនៅមូលដ្ឋាន និងជាពិសេសសមាជិកក្រុមប្រឹក្សាឃុំតែម្តង បានរៀនសូត្រកន្លងមក។ ប៉ុន្តែ ដោយសារតែសមត្ថភាពរបស់សមាជិកក្រុមប្រឹក្សាឃុំ ជាទូទៅនៅមានកំរិតទាបនៅឡើយ ការផ្តោតការយកចិត្តទុកដាក់ជាច្រើនត្រូវបានគេធ្វើឡើងចំពោះការកសាងសមត្ថភាព។ សមាជិកក្រុមប្រឹក្សាឃុំមួយចំនួនធំ មានកង្វះខាតខាងលក្ខណៈ-សម្បត្តិក្នុងការអប់រំ និងជំនាញ ដែលអាចផ្តល់លទ្ធភាពអោយពួកគាត់បំពេញអាណត្តិការងាររបស់ខ្លួន ប្រកបដោយប្រសិទ្ធិភាព។ ទោះបីជាតាមផ្លូវច្បាប់តម្រូវអោយសមាជិកក្រុមប្រឹក្សាឃុំ ត្រូវចេះ

អក្សរ ប៉ុន្តែពួកគាត់ភាគច្រើនមានសមត្ថភាពមិនដល់កំរិតមួយដែលអាចបំពេញមុខងារបាន។ បញ្ហាមួយផ្សេងទៀត គឺដោយសារប្រាក់ខែរបស់រដ្ឋាភិបាលមានកំរិតទាប ដែលជាមធ្យមពីរវាង ៨០,០០០ រៀល ទៅ ១២,០០០ រៀល ក្នុងមួយខែ (២០-៣០ ដុល្លាអាមេរិក/ខែ ឬ ១៦-២៤ អ៊ឺរ៉ូ/ខែ) ដែលជាហេតុមានការលំបាកក្នុងការជួល ក៏ដូចក្នុងការរក្សាទុកបុគ្គលិកដែលមានលក្ខណៈសម្បត្តិ។

របាយការណ៍ និងការវាយតម្លៃនានាបានបង្ហាញថា សមាជិកក្រុមប្រឹក្សាចាប់យកតួនាទីរបស់ខ្លួនដោយមធ្យ័តបំផុត។ ពួកគាត់កំពុងមានជំនឿចិត្តក្នុងការធ្វើផែនការរបស់ខ្លួន ប៉ុន្តែមានអារម្មណ៍ពឹងផ្អែកទៅលើបុគ្គលិកថ្នាក់ស្រុក (DFT)។ ពួកគាត់រីករាយចំពោះវគ្គបណ្តុះបណ្តាលផ្សេងៗ និងមានសំណូមពរដ៏ទទូចដើម្បីធ្វើអោយពួកគាត់កាន់តែប្រសើរឡើងថែមទៀត។ មានកម្មវិធីបណ្តុះបណ្តាលពហុជំនាញជាច្រើនបានធ្វើឡើងដល់សមាជិកក្រុមប្រឹក្សាឃុំជាច្រើនឆ្នាំ ដែលធ្វើអោយសមាជិកមួយចំនួនធំត្អូញត្អែរថា ជួនពេលខ្លះខ្លួនគ្មានពេលវេលាសំរាប់បំពេញភារកិច្ចដទៃទៀតរបស់ខ្លួន។ ពួកគាត់បានយល់ដឹងខ្លួនថា កំរិតអប់រំទាបរបស់ខ្លួន បានធ្វើអោយពួកគាត់មានការលំបាកនៅក្នុងកម្មវិធីបណ្តុះបណ្តាល ប៉ុន្តែពួកគាត់បានចង្អុលបង្ហាញថា មានគ្រូឧទ្ទេសនាមខ្លះមានការយល់ដឹងទៅលើប្រធានបទនោះ តិចតួចជាងពួកគាត់ទៅទៀត។ ពួកគាត់បានត្អូញត្អែរថា សំភារៈហ្វឹកហ្វឺន មានលក្ខណៈពិបាកយល់។ ដោយសារសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់មានបទពិសោធន៍ប្រាំឆ្នាំរួចមកហើយ វាអាចមានប្រយោជន៍ប្រសិនបើអោយពួកគាត់ជួយរៀបចំធ្វើគំរូប្លង់សំភារៈបណ្តុះបណ្តាលដោយខ្លួនគាត់ផ្ទាល់។

## ដំណាក់កាលចុងក្រោយបង្អស់-ក្របខ័ណ្ឌយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ ២០០៥-០៦

នៅពេលដែលផ្លូវទាល់ច្រកដ៏យូរអង្វែងមួយ ក្នុងការបង្កើតរដ្ឋាភិបាលបានកើតមានបន្ទាប់ពីការបោះឆ្នោតឆ្នាំ ២០០៣ ហើយត្រូវបានដោះស្រាយរួចរាល់នៅពាក់កណ្តាលឆ្នាំ២០០៤ កិច្ចព្រមព្រៀងស្តីពីការងារវិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានគេជ្រើសយក។ លទ្ធផលដំបូង គឺការបង្កើនល្បឿនក្នុងការបង្កើត និងការព្រមព្រៀងទៅលើយុទ្ធសាស្ត្រមួយ សំរាប់ការងារវិមជ្ឈការ និងវិសហមជ្ឈការ។ សិក្ខាសាលាថ្នាក់ជាតិមួយ ស្តីពី ក្របខ័ណ្ឌយុទ្ធសាស្ត្រ ត្រូវបានធ្វើឡើង ចាប់ពីថ្ងៃទី ១-២ ខែមេសា

ឆ្នាំ២០០៥ ដោយមានការចូលរួមពាក់ព័ន្ធដោយមន្ត្រីរាជរដ្ឋាភិបាលកម្ពុជា។ រដ្ឋមន្ត្រីក្រសួង និង រដ្ឋលេខាធិការមួយរូបពីគ្រប់ក្រសួងទាំងអស់ បូករួមនឹងអ្នកធ្វើគោលនយោបាយ អភិបាល និងអភិបាលរងទីមួយ និងបុគ្គលិកពីររូបទៀត ពីគ្រប់ខេត្ត ក្រុងទាំងអស់ ទីភ្នាក់ងារ អង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយ ដែលសរុបទាំងអស់មានចំនួនច្រើនជាង ៣០០នាក់។ គោលបំណងរបស់សិក្ខាសាលាគឺដើម្បីផ្សព្វផ្សាយ និងពិភាក្សាសេចក្តីព្រាង មុននឹងដាក់ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីអនុម័តជាផ្លូវការ។ បន្ទាប់ពីឆ្លងកាត់ការពិគ្រោះយោបល់ និងការពិនិត្យផ្ទៃក្នុងនៅក្នុងជួររដ្ឋាភិបាលរួចមក ក្របខ័ណ្ឌយុទ្ធសាស្ត្រ ស្តីពី វិមជ្ឈការ និងវិសហមជ្ឈការ ត្រូវបានអនុម័តជាផ្លូវការដោយទីស្តីការគណៈរដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥។

នៅដំណាក់កាលចុងក្រោយបង្អស់នេះ គឺការពាក់ព័ន្ធជាមួយនឹងបញ្ហា/លក្ខខណ្ឌតម្រូវដែលជាប់ទាក់ទងគ្នាទៅវិញទៅមក សំរាប់ការបង្កើនល្បឿនដំណើរការវិមជ្ឈការ។ ទីមួយ គឺមានតម្រូវការដើម្បីធ្វើអោយកាន់តែមានប្រសិទ្ធិភាពនៃការគ្រប់គ្រង និងការអនុវត្តន៍កំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ជាតិ។ ទីពីរ កម្មវិធីសីលាត្រូវបានពង្រីកត្រឹមតែមួយឆ្នាំប៉ុណ្ណោះរហូតដល់បំណាច់ឆ្នាំ ២០០៦ ដូច្នេះ ក្របខ័ណ្ឌថ្មីមួយសំរាប់កិច្ចសហការរវាងម្ចាស់ជំនួយ និងរាជរដ្ឋាភិបាលកម្ពុជា ត្រូវតែរកមធ្យោបាយដោះស្រាយ។ ទីបី អវត្តមាននៃរដ្ឋាភិបាលមូលដ្ឋានបន្ទាន់មួយដែលនៅពីលើឃុំ ដែលជាឧបសគ្គដ៏ចំបងមួយនៅក្នុងការបង្កើនល្បឿននៃការងារវិមជ្ឈការ ត្រូវតែធ្វើការដោះស្រាយអោយបាន។ ក្នុងការអភិវឌ្ឍន៍ និងអនុវត្តន៍ដំណើរការកំណែទំរង់ការងារវិមជ្ឈការ និង វិសហមជ្ឈការ ផ្នែកដ៏សំខាន់ទាំងពីរ- វិមជ្ឈការ និងវិសហមជ្ឈការ- គេមិនបានធ្វើសមកាលភាព (ដំណើរក្នុងពេលជាមួយគ្នា) នោះទេ។ អាមួយដែលមានមុនគេ ធ្វើដំណើរបានលឿនជាងអាក្រោយ វាមានន័យថា ការគួសបញ្ជាក់ដែលមានទំហំធំជាងដែលមានសព្វថ្ងៃនេះ ចាំបាច់ត្រូវលើកទៅដាក់ឱ្យនៅពីក្រោយវិញ។ ទោះជាយ៉ាងនេះក្តី សំរាប់ការងារនយោបាយ វាពិតជាមានការលំបាកខ្លាំងណាស់ ដោយសារវាបានបង្កប់ន័យថា ក្របខណ្ឌក្រសួង (ហើយនិងគណបក្សនយោបាយ) នៅក្នុងចំណោមកិច្ចការផ្សេងទៀត នឹងបាត់បង់ការត្រួតត្រាលើការអនុវត្តន៍គំរោងអភិវឌ្ឍន៍ ហើយនឹងកត្តាជាក់ស្តែងដទៃទៀតដែលថា ក្រសួង ក៏ត្រូវបានបែងចែកតាមបែបនយោបាយ រំលងពីលើការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ” (ទីប្រឹក្សា OPM/SPM, 2005: 5)។

ទស្សនៈវិស័យ យុទ្ធសាស្ត្រ និងគោលនយោបាយថ្នាក់ជាតិនេះ ដើម្បីការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ត្រូវតែដាក់បញ្ចូលនូវ :

- *វិធានសម្ព័ន្ធ និងប្រព័ន្ធដែលបានត្រួតពិនិត្យឡើងវិញ* សំរាប់ក្រុមប្រឹក្សាឃុំ សង្កាត់ និងសំរាប់រដ្ឋបាលខេត្ត ក្រុង ស្រុក ខ័ណ្ឌផងដែរ ដើម្បីបង្កលទ្ធភាពអោយគេទាំងអស់ បានជួយជំរុញ និងសម្រួលដល់ទិសដៅនៃកិច្ចអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ។
- *វិធាន និងការទទួលខុសត្រូវច្បាស់លាស់* សំរាប់ថ្នាក់អភិបាលកិច្ចនីមួយៗ និងសំរាប់នាយកដ្ឋាន និងទីភ្នាក់ងាររបស់រដ្ឋាភិបាល ដែលប្រតិបត្តិការនៅថ្នាក់ទាំងនេះ។
- *ការជាប់ទាក់ទងគ្នាទៅវិញទៅមករវាងការទទួលខុសត្រូវ និងធនធាន* រួមទាំង —
    - ✓ តម្រូវការក្នុងការធានាស្ថេរភាពនយោបាយ និងម៉ាក្រូសេដ្ឋកិច្ច
    - ✓ ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ តាមរយៈការងារវិមជ្ឈការសារពើពន្ធ និង
    - ✓ ធនធានមនុស្ស និងស្ថាប័នគ្រប់គ្រាន់។
- *ការងារសម្របសម្រួល និងភាពជាដៃគូកាន់តែធំធេងថែមទៀត* ក្នុងចំណោមស្ថាប័នរបស់រាជរដ្ឋាភិបាល និងរវាងរាជរដ្ឋាភិបាល និងម្ចាស់ជំនួយរបស់ខ្លួន ហើយនិងដៃគូអង្គការមិនមែនរដ្ឋាភិបាល។
- ការផ្តល់ធនធាន និងយន្តការ ដើម្បី *អនុវត្ត និងគ្រប់គ្រងដំណើរការ។*
- *ការចាត់ជាដំណាក់កាលៗ និងក្របខណ្ឌពេលវេលា* សំរាប់ការអនុវត្តន៍ប្រកបដោយការសម្របសម្រួល និងសនិទានភាព នៃលក្ខខណ្ឌតម្រូវទាំងអស់នេះ (ព្រុំ សុខា, ២០០៧: ៤៧-៤៨)។

នៅមុនការអនុម័តច្បាប់រៀបចំអង្គការ មានការផ្លាស់ប្តូរជាច្រើនត្រូវបានគេធ្វើរួចរាល់ហើយ។ ការផ្លាស់ប្តូរដ៏ធំជាងគេមួយ គឺនៅថ្នាក់ជាតិ គឺគណៈកម្មាធិការជាតិដឹកនាំការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ (គ.ជ.វ.វ) ដែលចូលមកកាន់បង្កៀរសេះ និងដឹកនាំការងារសម្របសម្រួល និងគ្រប់គ្រងសំរាប់ការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ជំនួសគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ (គ.ជ.ឃ.ស) និងគណៈកម្មាធិការអន្តរក្រសួងរៀបចំធ្វើសេចក្តីព្រាងច្បាប់រៀបចំអង្គការ (IMC)។ ក្រៅអំពីការងារធ្វើបញ្ចប់ជាចុងក្រោយនៃសេចក្តីព្រាងច្បាប់រៀបចំអង្គការ គ.ជ.

វ.វ ក៏មានការទទួលខុសត្រូវផងដែរសំរាប់ការបង្កើតក្របខ័ណ្ឌអនុវត្ត និងអនុម័តលក្ខខណ្ឌការងារ (TOR) សំរាប់ការបង្កើតកម្មវិធីអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(SNDD) របស់រដ្ឋាភិបាល។

ការផ្លាស់ដ៏សំខាន់មួយផ្សេងទៀត គឺការទទួលស្គាល់របស់ក្រសួងមហាផ្ទៃ ក្នុងការធ្វើការឱ្យនាយក-ដ្ឋានរបស់ខ្លួន មានការឆ្លើយតប និងសម្របទៅនឹងសេចក្តីត្រូវការការងារវិមជ្ឈការ និងវិសហមជ្ឈ-ការកាន់តែច្រើនឡើងថែមទៀត រួមទាំង ការផ្តល់នូវសេវាលេខាធិការដ្ឋានសំរាប់ គ.ជ.វ.វ និង ការទទួលយកមុខងាររបស់លេខាធិការដ្ឋានកម្មវិធីសីលា ដែលកំពុងស្ថិតក្រោមការរំសាយជាបណ្តើរៗនោះ។ ផែនការសកម្មភាពការងារវិមជ្ឈការ និងវិសហមជ្ឈការ/SNDD និងថវិកាដែលបានស្នើឡើងសំរាប់ឆ្នាំ២០០៧ គឺចាំបាច់ណាស់សំរាប់ "កាត់បន្ថយការរំខានអោយនៅកំរិតតិចបំផុត" នៅថ្នាក់ក្រោមជាតិ និងការបន្តនិរន្តរភាពនៃការចាត់ចែងនៅថ្នាក់ក្រោមជាតិនាពេលបច្ចុប្បន្ន ប៉ុន្តែបានចាប់ផ្តើមធ្វើការណែនាំអំពី ការផ្លាស់ប្តូរនេះបានទាន់ពេលវេលាពីថ្នាក់ឃុំ សំរាប់ការបោះឆ្នោតជ្រើស-រើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅខែមេសា ឆ្នាំ២០០៧ (ព្រុំ សុខា, ២០០៧: ២៧)។

សេចក្តីព្រាងច្បាប់បឋម នៃច្បាប់រៀបចំអង្គការ ត្រូវបានសរសេររួចរាល់ហើយ។ សេចក្តីព្រាងច្បាប់នេះចែងចេញជាប្រាំផ្នែក រួមមាន ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការរបស់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ អភិបាល និងប្រធានក្រុមប្រឹក្សា បុគ្គលិកនៃក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាជាតិ និងដំណើរការផ្សេងៗសំរាប់ការអនុវត្តន៍ច្បាប់ ហើយនិងប្រព័ន្ធការបោះឆ្នោតសំរាប់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិទាំងអស់នេះ។ ទោះបីការពិគ្រោះយោបល់ នៅក្នុងក្រសួងមហាផ្ទៃ ក្នុងចំណោមម្ចាស់ជំនួយ ហើយនិងនៅក្នុងពេលធ្វើសន្និបាតថ្នាក់ជាតិរបស់ឃុំ សង្កាត់ ត្រូវបានធ្វើរួចហើយក៏ដោយ សេចក្តីព្រាងច្បាប់រៀបចំអង្គការ នៅមិនទាន់បានដាក់ជាសាធារណៈនៅឡើយ។ មានការចង្អុលបង្ហាញថា ដំបូងត្រូវមានសេចក្តីសំរេចដោះស្រាយបញ្ហាដែលមានវិវាទជាមុនសិន ប្រហែលនៅថ្នាក់ គ.ជ.វ.វ មុននឹងដាក់ជូនច្បាប់រៀបចំអង្គការទៅសភា។ សង្ឃឹមថានឹងមានពេលវេលាគ្រប់គ្រាន់សំរាប់ការពិភាក្សាជាសាធារណៈ នៅចន្លោះពេលនៃការចេញផ្សាយជា-សាធារណៈនៃច្បាប់រៀបចំអង្គការ មុនពេលដាក់ជូនទៅសភា។ ដោយហេតុថា គណបក្សប្រជាជនកម្ពុជា ជាអ្នកត្រួតត្រាសភា វាមិនទំនងក្លាយជាទីកន្លែងសំរាប់ពិភាក្សាបញ្ហាផ្សេងៗនោះទេ។

ច្បាប់រៀបចំអង្គការ ត្រូវបានគេសន្និដ្ឋានថា ជាច្បាប់មួយដែលនឹងផ្តល់ក្របខណ្ឌយ៉ាងទូលំទូលាយ សំរាប់រដ្ឋាភិបាលមូលដ្ឋាន។ "ដើម្បីធានាអោយមានភាពប្រែប្រួលនៃជីវិតរស់នៅរបស់ពលរដ្ឋមូល-ដ្ឋានរបស់ខ្លួនយ៉ាងពិតប្រាកដ ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិត្រូវតែមាន *ឋានៈ មុខងារ អំណាច និងធនធាន* សមស្រប។ ជោគជ័យនៃកំណែទំរង់នេះ អាស្រ័យយ៉ាងសំខាន់ទៅលើ គំនិតយល់ឃើញដែលថា ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិនីមួយៗត្រូវតែមាន រដ្ឋបាលឯកភាពមួយ។ *រដ្ឋបាលឯកភាព* បង្កប់អត្ថន័យថា មិនថាទៅដល់កន្លែងណា និងតាមដែលអាចធ្វើទៅបាន ក្រុមប្រឹក្សានីមួយៗគួរតែមាន និងគួរតែត្រួតត្រាទៅលើផែនការអភិវឌ្ឍន៍ដែលលក្ខណៈទូលំទូលាយ ថវិកា និងបុគ្គលិកផ្ទាល់ខ្លួន សំរាប់គ្រប់កិច្ចការទាំងអស់ ដែលស្ថិតនៅក្រោមសិទ្ធិនៃដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ។ ដូច្នេះ ក្រុមប្រឹក្សាណាដែលមានរដ្ឋបាលឯកភាព ត្រូវត្រួតត្រាទៅលើសំភារៈឧបករណ៍ចាំបាច់ ដើម្បីឆ្លើយតបទៅនឹងតម្រូវពិតប្រាកដរបស់ពលរដ្ឋមូលដ្ឋានរបស់ខ្លួន។ ការចាត់ចែងការងាររដ្ឋបាលបែបនេះ ត្រូវដាក់បញ្ចូលលក្ខខណ្ឌតម្រូវធម្មតាដែលមានលក្ខណៈចាប់បង្ខំ និងបទដ្ឋានមួយចំនួន សំរាប់ការគ្រប់គ្រងការងារហិរញ្ញវត្ថុអោយបានត្រឹមត្រូវ និងសវនកម្ម និងការតាមដាន និងការវាយតម្លៃលើការបំពេញភារកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ។ យន្តការនានាសំរាប់ការចូលរួមរបស់ប្រជាពលរដ្ឋតម្លាភាព ការឆ្លើយតប និងគណនេយ្យភាពនៅលើគ្រប់ទស្សនៈទាំងអស់របស់អភិបាលកិច្ចមូលដ្ឋាន គឺជាមូលដ្ឋាននៃប្រព័ន្ធ និងគំនិតយល់ដឹងទាំងមូលនៃកិច្ចការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ និងការងាររដ្ឋបាលឯកភាព"។ (ព្រុំ សុខា, វគ្គ ៧, ទំព័រ ២)។

ការផ្លាស់ប្តូរដ៏ទូលំទូលាយគិតគូរទៅលើច្បាប់រៀបចំអង្គការ តម្រូវអោយមានការចាត់ដំណាក់កាលដោយប្រុងប្រយ័ត្ន។ "គោលការណ៍នៃនាំ និងលក្ខខណ្ឌតម្រូវជាមូលដ្ឋាន គឺមានន័យថា ការផ្ទេរទៅអោយក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិនៃការទទួលខុសត្រូវ និងមុខងាររបស់រដ្ឋាភិបាល ជាមួយនឹងធនធានសមស្រប ត្រូវធ្វើឡើងតាមដំណាក់សមរម្យ ដើម្បីធានាបានការងារអន្តរកាលមួយ ប្រកបដោយភាពរលូន។ ការផ្ទេរត្រូវធ្វើឡើងតាមរបៀបមួយដោយមានផែនការច្បាស់លាស់ ជាដំណាក់-កាលៗ សនិទានភាព មានការសម្របសម្រួល ពិគ្រោះយោបល់ និងដោយតម្លាភាព។ មួយវិញទៀតត្រូវធ្វើយ៉ាងណាកាត់បន្ថយអោយបានតិចបំផុតនូវការរំខានផ្សេងៗទៅលើប្រតិបត្តិការរបស់រដ្ឋាភិ-បាលដែលកំពុងដំណើរ រួមទាំង ការឧបត្ថមមូលនិធិ កិច្ចគាំទ្រ និងការចូលរួមនៃភ្នាក់ងារអន្តរជាតិម្ចាស់ជំនួយនិងអង្គការមិនមែនរដ្ឋាភិបាល"។ (ព្រុំ សុខា, វគ្គ ៧, ទំព័រ ២-៣)។ អ្វីដែលមានលក្ខណៈ

ត្រឹមត្រូវខាងផ្នែកនយោបាយ ដែលនៅក្នុងបទបង្ហាញរបស់លោក ព្រុំ សុខា មិនបានចង្អុលបង្ហាញផងទេ នោះគឺការចចារដ៏ខ្លាំងក្លាស្តីពីការផ្ទេរមុខងារ និងអំណាចដែលនឹងត្រូវប្រើប្រាស់ពេលវេលាដ៏ច្រើន។ ការពិចារណាមួយផ្សេងទៀត គឺការត្រួតត្រាដោយគណបក្សប្រជាជនកម្ពុជា ដំណើរការកាន់តែវែងឆ្ងាយ ការត្រួតត្រាកាន់តែងាយស្រួល។ សេចក្តីសំរេចចិត្តដើម្បីបង្កើតក្រុមប្រឹក្សានៅមូលដ្ឋានតាមការបោះឆ្នោតដោយអសកល គឺច្បាស់ណាស់ថា ជាសេចក្តីសំរេចមួយដែលធ្វើឡើងដោយលោកនាយករដ្ឋមន្ត្រីខ្លួនគាត់ផ្ទាល់។

កិច្ចការអន្តរកាលមួយផ្សេងទៀតដែលចាំបាច់ត្រូវគ្រប់គ្រងដោយប្រុងប្រយ័ត្នផងដែរនោះ គឺចលនាងាកចេញពីតួនាទីរបស់ម្ចាស់ជំនួយ នៅក្នុងគំរោងប្លង់វិមជ្ឈការ។ ការនេះគឺជាដំណើរការរំសើបជាពិសេសមួយ ដោយសារថា រាជរដ្ឋាភិបាលកម្ពុជាពឹងផ្អែកទៅលើធនធានរបស់ម្ចាស់ជំនួយ។ ដើម្បីត្រៀមរៀបចំការងារអន្តរកាលអោយងាកចេញពីកម្មវិធីសីលា រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍបានព្រមព្រៀងទៅលើគោលការណ៍ណែនាំមួយចំនួន កាលពីខែមិថុនា ឆ្នាំ២០០៦ ដូចខាងក្រោមៈ

- ការអភិវឌ្ឍន៍ផែនការរបស់ផ្នែកផ្សេងៗ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៅក្រោមក្របខណ្ឌនៃផែនការ NSDP ឆ្នាំ ២០០៦ - ២០១០
- គោរពភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំនៃដំណើរការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលកម្ពុជា
- ការធ្វើអោយស្របគ្នានៃយុទ្ធសាស្រ្តរបស់ប្រទេសម្ចាស់ជំនួយ ជាមួយការងារអាទិភាពរបស់ NSDP
- ធ្វើអោយមានការកើនឡើងនូវការប្រើប្រាស់ស្ថាប័ន ប្រព័ន្ធ និងនីតិវិធីរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានធ្វើការពង្រឹងរួចមកហើយ
- បង្កើនសមាមាត្រនៃកិច្ចសហការអភិវឌ្ឍន៍ តាមរយៈកម្មវិធីតាមផ្នែក/កម្មវិធីតាមប្រធានបទ និង យុទ្ធសាស្រ្តនានាដែលមានមូលដ្ឋានជាកម្មវិធី។ *(សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍ ស្តីពី ការបង្កើនប្រសិទ្ធិភាពនៃជំនួយ* (មិនា ២០០៦)។ ការសិក្សាឯករាជ, ២០០៦: ១០)។

ការសិក្សាឯករាជត្រូវបានធ្វើឡើងដើម្បីលើកស្នើនូវជំរើសផ្សេងៗ សំរាប់របៀបរបបថ្មី សំរាប់ជំនួយ

ផ្សេងៗរបស់ម្ចាស់ជំនួយ ទៅលើការងារវិមជ្ឈការ និងវិសហមជ្ឈការ។ ការសិក្សានេះត្រូវបានធ្វើបទបង្ហាញដោយឯកឧត្តមសរ ខេង ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅក្នុងសម័យប្រជុំមួយជាមួយម្ចាស់ជំនួយ កាលពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៦។ នៅក្រោមជំរើសមួយចំនួនដែលបានជ្រើសរើសដោយរាជរដ្ឋាភិបាលកម្ពុជាៈ

- ម្ចាស់ជំនួយ គួរតែមានលទ្ធភាពបញ្ជូនមូលនិធិទៅក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ តាមរយៈអាជ្ញាធរអនុវត្ត ឬកម្មវិធីតាមវិស័យរបស់ក្រសួងនានា។
- ម្ចាស់ជំនួយ គួរតែមានលទ្ធភាពផ្តល់ការគាំទ្រដល់ថ្នាក់ជាតិ ទាំងអាជ្ញាធរអនុវត្ត និងក្រសួងសាម៉ី។
- ដើម្បីធានាបាននូវភាពស្របគ្នារបស់ម្ចាស់ជំនួយ ទៅនឹងច្បាប់រៀបចំអង្គការ និងក្របខ័ណ្ឌអនុវត្ត ម្ចាស់ជំនួយទាំងអស់នឹងតម្រូវអោយចូលរួមជាភាគីនៅក្នុង "កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល និងម្ចាស់ជំនួយ ស្តីពីកិច្ចគាំទ្រការងារវិមជ្ឈការ និងវិសហមជ្ឈការ"។ ថាតើពួកគេត្រូវផ្តល់កិច្ចគាំទ្រទៅអាជ្ញាធរអនុវត្ត ឬ ក្រសួងសាម៉ី។
- មូលនិធិវិមជ្ឈការ និងវិសហមជ្ឈការ អាចបង្កើតបានជាការទាក់ទាញនូវធនធានរបស់ម្ចាស់ជំនួយ (ដូចជា កញ្ចប់ព្រៀងត្រងយកមូលនិធិ មួយ) សំរាប់ឧបត្ថមមូលនិធិដល់ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិ។
- មូលនិធិវិមជ្ឈការ និងវិសហមជ្ឈការ អាចប្រើប្រាស់ផងដែរដើម្បីទាក់ទាញកិច្ចគាំទ្ររបស់ម្ចាស់ជំនួយនៅថ្នាក់ជាតិ។ (ឯកឧត្តម សរ ខេង, ២០០៦: ៧)។

នៅក្នុងកិច្ចប្រជុំពិគ្រោះយោបល់រវាងរដ្ឋាភិបាល និងម្ចាស់ជំនួយ ដែលបានធ្វើឡើងកាលពីថ្ងៃទី២ ខែមិនា ឆ្នាំ២០០៦ ឯកឧត្តម សរ ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានធ្វើការលាតត្រដាងអំពីផ្នែកសំខាន់ៗ និងក្របខ័ណ្ឌពេលវេលា សំរាប់ការអនុវត្តន៍ការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ។ ក្របខ័ណ្ឌអនុវត្តផ្តល់នូវដំណាក់កាលចំនួន៤យ៉ាងពិស្តារ នៃយុទ្ធសាស្ត្រអនុវត្តសំរាប់ច្បាប់រៀបចំអង្គការ ដែលបានធ្វើការអភិវឌ្ឍន៍ និងត្រួតពិនិត្យដោយ គ.ជ.វ.វ។ ប្រខ័ណ្ឌនេះបានកំណត់អត្តសញ្ញាណសំរាប់ផ្នែកសំខាន់ៗ ការងារអាទិភាព និងលំដាប់លំដោយនៃសកម្មភាពសំរាប់ការធ្វើកំណែទំរង់ និងអនុវត្តច្បាប់រៀបចំអង្គការ និងគោលនយោបាយដទៃទៀតដែលជាប់-ពាក់ព័ន្ធ។ ក្របខ័ណ្ឌផ្តល់ផងដែរនូវគោលការណ៍ជាបឋម ជមរើស និងក្របខ័ណ្ឌពេលវេលាសំរាប់

ក្រសួង ទីភ្នាក់ងារអន្តរជាតិ និងម្ចាស់ជំនួយ ដើម្បីអភិវឌ្ឍកម្មវិធីរយៈពេលខ្លី មធ្យម និងរយៈពេលវែងដែលមានលក្ខណៈបត់បែន និងដែលស្របទៅនឹងគោលនយោបាយ ហើយនិងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល។

| ២០០៦ | ២០០៧ — ២០០៩ | ២០១០ - ២០១២ | -២០១៣ |
| --- | --- | --- | --- |
| *ដំណាក់កាលត្រៀមរៀបចំ* | *ដំណាក់កាលចាប់ផ្តើមដំបូង* | *ដំណាក់កាលអន្តរកាល* | *ដំណាក់កាលផ្លាស់ប្តូរ* |
| • ការពិគ្រោះយោបល់ទៅលើសេចក្តីព្រាងច្បាប់រៀបចំអង្គការ<br>• ការអនុម័តច្បាប់រៀបចំអង្គការ<br>• ការបង្កើតយុទ្ធសាស្ត្រអនុវត្ត<br>• ការបង្កើតអាជ្ញាធរអនុវត្ត<br>• យុទ្ធនាការផ្សព្វផ្សាយព័ត៌មាន<br>• ការបង្កើតរបៀបរបបសំរាប់ម្ចាស់ជំនួយគាំទ្រដំណាក់កាលចាប់ផ្តើមដំបូង<br>• ការសន្យាជំនួយពីខាងក្រៅ | • ការបោះឆ្នោតឃុំ ២០០៧<br>• ការបង្កើតរចនាសម្ព័ន្ធ/ប្រព័ន្ធនៅថ្នាក់ក្រោមជាតិ ដែលបានកែតម្រូវ<br>• ការបង្កើត អាជ្ញាធរអនុវត្ត<br>  • ការបង្កើតដំណើរការគ្រប់គ្រងគោលនយោបាយ<br>  • ការបង្កើតគំរូឧបករណ៍/សំភារៈមធ្យោបាយសំរួលរវាងរដ្ឋាភិបាល/ម្ចាស់ជំនួយ<br>  • ការបោះឆ្នោតដោយអសកលនៃក្រុមប្រឹក្សាខេត្ត និងក្រុមប្រឹក្សាស្រុក (២០០៨/២០០៩)<br>  • ការចាត់តាំងមុខងារ ការផ្លាស់ប្តូររចនាសម្ព័ន្ធ ការផ្ទេរធនធាន<br>  • ការចាត់ចែងសារពើពន្ធអន្តរ-រដ្ឋាភិបាល<br>  • ការកសាងសមត្ថភាព (ថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ)<br>  • ការត្រួតពិនិត្យ/ធ្វើឡើងវិញនៃរបៀបរបបសំរាប់ម្ចាស់ជំនួយ | • និរន្តរភាពនៃដំណើរការកំណែទំរង់ (ជាពិសេសនៅក្នុងផ្នែកអាទិភាពដាក់បន្ថែមថ្មី<br>• ការកសាងសមត្ថភាព (ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ<br>• ត្រួតពិនិត្យក្របខ័ណ្ឌសារពើពន្ធតាមបែបវិមជ្ឈការ<br>• ត្រួតពិនិត្យផលប៉ះពាល់មកពីការផ្លាស់ប្តូរនៅក្នុងវិស័យដាក់បន្ថែមថ្មី<br>• ការបោះឆ្នោតឃុំឆ្នាំ២០១២<br>• ការត្រួតពិនិត្យ/បង្កើតឡើងវិញនៃរបៀបរបបសំរាប់ម្ចាស់ជំនួយ | • ការបង្រួបបង្រួមកំណែទំរង់<br>• ការកែតម្រូវឡើងវិញនៃប្រព័ន្ធនិងរចនាសម្ព័ន្ធ<br>• ការបោះឆ្នោតក្រុមប្រឹក្សា ស្រុក និងខេត្ត |

សេចក្តីព្រាងច្បាប់សន្មត់ថា ការកសាង និងការបង្កើតឡើងវិញនេះ គឺជាការងារដ៏ធំធេង និងសាំ-ញ៉ាំមួយ ហើយថា នឹងដំណើរការទៅតាមដំណាក់កាល១ ព្រមទាំងអនុវត្តបន្តិចម្តង១ពេញមួយទសវត្សរ៍បន្ទាប់ ឬក៏ វែងជានេះ។ (ព្រុំ សុខា ២៨)។ ខណៈដែលប្រសាសន៍នេះគ្មានអ្វីត្រូវឆ្ងល់ និងពិតជាត្រឹមត្រូវមែន នោះអ្វីដែលជាសារសំខាន់ដែលត្រូវចង្អុលបង្ហាញគឺថា ការនេះគឺជា "ដំណើរការបែបនយោបាយ" ជាបន្ទាន់បំផុត។ "ក្នុងការអនុវត្តន៍ដំណើរការកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ផ្នែកដ៏សំខាន់ទាំងពីរ — វិមជ្ឈការ និងវិសហមជ្ឈការ — នៅមិនទាន់បានធ្វើសមកាលភាពនៅឡើយ។ អាមួយដែលមានមុនគេ ធ្វើដំណើរបានលឿនជាងអាក្រោយ វាមានន័យថា ការគូសបញ្ជាក់ដែលមានទំហំធំជាងដែលមានសព្វថ្ងៃនេះ ចាំបាច់ត្រូវលើកទៅដាក់អោយនៅពីក្រោយវិញ។ ទោះជាយ៉ាងនេះក្តី សំរាប់ការងារនយោបាយ វាពិតជាមានការលំបាកខ្លាំងណាស់ ដោយសារវាបានបង្កប់ន័យថា ក្របខណ្ឌក្រសួង (ហើយនិងគណបក្សនយោបាយ) នៅក្នុងចំណោមកិច្ចការផ្សេងទៀត នឹងបាត់បង់ការត្រួតត្រាលើការអនុវត្តន៍គំរោងអភិវឌ្ឍន៍ ហើយនឹងកត្តាជាក់ស្តែងដទៃទៀតដែលថា ក្រសួង ក៏ត្រូវបានបែងចែកតាមបែបនយោបាយ រំលងពីលើការងារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ" (ទីប្រឹក្សា OPM/SPM, 2005: 5)។

សេចក្តីព្រាងច្បាប់រៀបចំអង្គការ មានដំណើរស្វាហាប់ជាងឯកសារជាយុទ្ធសាស្ត្រនៃការងារវិមជ្ឈ-ការ និងវិសហមជ្ឈការទៅទៀត។ ទោះបីជាការជាក់ស្តែងដែលថា "សាច់" នៃ "វិសហមជ្ឈការ"-ការប្រគល់អោយនូវមុខងារទៅ SNAs កំពុងស្ថិតក្រោមការតថ្លៃគ្នានៅឡើយក៏ដោយ សេចក្តីព្រាងច្បាប់រៀបចំអង្គការបានដោះស្រាយបញ្ហារចនាសម្ព័ន្ធរួចហើយ។ ខេត្ត និងស្រុក នឹងត្រូវបញ្ចប់ធ្វើជា ប៉ូស្តិ៍ជួរមុខ របស់ក្រសួងមហាផ្ទៃ ព្រោះថាខេត្ត និងស្រុកនឹងមានក្រុមប្រឹក្សា និងផ្នែកប្រតិបត្តិតាមការបោះឆ្នោត (ជាអសកល)។ ការទំនាក់ទំនងតាមខ្សែបណ្តោញ ក៏ត្រូវបានដោះស្រាយផងដែរ ឧ. អ្នកណាជាអ្នកបោះឆ្នោតជ្រើសរើសអភិបាល ហើយនិងការជ្រើសរើសការបោះឆ្នោត ប៉ុន្តែត្រង់ចំណុចនេះ សេចក្តីព្រាងច្បាប់នៅមិនទាន់បានបញ្ចប់នៅឡើយនៅចុងឆ្នាំ២០០៦។ ការជ្រើសការបោះឆ្នោតដែលមាននៅក្នុងច្បាប់រៀបចំអង្គការ ប្រហែលជាត្រូវបង្កើតរូបមន្តឡើងវិញនៅក្នុងច្បាប់ស្តីពីការបោះឆ្នោតឃុំ ដែលគេសន្និដ្ឋានថា នឹងមានគណបក្សនយោបាយផ្សេង១ចូលរួម និងធានាចំពោះមុខតំណែងខ្លះសំរាប់គណបក្សប្រឆាំង ប៉ុន្តែតាមការអនុវត្តន៍ជាក់ស្តែង នឹងពង្រឹងដល់

គណបក្សប្រជាជនកម្ពុជាបន្ថែមទៀត។ ការតថ្លៃគ្នានឹងមានកាន់តែខ្លាំងនៅមុខការដាក់ជូនច្បាប់នេះ នៅក្នុងដំណើរការរបស់ គ.ជ.វ.វ ទាំងនៅក្នុងកិច្ចប្រជុំផ្លូវការ និងក្រៅផ្លូវការ សំខាន់ជាងនេះទៅទៀត គឺនៅក្នុងគណបក្ស CPP តែម្តង។ ទោះបីគេបានដាក់កាលបរិច្ឆេទសំរាប់ការដាក់ជូនទៅសភានៅត្រីមាសទីបួននៃឆ្នាំ២០០៦ ក៏ដោយ ក៏ច្បាប់រៀបចំអង្គការនៅមិនទាន់បានដាក់ជូនសភានៅឡើយ នៅដើមឆ្នាំ២០០៧នេះ។ ដោយសារ CPP ត្រួតត្រាសភានៅក្នុងឆ្នាំ២០០៦ សេចក្តីព្រាងច្បាប់រៀបចំអង្គការចុងក្រោយគួរតែបានអនុម័តដោយសភា ដោយគ្មានបញ្ហាច្រើននោះទេ។

## បញ្ហាបង្កើតស្ថាប័ន

ការលាតត្រដាងបង្ហាញនូវការងារវិមជ្ឈការរបស់កម្ពុជា មានភាពខុសគ្នារវាង "ការងារវិសហមជ្ឈការ ដែលមុខងារ និងអំណាចបាននឹងកំពុងប្រគល់ទៅអោយអង្គភាពនៅមូលដ្ឋាន ចំណែក"ការងារវិមជ្ឈការ" ការប្រគល់ជូននូវមុខងារ និងអំណាច ទៅអោយអង្គភាពរដ្ឋាភិបាលមូលដ្ឋានដែលជាប់ឆ្នោត។ ឯកសាររបស់រាជរដ្ឋាភិបាលកម្ពុជានិយាយថា គោលបំណងគឺដើម្បី "ធ្វើវិមជ្ឈការ"នៅថ្នាក់ខេត្ត និងថ្នាក់ស្រុក តាមរយៈការបង្កើតប្រភេទនៃអង្គភាពជាតំណាង តាមរយៈការបោះឆ្នោត និងដើម្បី "ធ្វើវិសហមជ្ឈការ" នូវមុខងារ និងអំណាចច្រើនទៀត ទៅអោយក្រុមប្រឹក្សាឃុំ សង្កាត់ជាប់ឆ្នោត។ ភាពខុសគ្នាក៏ត្រូវបានគេធ្វើឡើងផងដែររវាង "ការអភិវឌ្ឍន៍ផ្នែករដ្ឋបាល" និង "ការអភិវឌ្ឍន៍ផ្នែកនយោបាយ"។ *ការអភិវឌ្ឍន៍ផ្នែករដ្ឋបាល* ពាក់ព័ន្ធនឹងការផ្តល់សេវា សំភារៈជួយសំរួលការរស់នៅ និងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗជាសារវ័ន្តនិងពិតប្រាកដ តាមការត្រួតត្រាបែបអភិបាលកិច្ច។ *ការអភិវឌ្ឍន៍ផ្នែកនយោបាយ* តម្រូវអោយបង្កើតក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិស្វយ័ត្ត ប៉ុន្តែគ្មានអំណាចត្រួតត្រា ដែលជាប់ឆ្នោតតាមរយៈការបោះឆ្នោតជាសកល និងអសកល។ ការអភិវឌ្ឍន៍ផ្នែកនយោបាយ ក៏ពាក់ព័ន្ធផងដែរទៅនឹងការជួយសម្រួលដល់ការចូលរួមរបស់ប្រជាពលរដ្ឋ នៅក្នុងការងារអភិបាលកិច្ច រាប់បញ្ចូលទាំងយន្តការសមស្របសំរាប់ការចូលរួមរបស់ប្រជាជន ក្នុងការបង្កើតជំរើសផ្សេងៗទាក់ទិននឹងសេវា សំភារៈសំរួលការរស់នៅ និងហេដ្ឋារចនាសម្ព័ន្ធណាមួយដែលរួមចំណែកបានយ៉ាងល្អបំផុតដល់ការលើកកំពស់គុណភាពជីវិតរបស់ខ្លួន។ ជាការសំខាន់មិនអាចខ្វះបាន ដើម្បីលើកសរសើរថា កិច្ចអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យអាចនឹងសំរេចបាន និងមានចីរភាពទៅបាន វៀរលែងតែ ការអភិវឌ្ឍន៍ផ្នែកនយោបាយដែលមានលក្ខណៈគ្រប់គ្រាន់នោះ ត្រូវបានគេ

ប្រើប្រាស់ដើម្បីបង្កើនគំនិតសុទិដ្ឋិនិយម និងដើម្បីផ្តល់អោយមាន *ការអភិវឌ្ឍន៍ផ្នែករដ្ឋបាល* ដែលសមស្រប។ ហេតុដូច្នេះ ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ វាមិនសាមញ្ញដោយគ្រាន់តែមានពាក់ព័ន្ធការចាត់ចែងផ្នែករចនាសម្ព័ន្ធ និងប្រព័ន្ធរដ្ឋបាលប៉ុណ្ណោះទេ។ ការអភិវឌ្ឍន៍ផ្នែកនយោបាយ ហើយនិងការអភិវឌ្ឍន៍ផ្នែករដ្ឋបាលដ៏សមស្រប ត្រូវតែដាក់បញ្ចូលគ្នាដើម្បីសំរេចបានការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ" (ឯកឧត្តម ព្រុំ សុខា, ២០០៧: ៦)។

នៅត្រង់ចំណុចនេះទាក់ទិនដំណើរការវិមជ្ឈការ បញ្ហាបង្កើតស្ថាប័នដ៏មានសារសំខាន់បំផុតនោះគឺត្រូវធ្វើជាមួយនឹងអ្វីដែលត្រូវធ្វើជាមួយខេត្ត និងស្រុក។ បញ្ហាដ៏ធំជាងគេបំផុតមួយនៅក្នុងការងារវិមជ្ឈការរបស់កម្ពុជា គឺថា ថ្នាក់មធ្យមនៅចន្លោះក្រុមប្រឹក្សាឃុំ និងរដ្ឋាភិបាលថ្នាក់កណ្តាល សំរាប់ការតាំងចិត្ត និងគោលបំណងទាំងអស់មិនទាន់កើតមានឡើយ។ មានខេត្ត និងស្រុក ប៉ុន្តែខេត្ត និងស្រុកទាំងនោះគ្មានមុខងារ និងអំណាចដាច់ស្រឡះដែលប្រគល់ជូនដោយរដ្ឋាភិបាលថ្នាក់កណ្តាល ហើយក៏មិនមែនជាស្ថាប័នផ្តល់អាណត្តិការងារតាមការបោះឆ្នោតរបស់ប្រជាពលរដ្ឋនោះដែរ។ ការនេះបង្កើតជាបញ្ហាសំរាប់ឃុំ ពីព្រោះថា គោលនយោបាយ និងសេចក្តីណែនាំផ្សេងៗរបស់រដ្ឋាភិ-បាលថ្នាក់កណ្តាលត្រូវធ្វើដំណើរមកក្រោមយ៉ាងស្រួលនោះ ចម្ងាយផ្លូវរដ្ឋបាល និងនយោបាយពីឃុំឡើងទៅលើ មិនត្រូវបានជួយសម្រុះសម្រួលដោយរដ្ឋាភិបាលថ្នាក់មធ្យមនោះទេ។

បើទោះបីជាបទប្បញ្ញត្តិផ្សេងៗពាក់ព័ន្ធខេត្ត និងស្រុក ដែលមានចែងនៅក្នុងច្បាប់រៀបចំអង្គការនៅកំពុងធ្វើការតថ្លៃគ្នានៅឡើយ ឯកសារយុទ្ធសាស្ត្រស្តីពី ការងារវិមជ្ឈការ និងវិសហមជ្ឈការ បានដាក់បង្ហាញបញ្ហាមួយចំនួនដែលត្រូវដោះស្រាយ។ "នៅខេត្ត ក្រុង ប្រព័ន្ធរដ្ឋាភិបាលនៅរក្សាតាមបែបមជ្ឈការនៅឡើយ ដោយមានក្រសួង/នាយកដ្ឋានរបស់ក្រសួងអនុវត្តគោលនយោបាយ និងផែនការរបស់ថ្នាក់ជាតិ។ ផែនការអភិវឌ្ឍន៍ ថវិកា និងប្រព័ន្ធគ្រប់គ្រងបុគ្គលិកខេត្ត/ក្រុងដែលប្រទាក់គ្នាទៅវិញទៅមក នៅមិនទាន់មាននៅឡើយ។ បច្ចុប្បន្ននេះ អភិបាលខេត្ត/ក្រុង ដែលជាតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជា មានការទទួលខុសត្រូវក្នុងការថែរក្សាសន្តិសុខ និងរបៀបរៀបរយសាធារណៈ ហើយនិងធានាអំពីនីត្យានុភាពការងារ ដែលអនុវត្តដោយឃុំ។ ជាការបន្ថែម អភិបាលខេត្ត/ក្រុងមានការទទួលខុសត្រូវក្នុងការជំរុញ និងណែនាំការងាររបស់នាយកដ្ឋានបច្ចេកទេសផ្សេងៗគ្នានៅជុំវិញខេត្ត ស្របទៅតាមគោលនយោបាយរបស់រដ្ឋាភិបាល។ ទោះជាយ៉ាងណាក៏ដោយ នៅពេលបច្ចុប្បន្ន

នេះ កម្មវិធីអភិវឌ្ឍន៍ច្រើនបំផុតរបស់ផ្នែកនីមួយៗត្រូវបានធ្វើផែនការ និងគ្រប់គ្រងដោយថ្នាក់កណ្ដាល ហើយខ្សែគណនេយ្យភាពរបស់នាយកដ្ឋានតាមខេត្ត ដែលជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តន៍ នៅតែស្ថិតក្រោមក្រសួងខ្សែបណ្ដាញរបស់ខ្លួននៅឡើយ។ មុខងារ និងរចនាសម្ព័ន្ធជាន់គ្នារវាងនាយកដ្ឋាន/ការិយាល័យរបស់ក្រសួងខ្សែបណ្ដាញទាំងនោះ បានបន្ថែមទៅលើបញ្ហានៃការសម្របសម្រួលនៅថ្នាក់ខេត្ត និងថ្នាក់ស្រុក។ ដោយសារអវត្តមានក្របខ័ណ្ឌច្បាប់ដែលជាអ្នកបង្កើតអោយមានប្រព័ន្ធសមាហរណកម្មរដ្ឋបាលដែនដីដ៏ពិតប្រាកដមួយ បានធ្វើអោយអាណត្តិការងាររបស់អភិបាលខេត្ត/ក្រុងក្នុងការធ្វើផែនការ ក៏ដូចការសម្របសម្រួលកិច្ចការអភិវឌ្ឍន៍នៅមូលដ្ឋានមិនអាចអនុវត្តបានពេញលេញ នៅពេលបច្ចុប្បន្ននេះបានឡើយ”។ (RGC, ក្របខ័ណ្ឌយុទ្ធសាស្ត្រ, ២០០៦:២)

**ខេត្ត** គឺជាយន្តការគាំទ្រដ៏មានសារសំខាន់សំរាប់ការងារវិមជ្ឈការ។ ទោះជាយ៉ាងនេះក្ដី រចនាសម្ព័ន្ធគ្រប់គ្រងនៃការិយាល័យរបស់អភិបាលខេត្តដែលមានសព្វថ្ងៃ គឺមានលក្ខណៈវិសមិតភាពជាមួយនឹងតួនាទី និងការទទួលខុសត្រូវថ្មីរបស់អភិបាល ដោយសារហេតុផលសំខាន់ដូចខាងក្រោមនេះ :

- អភិបាល មានការទទួលខុសត្រូវគ្រប់គ្រងខាងផ្លូវច្បាប់នៃការងាររដ្ឋបាល និងការតាមដានលើកិច្ចការហិរញ្ញវត្ថុជាទូទៅ រួមទាំង ការអនុម័តថវិការបស់ផ្នែកនីមួយៗ ប៉ុន្តែគ្មានអំណាចផ្លាស់ប្តូរវាទេ។ ការគ្រប់គ្រងលំអិតរបស់ក្រសួងតាមខ្សែបណ្ដាញ និងសេវាកម្មវិសហមជ្ឈការ មិនត្រូវបានគេកំណត់ច្បាស់លាស់ទេ នៅក្នុងអាណត្តិរបស់អភិបាលបច្ចុប្បន្ន។
- កង្វះធនធានសំរាប់សកម្មភាពប្រតិបត្តិការ ជាញឹកញាប់បង្កើតអោយមាន ក.ដប (ការចង្អៀតចង្អល់) ការបំពេញភារៈកិច្ចមិនបានល្អ និងកង្វះខាតព័ត៌មាន។
- គ្មានការត្រួតពិនិត្យ និងតុល្យការនឹងគ្នាច្បាស់លាស់សំរាប់ការងារអភិបាលកិច្ចថ្នាក់ខេត្តទេ។ តួនាទី និងកិច្ចការដែលបានប្រគល់អោយខេត្ត ពុំមានការគាំទ្រដោយប្រភពហិរញ្ញវត្ថុនោះឡើយ។ រដ្ឋបាលខេត្ត មានកង្វះខាតធនធានមនុស្ស។
- សេវាកម្មត្រូវបានគេចាត់ចែងនៅក្រោមប្រព័ន្ធតាមឋានានុក្រម និងដាច់ដោយឡែកពីគ្នាណែនាំដោយទិសដៅតាមផ្នែកនៃក្រសួងនីមួយៗ។ កិច្ចការសន្តិខុស គោលនយោបាយ និងការចុះឈ្មោះ/ចុះបញ្ជីផ្សេងៗ សឹងតែជាប់ទាក់ទិនយ៉ាងជិតស្និតជាមួយនឹងខេត្ត និងសកម្ម-ភាពអភិវឌ្ឍន៍ថ្នាក់ក្រោមជាងនេះ នៅក្នុងការងាររដ្ឋបាល និងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុមួយដែលប្រេះស្រាំ នៅថ្នាក់ខេត្ត។

- ការធ្វើទំនាក់ទំនងមិនច្បាស់លាស់ រវាងអភិបាល និងនាយកដ្ឋានបច្ចេកទេស និងរវាងអភិ-បាល និងរដ្ឋាភិបាលថ្នាក់កណ្តាល។

ជាការសន្និដ្ឋាន ខេត្តបច្ចុប្បន្ននេះ មានកង្វះខាតផ្នែកឧបករណ៍គ្រប់គ្រង ដើម្បីយកមកប្រើប្រាស់លើការងាររដ្ឋបាល និងផែនការហិរញ្ញវត្ថុអោយបានទូលំទូលាយ និងត្រួតមើលការគ្រប់គ្រង។ ការងាររដ្ឋបាលមានលក្ខណៈជាវិមជ្ឈការ និងមានចរិតលក្ខណៈទៅតាមរចនាសម្ព័ន្ធគ្រប់គ្រងខុស១ពីគ្នា។ ដែលការនេះ នាំទៅដល់កង្វះខាតគណនេយ្យភាព និងតម្លាភាព ដែលជាកត្តាចំបាច់សំរាប់ការងារអភិបាលកិច្ច ដែលបានផ្តល់អាទិភាពខ្ពស់បំផុតនៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាល”។ (NCSC, 2005: 23)។

នៅក្នុងឯកសារយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ ការងារវិមជ្ឈការទៅថ្នាក់ខេត្ត ប្រហែលជា គំនិតផ្តួចផ្តើមថ្មីមួយដ៏សំខាន់បំផុត។ “ក្រុមប្រឹក្សាខេត្តដែលជាប់ឆ្នោតតាមការបោះឆ្នោតដោយអសកល ត្រូវតែបង្កើតអោយបាន។ ចំនួនអាសនៈនៅក្នុងក្រុមប្រឹក្សាខេត្ត ត្រូវតែកំណត់តាមមូល-ដ្ឋានភូមិសាស្ត្រ និងប្រជាសាស្ត្រ ..។ ក្រុមប្រឹក្សាខេត្ត ត្រូវពិនិត្យ និងអនុម័តផែនការ និងថវិការបស់អភិបាល ដែលបានដាក់ជូនមកខ្លួនដោយអភិបាល និងត្រូវពិនិត្យ និងវាយតម្លៃសកម្មភាពរបស់អភិបាល និងកិច្ចការរដ្ឋបាលរបស់ខេត្ត និងប្រសិនបើចាំបាច់ ត្រូវស្វែងរកការបំភ្លឺពាក់ព័ន្ធសេចក្តីសំ-រេចផ្នែករដ្ឋបាលរបស់អភិបាល។ ក្រុមប្រឹក្សា ត្រូវមានសិទ្ធិស៊ើបអង្កេតលើបញ្ហាណាមួយដែលមានសារសំខាន់ចំពោះប្រជាពលរដ្ឋដែលខ្លួនធ្វើជាតំណាងអោយ បោះផ្សាយការរកឃើញរបស់ខ្លួន និងលើកអនុសាសន៍ ព្រមទាំងដាក់សំណើរទៅអភិបាល”។ (RGC, ក្របខ័ណ្ឌយុទ្ធសាស្ត្រ, ២០០៦:៨)។

នៅទីត្រង់ចំណុចនេះ ការពិចារណាស្រដៀងគ្នានេះដែលមានលក្ខណៈជា “កលយុទ្ធ” នៅក្នុង “យុទ្ធសាស្ត្រ” អាចអោយគេអង្កេតបានផងដែរ។ តាមការបង្កើតបែបនេះ ក្រុមប្រឹក្សាខេត្តមិនមានអំណាចច្រើនពេកទេ។ បញ្ហាដែលអាក្រក់បំផុតគឺថា ដោយសារអភិបាលតែងតាំងដោយអាជ្ញាធរដែលខ្ពស់ជាង ដោយសារថវិការបស់គាត់ចេញពីរដ្ឋាភិបាលថ្នាក់កណ្តាល និងដោយសារសិទ្ធិអំណាចរបស់គាត់ជា “ក្រុមប្រឹក្សាជាប់ឆ្នោតដោយអសកល” ដែលមានលក្ខណៈទន់ខ្សោយ នោះនឹងមានគណនេយ្យភាពតិចតួចបំផុតចំពោះប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ស្រុក មិនទទួល

បានច្រើនប៉ុន្មានទេ តាមអំណាច "នៅលើក្រដាស"។ តួនាទីនៅមានកំរិតដែលបានចាត់តាំងទៅឱ្យស្រុក មានលក្ខណៈមន្ទីលសំរាប់វិមជ្ឈការតាមបែបប្រជាធិបតេយ្យ ដោយសារថា វត្តមានរបស់រដ្ឋាភិបាលមូលដ្ឋានថ្នាក់មធ្យមនេះនាំអោយមានកំណើនចម្ងាយផ្នែកនយោបាយរវាងឃុំ និងខេត្ត។

ស្រុក ដោយសារតែ ជាប់សាច់ជាប់ឈាមជាមួយអង្គភាពរដ្ឋាភិបាលបោះឆ្នោតឃុំ នឹងប្រហែលជាក្លាយទៅជាមជ្ឈមណ្ឌលនៃទំនាញនៃប្រព័ន្ធទាំងមូល នៅពេលចុងក្រោយ។ បញ្ហាគឺថា ស្រុកនៅពេលនេះ មានភាពទន់ខ្សោយជាងខេត្ត។ ប្រព័ន្ធគណនេយ្យភាពត្រូវប្រះស្រាំតាមអង្គភាព តាមផ្នែករបស់ខ្លួន។ មិនមែនក្រសួង/ទីភ្នាក់ងារទាំងអស់ សុទ្ធតែមានអង្គភាពរបស់ខ្លួននៅថ្នាក់ស្រុក នោះទេ និងមានខ្លះទៀតកំពុងអនុវត្តក្រៅក្របខ័ណ្ឌរដ្ឋបាលស្រុកទៀតផង។ បញ្ហាបូកបន្ថែមពីលើ នេះទៀតគឺកង្វះសង្គតិភាពរវាងវិស័យសេវាកម្ម ដែលបានចាត់តាំងនិងប្រើប្រាស់ដោយក្រសួងខ្លះ ដើម្បីរៀបចំការប្រគល់សេវារបស់គេ និងព្រំដែនរដ្ឋបាលស្រុក។ វិបរិណាម (ការប្រែប្រួល) ដ៏សំខាន់នៃទំហំរបស់ស្រុក ក៏ជាបញ្ហាផងដែរ ដែលនាំអោយមានការលំបាកកាន់តែខ្លាំងឡើងថែមទៀត នៅក្នុងការធ្វើផែនការអោយបានប្រសិទ្ធិភាព សំរាប់ការផ្តល់សេវាសាធារណៈជាមូលដ្ឋាន។ ការលើកកំពស់ប្រសិទ្ធិភាពនៃសកម្មភាពផ្តល់សេវាសាធារណៈជាមូលដ្ឋាននៅថ្នាក់ស្រុក នឹងតម្រូវអោយមានរួចជាស្រេចនូវយន្តការផ្សេងៗដែលនឹងធានាបានថា រដ្ឋបាលស្រុកត្រូវមានគណនេយ្យភាពចំពោះប្រជាជននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន"។ (RGC, ក្របខ័ណ្ឌយុទ្ធសាស្រ្ត, ២០០៦:២)។

យោងតាមរបាយការណ៏សង្ខេបរបស់ Biddulph ថ្នាក់ស្រុក/ខ័ណ្ឌនៅក្នុងប្រទេសកម្ពុជា ត្រូវបាន..... ចំពោះហេតុផលដូចខាងក្រោមៈ

- ការធ្វើវិមជ្ឈការទៅឱ្យថ្នាក់ឃុំ/សង្កាត់ បានកាត់ផ្តាច់ទំនាក់ទំនងគ្រប់គ្រងផ្ទាល់ពីស្រុក/ខ័ណ្ឌ ចំពោះឃុំ/សង្កាត់ ជាពិសេស ដោយសារថា ការគាទ្រចំពោះឃុំ/សង្កាត់ ត្រូវបានគ្រប់គ្រងមួយផ្នែកធំពីថ្នាក់ខេត្ត/ក្រុង។
- ការគ្រប់គ្រងសព្វថ្ងៃ សង្កត់ធ្ងន់ទៅលើការគ្រប់គ្រងតាមខ្សែបណ្តោយពីថ្នាក់ក្រសួងមកមន្ទីរខេត្ត-ក្រុង ចំពោះការិយាល័យបច្ចេកទេសស្រុក/ខ័ណ្ឌ ហេតុនេះហើយវាបានកាត់បន្ថយតួនាទីរបស់ស្រុក/ខ័ណ្ឌ។

- ការទទួលខុសត្រូវដែលមានការពាក់ព័ន្ធតិចតួច និងធនធាននៅក្នុងក្រសួង ត្រូវបានធ្វើវិមជ្ឈការពីបទៅឱ្យខ្សែបណ្ដោយនៅស្រុក/ខ័ណ្ឌ: កម្មវិធីភាគច្រើនត្រូវបានអនុវត្តដោយផ្ទាល់ដោយបុគ្គលិកពីថ្នាក់ជាតិ ឬពីថ្នាក់ខេត្ត (Biddulph ២០០៦: ១២២) ។

សូម្បីតែស្រុកមិនបានទទួលអំណាចលើ"ក្រដាស"ឱ្យបានច្រើននៅក្នុងយុទ្ធសាស្ត្រវ&រ។ "រដ្ឋបាលដែល បានច្របាច់បញ្ចូលគ្នានៅថ្នាក់ស្រុក គួរត្រូវបានចាត់តាំងមុខងារឱ្យបានច្បាស់លាស់នៅក្នុងការបែងចែក សេវាសាធារណ: និងការគ្រប់គ្រងកម្មវិធីអភិវឌ្ឍ.......។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងដំណាក់កាលផ្ដួចផ្ដើមកំណែទំរង់ រដ្ឋបាលថ្នាក់ស្រុកដែលបានច្របាច់បញ្ចូលគ្នាមិនត្រូវមានអង្គភាព គ្រប់គ្រងថវិកាដាច់ដោយឡែកនោះទេ។ ថវិការបស់ស្រុក និងមុខងារគ្រប់គ្រងបុគ្គលិក ត្រូវតែជាផ្នែកបញ្ចូល គ្នាមួយនៃថវិកាដែលបានរួមបញ្ចូលគ្នា និងប្រព័ន្ធគ្រប់គ្រងបុគ្គលិករបស់ខេត្ត"។ (រាជរដ្ឋាភិបាលកម្ពុជា- ក្របខ័ណ្ឌយុទ្ធសាស្ត្រ ២០០៦: ៨)។ ស្រុកក៏នឹងទទួលបានក្រុមប្រឹក្សាស្រុកដែលជាប់ឆ្នោតដោយអសកល ដែល"...នឹងពិនិត្យមើលឡើងវិញ និងអនុម័តលើផែនការថ្នាក់ស្រុក និងសមាសធាតុថ្នាក់ស្រុកនៃថវិកាខេត្ត មុននឹងការបញ្ជូនរបស់ខ្លួន ទៅឱ្យអភិបាលខេត្ត និង ក្រុមប្រឹក្សា")។(រាជរដ្ឋាភិបាលកម្ពុជា- ក្របខ័ណ្ឌយុទ្ធសាស្ត្រ ២០០៦: ៨)

តួនាទីមានកំរិតដែលបានចាត់តាំងទៅឱ្យស្រុក គឺមានបញ្ហាសម្រាប់ការធ្វើប្រជាធិបតេយ្យវិមជ្ឈការ ដោយសារតែវត្តមានរបស់រដ្ឋាភិបាលមូលដ្ឋានអន្តរការីដែលគ្មានអំណាចគ្មានអំណាច បានបង្កើនឱ្យមាន គម្លាតខាងនយោបាយរវាងឃុំ និងខេត្ត។ បញ្ហានេះ យ៉ាងហោចណាស់ក៏ត្រូវបានទទួលស្គាល់នៅក្នុទ្រឹស្ដី ដោយរដ្ឋអំណាចរបស់រាជរដ្ឋាភិបាលកម្ពុជាផងដែរ។ "ជាពិសេស នៅក្នុងអំឡុងអាណត្តិ ៥ ឆ្នាំ ដំបូង ក្រុមប្រឹក្សាស្រុកដែលថ្មី និងត្រូវឱ្យប្រសើរឡើងនេះ គួរតែជួយ និងគាំទ្រដល់ក្រុមប្រឹក្សាឃុំដើម្បីបង្កើត ជំរុញ និងទទួលបានការ-អភិវឌ្ឍន៍បែបប្រជាធិបតេយ្យ។ ក្រុមប្រឹក្សាស្រុកគួរតែលើកស្ទួយ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការគម្រោង និងកម្មវិធីអន្តរឃុំ រួមទាំងការចូលរួមរបស់ក្រុមប្រឹក្សាឃុំនៅក្នុងសម្ព័ន្ធជាតិ គាំទ្រក្រុមប្រឹក្សាឃុំ/សង្កាត់ សមាគមន៍ថ្នាក់ខេត្ត និងបណ្ដាញការងារនៅថ្នាក់ស្រុករបស់ខ្លួន ។ ហេតុនេះ ទើបសេចក្ដីព្រាងច្បាប់បានសង្កត់ធ្ងន់ទៅលើការជាប់ទាក់ទងរវាងឃុំ និងស្រុក ជាមួយនឹងគោលបំណងនៃ ការពង្រឹងអភិបាលកិច្ចបែបប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន។ យោងតាមច្បាប់រៀបចំអង្គការ ក្រុមប្រឹក្សាស្រុកក៏នឹងទទួលខុសត្រូវ

ផងដែរចំពោះការផ្តល់សេវា សម្ភារៈជួយសម្រួល និងហេដ្ឋារចនា សម្ព័ន្ធពីថ្នាក់ស្រុក ឱ្យស្របទៅនឹងមុខងារដែលបានប្រគល់មកឱ្យក្រុមប្រឹក្សាស្រុក។ (ឯកឧត្តម ព្រុំ សុខា ២០០៧: ៣៩-៤០)។

តាមការពិត **ឃុំ** គឺជាផ្នែកឆ្លើយតបនៃវិមជ្ឈការគិតមកទល់ពេលនេះ។ ក្នុងខណៈដែលមានភាព សមហេតុ-សមផលពិតប្រាកដចំពោះជំរើសនេះ ការបញ្ចប់ដំណើរការដើម្បីជុំវិញនីតិប្រតិបត្តិ និងក្រុមប្រឹក្សាស្រុក និងខេត្តដែលជាប់ឆ្នោត គួររាប់បញ្ចូលនូវការពិចារណាពីទំហំ (ប្រជាពលរដ្ឋ និងបូរណភាពដែនដីរបស់ អង្គភាពរដ្ឋាភិបាលមូលដ្ឋាន ដែលមានលក្ខណៈល្អប្រសើរចាប់តាំងពីចំនុចមានប្រៀបខាងរដ្ឋបាល និង វិមជ្ឈការ។ ឃុំនៅកម្ពុជាមានលក្ខណៈស្រដៀងគ្នា និងថែមបុន (tambom) ដែលត្រូវបានធ្វើឱ្យទៅជា ផ្នែកឆ្លើយតបនៃវិមជ្ឈការនៅក្នុងប្រទេសថៃ។ តែនៅក្នុងប្រទេសហ្វីលីពីន និងឥណ្ឌូណេស៊ី ចំនុចកណ្តាលនៃ ភាពស្រួចស្រាវនៃវិមជ្ឈការ គឺក្រុង និង ការប៊ូប៉ាតិន (kabupaten) ដែលមានលក្ខណៈស្ទើរតែដូចគ្នានឹង ស្រុកនៅកម្ពុជា។ ការបន្តការពិភាក្សាទៅលើការច្របាច់ឃុំបញ្ចូលគ្នាមិនគួរមានសិទ្ធិបុព្វក្រៃលើសេចក្តីសំរេចពី តួនាទីរបស់ស្រុក និងការទំនាក់ទំនងរបស់ខ្លួនចំពោះឃុំនោះឡើយ។

ក្នុងពេលរង់ចាំសេចក្តីសំរេចទៅលើតួនាទីរបស់ស្រុក គួរផ្តោតការយកចិត្តទុកដាក់ការំពង្រឹងឃុំ។ "វាច្បាស់-ណាស់ថា ក៏រិតរដ្ឋាភិបាលពឹងពាក់យ៉ាងខ្លាំងទៅលើរចនាសម្ព័ន្ធគាំទ្រ។ ផ្ទុយទៅវិញ ចំនុចនេះបាន ពង្រីកលំហរភាពលប់លើពីថ្នាក់លើមកថ្នាក់ក្រោម ដែលជាប្រព័ន្ធមួយវិមជ្ឈការគួរតែលប់បំបាត់ចំនុចនេះ។ (Rusten ២០០៥:៨៨)។ សម្រាប់ការចាប់ផ្តើមជាមួយស្ថានភាពមិនធម្មតាដែលក្រុមប្រឹក្សាដែលជាប់ឆ្នោតត្រូវធ្វើការជាមួយស្មៀន ដែលជាបុគ្គលិកតែម្នាក់គត់តែតាំងឡើងដោយក្រសួងមហាផ្ទៃ គួរតែធ្វើការកែប្រែ។ ក្រុមប្រឹក្សាឃុំមួយបានរៀបរាប់ចំនុចនេះថា "ដោយសារតែឃុំខ្វះខាតបុគ្គលិករដ្ឋបាល សមាជិកក្រុមប្រឹក្សាខ្លួនឯងត្រូវធ្វើការងារប្រតិបត្តិ។ ក្រុមប្រឹក្សាឃុំរបស់កម្ពុជាអាចត្រូវបកស្រាយថា អង្គការដែលមានជើងមួយដែលជាអង្គការនីតិបញ្ញត្តិផង អង្គការនីតិប្រតិបត្តិផង និងជាអង្គការត្រួតពិនិត្យតាមដានផង។ អាចនិយាយម្យ៉ាងទៀតថា សមាជិកក្រុមប្រឹក្សាមានសិទ្ធិធ្វើបទបញ្ជាផ្ទៃក្នុងដោយខ្លួនឯង ពួកគេបំពេញការងារផ្នែកនីតិប្រតិបត្តិ ហើយពួកគេបំពេញគុណភាពត្រួតពិនិត្យគំរោងទាំងឡាយដោយខ្លួនឯង។ (Rusten ២០០៥: ៨៨)។

ស្ថានភាពសារពើពន្ធរបស់ឃុំគួរតែត្រូវបានដោះស្រាយ ប្រសិនបើមិនកែប្រែចំនុចដទៃទៀតនោះទេ ដោយការផ្តល់មកឱ្យឃុំនូវអំណាចប្រមូលពន្ធអាករ ដែលសមស្រប។ សម្រាប់ពេលបច្ចុប្បន្ននេះ កំរៃដែលឃុំ អាចប្រមូលបានតែមួយគត់នោះគឺការចុះបញ្ជីអត្រានុកូលដ្ឋាន។ ស្មៀនឃុំជាអ្នកប្រមូលកំរៃនេះ។ យោងតាមការបញ្ជាក់ជាបឋម កំរៃនេះមានចំនួនកំរិតមែនទែន។ បច្ចុប្បន្ន ស្រុកជាអ្នកប្រមូលពន្ធអាករនៅកំរិតថ្នាក់ភូមិ។ ក្រុមស្រាវជ្រាវបានបញ្ជាក់ថាកំរៃទីផ្សារដែលបានបង់នៅតាមភូមិ (កំរៃប្រចាំថ្ងៃ គឺផាស៊ី) កំរៃប្រចាំខែ (ពន្ធដារ) ក៏ដូចជាកំរៃប្រចាំឆ្នាំ (ពន្ធបាតង់) ទៅលើម៉ាស៊ីនស្រូវ និងមុខរបរ "យន្តកម្ម" ផ្សេងទៀតមានចំនួនយ៉ាងច្រើន ហើយប្រសិនបើបញ្ញត្តិច្បាប់ត្រូវបានចេញដើម្បីឱ្យឃុំធ្វើការប្រមូលពន្ធទាំងនេះ នោះវាអាចធ្វើឱ្យមានចំណូលមួយច្បាស់លាស់។ ដូចនេះ តម្រូវឱ្យមានដំណោះស្រាយលើការចេញ បញ្ញត្តិច្បាប់សម្រាប់ការប្រមូលពន្ធដោយឃុំ ដោយមានប្រពន្ធតម្លាភាព និងការទទួលខុសត្រូវ។ ទំរាំដល់ឃុំ អចប្រមូលថវិកាផ្ទាល់ខ្លួនបាន វាចាំបាច់ណាស់ដែលការផ្ទេរមុខងារត្រូវធ្វើឱ្យស្របគ្នាជាមួយការផ្តល់ធនធានឱ្យបានគ្រប់-គ្រាន់ដើម្បីដោះស្រាយបញ្ហា។ វាមានគ្រោះថ្នាក់ដែលថាអង្គភាពទាំងឡាយបង្វែរការទទួលខុសត្រូវរបស់ខ្លួនដោយមិនមានការផ្តល់ធនធានដែលចាំបាច់នោះ។ (CDRI PORDEC ២០០៣: ២០-២២)។

គួរតែមានការផ្សព្វផ្សាយមួយដើម្បីធ្វើវិសោធនកម្មច្បាប់ និងបំពេញចន្លោះប្រហោងច្បាប់ដើម្បីធ្វើឱ្យ ស្វ័យ-ភាពរបស់ឃុំមានភាពប្រសើរឡើង និងពង្រីកអំណាចរបស់ឃុំ។ ឧទាហរណ៍ មាត្រា ៤៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ចែងថា "....រដ្ឋបាលឃុំ ត្រូវមានកាតព្វកិច្ចការពារ និងថែរក្សាបរិស្ថានធនធានធម្មជាតិ វប្បធម៌ និងបេតិកភ័ណ្ឌជាតិ"។ ផ្ទុយទៅវិញ ប្រឈមមុខចំពោះកាតព្វកិច្ចទាំងនេះ មាត្រា ៤៥ ចែងថា រដ្ឋបាលឃុំ-សង្កាត់ មិនត្រូវមានដើម្បីសម្រេចលើបញ្ហាព្រៃឈើនោះទេ។ (Biddulph ២០០៣:៣០)។ អំណាចទាំងនេះសំខាន់បំផុត ព្រោះក្រុមប្រឹក្សាឃុំ កំពុងត្រូវបានស្នើសុំឱ្យធ្វើអន្តរាគមន៍ចំពោះវិវាទលើបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ និងបេតិកភ័ណ្ឌជាតិ។ វិវាទទាំងនេះកំពុងកើនឡើងដោយសារល្បឿននៃការអភិវឌ្ឍន៍កំពុងមានភាពខ្លាំងខ្លា។

ថ្នាក់**ភូមិ**ពិបាកយកចិត្តទុកដាក់ចំពោះឯកសាររបស់រដ្ឋាភិបាលណាស់។ ប៉ុន្តែ សូម្បីតែរដ្ឋាភិបាលថ្នាក់ភូមិ មិនអាចធ្វើទៅបាននៅដំណាក់កាលនេះចំពោះដំណើរវិមជ្ឈការក៏ដោយ និយាយឱ្យសមហេតុសមផលទៅគឺ ថ្នាក់ភូមិជាចំនុចស្នូលនៃជីវិតរស់នៅរបស់ប្រជាពលរដ្ឋ។ សាប់ស៊ីដាយរី (subsidiary គួរតែចាប់ផ្តើមនៅ ត្រង់

ចំនុចនេះ)។ សំខាន់ជាងនេះទៅទៀត តាមមើលទៅគណៈបក្សប្រជាជនកម្ពុជាយល់ថា ការត្រួតពិនិត្យចាប់ផ្តើមនៅកំរិតនេះ។ សព្វថ្ងៃនេះ មេភូមិត្រូវបានតែងតាំងនៅភ្នំពេញ ដោយក្រសួងមហាផ្ទៃ។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ចែងថា ក្រុមប្រឹក្សាឃុំគួរជ្រើសរើសមេភូមិថ្មី តែចំនុចត្រង់នេះតម្រូវឱ្យមានអនុក្រិត្យបន្ថែមទៀតពីក្រសួងមហាផ្ទៃ មុននឹងអនុវត្តចំនុចនេះបាន។ ការអំពាវនាវឱ្យមានការបោះឆ្នោតជ្រើសរើសមេភូមិដោយផ្ទាល់គួរតែត្រូវបានបន្ត ប៉ុន្តែ អាចអំពាវនាវឱ្យមានការផ្សព្វផ្សាយមួយនៅចន្លោះពេលនេះដើម្បីឱ្យក្រុមប្រឹក្សាឃុំជាអ្នកតែងតាំងមេភូមិជំនួយឱ្យក្រសួងមហាផ្ទៃ ជាពិសេស ដោយសារតែពួកគេបានទទួលប្រាក់កំរៃពីថវិកា CSF ។ គួរផ្តល់ការយកចិត្តទុកដាក់ពិសេសចំពោះតួនាទីរបស់ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (VDC)។ ទោះបីជាអ្នកសង្កេតការណ៍ខ្លះនិយាយថា សមាជិកភាពនៅក្នុង VDC មិនព្យាយាមខិតខំធ្វើការទេ ព្រោះពកគេមិនបានទទួលប្រាក់កំរៃ ក៏វាអាចជាឧបករណ៍មួយយ៉ាងសំខាន់សំរាប់ការចូលរួមនៅក្នុងការងារនៅថ្នាក់ភូមិ។

ជាទ្រឹស្តី រដ្ឋាភិបាលមានបំណងដោះស្រាយបញ្ហាទាំងអស់នេះ។ "ហេតុនេះ ទស្សនៈនៃ សាប់ស៊ីដាយរីធី (subsidiarity)គឺអាស្រ័យទៅលើសម្មតិកម្មដែលថា មុខងារមួយដែលចាត់ចែងដោយអាជ្ញាធរដែលនៅជិតប្រជាជនដែលទទួលការប៉ះពាល់ មានប្រសិទ្ធិភាពបំផុត លើកលែងតែវាបង្ហាញច្បាស់ថា មុខងារនោះអាចចាត់ចែងបានប្រសើរដោយអាជ្ញាធរថ្នាក់លើ។ ហេតុដូចនេះ វាអាចរំពឹងថាមុខងារជាច្រើននឹងត្រូវបានផ្ទេរទៅឱ្យក្រុមប្រឹក្សាឃុំដែលជាអង្គភាពនៅជិតប្រជាជនបំផុតនៅប៉ុន្មានឆ្នាំខាងមុខនេះ។ ប៉ុន្តែ ភាពដែលអាចសំរេចបានរបស់ក្រុមប្រឹក្សាឃុំជាច្រើនក្នុងនាមជាអាជ្ញាធរអភិវឌ្ឍន៍ គឺត្រូវបានរាំងស្ទះដោយទំហំ ឬទីតាំងរបស់ខ្លួន។ ហេតុដូច្នេះ វាអាចរំពឹងបានថា មុខងារដែលគួរពិចារណាមួយចំនួននឹងត្រូវផ្តល់ឱ្យក្រុមប្រឹក្សាស្រុក ខេត្ត និងក្រុង ដែលជាអង្គភាពអភិបាលកិច្ចស្ថិតនៅជិតប្រជាជនបន្ទាប់"។(ឯកឧត្តម ព្រុំ សុខា ៣៤)។

ដំណាក់កាលថ្មីនេះគួរត្រូវបានផ្តោតការយកចិត្តទុកដាក់ចំពោះការធ្វើឱ្យដល់កំរិតអតិបរមានូវការទទួល បានប្រជាធិបតេយ្យរបស់ក្រុមប្រឹក្សាឃុំ ដោយផ្តោតការយកចិត្តទុកដាក់ទៅលើទំនាក់ទំនង"ខ្សែទទឹង" នៅទូទាំងក្រុមប្រឹក្សាឃុំ និងបណ្តាញអង្គការមិនមែនរដ្ឋាភិបាលនៅកំរិតនេះ។ ប្រការនេះអាចបង្កើនសក្តានុពលចំពោះសម្ពាធពី"ថ្នាក់ក្រោមឡើងមក" សម្រាប់ការពង្រឹងក្រុមប្រឹក្សាឃុំក្នុងពេលដំណាលគ្នា និងការធ្វើវិសហមជ្ឈការទៅឱ្យថ្នាក់ស្រុក និងខេត្ត កានតែជា "វិមជ្ឈការ"ខ្លាំងឡើង។ មានការខិតខំប្រឹងប្រែងបន្តទៅ

ទៀតដើម្បីបង្កើតសមាគមសមាជិកក្រុមប្រឹក្សាឃុំ និងផ្ដល់ឱកាសសម្រាប់ផែនការអភិវឌ្ឍដែលមានលក្ខណៈចូលរួមពីក្នុងចំណោមឃុំ អាចធ្វើដំណើរវែងឆ្ងាយឆ្ពោះទៅកាន់វិមជ្ឈការក្នុងលក្ខណៈសាមគ្គីគ្នា។ នៅពេលណាដែលការអនុវត្តនយោបាយដើរតាមខ្សែបណ្ដោយ នោះគណៈបក្សនយោបាយនឹងបន្តមានភាព លើសលប់។ វាមានតែការជំរុញការសម្របសម្រួលទំនាក់ទំនងខ្សែ"ទទឹង"ទេ ទើបវេទិកាសម្រាប់ប្រភេទថ្មី នៃនយោ-បាយ អាចត្រូវបានអភិវឌ្ឍ។

ការបែងចែកសព្វថ្ងៃទៅឱ្យក្រុមប្រឹក្សាឃុំ គឺមានតែគំរោងនៅថ្នាក់ឃុំតែប៉ុណ្ណោះ។ បញ្ហាអភិវឌ្ឍជាច្រើនមានលក្ខណៈជាអន្តរឃុំ ហើយតម្រូវឱ្យមានការសហការជាអន្តរឃុំ។ ឧទាហរណ៍ ជំលោះដីធ្លី ការគ្រប់-គ្រងធនធាន និងការផ្ដល់សេវាផ្សេងៗ ដូចជា សុខាភិបាល អប់រំ និងការផ្សព្វផ្សាយកសិកម្ម ក្នុចំណោមបញ្ហាផ្សេងៗទៀត។ ការគាំទ្រការរ៉ាប់រងជាអន្តរឃុំអាចសម្របសម្រួលដល់ការអភិវឌ្ឍន៏តំបន់ មូលដ្ឋានដោយការធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានមានភាពប្រសើរឡើង បង្កើនលទ្ធភាពទីផ្សារ និងអាចបង្កើនសក្ដា-នុពល ចំណូលដល់សហគមន៏។ ការអនុវត្តន៏សកម្មភាពអន្តរឃុំក៏សម្របសម្រួលដល់ការអភិវឌ្ឍន៏ សមត្ថភាពចំពោះការចូលរួមពាក់ព័ន្ធតាមរយៈការចរចារ និងទំនាក់ទំនងទៅវិញទៅមកក្នុងចំណោមដៃគូ ពាក់ព័ន្ធ។ (EU-UNDP ២០០៦: ៧)។ គំរោងអន្តរឃុំរបស់ UNDP-EU មួយកំពុងតែបន្តដំណើរការ។ បញ្ហាគឺនៅត្រង់ថា ការងារនៅក្នុងខេត្តគំរោងសាកល្បងប្រាំពាក់ព័ន្ធតែទៅនឹងគំរោងហេដ្ឋារចនាសម្ព័ន្ធ។ បញ្ហាមួយទៀតគឺថា គំរោងកសាងសម្ព័ន្ធសមាជិកក្រុមប្រឹក្សាឃុំកំពុងត្រូវបានអនុវត្តនៅថ្នាក់ខេត្តតែប៉ុណ្ណោះ គឺមិននៅថ្នាក់ស្រុកដូចដែលបានស្នើឡើងនៅក្នុងសំណើដើមរបស់ UNDP នោះទេ។ ទោះបីសម្ព័ន្ធនឹងជា អង្គការមិនមែនរដ្ឋាភិបាលក៏ដោយ ក៏គំនិតផ្ដួចផ្ដើមដើម្បីបង្កើតសម្ព័ន្ធនេះគឺបានមកពីក្រសួងមហាផ្ទៃ ហើយ សមាគមខេត្តមួយចំនួននឹងត្រូវទទួលស្គាល់ដោយក្រសួងមហាផ្ទៃ។

## នយោបាយវិមជ្ឈការ និងវិសហមជ្ឈការ

ប្រសិនបើលោក លោកស្រីក្រលេកមើលដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ (វ&វ) និងគំនរអក្សរសាស្ត្រដែលបានបង្កើនឡើង លោក លោកស្រីអាចមានអារម្មណ៍ថាដំណើរការនេះត្រូវបានប្រតិបត្តិជាមួយកិរិតស្ម័យភាពដែលគួរឱ្យពិចារណា។ ចំនុចនេះវាពិតក្នុងកិរិតមួយ ដែលដំណើរការភាគច្រើននៃការបង្កើនយោបល់ដើម្បីឱ្យវ&វ មានដំណើរការឆ្ពោះទៅមុខ គឺកើតឡើងក្នុងរង្វង់ទីប្រឹក្សាអ្នកផ្ដល់ជំនួយមួយក្រុម

និងមន្ត្រីសំខាន់របស់រាជរដ្ឋាភិបាលកម្ពុជានៅក្រសួងមហាផ្ទៃនៅក្នុងទីក្រុងភ្នំពេញ។ នៅក្រៅទីក្រុងភ្នំពេញ ការងារអភិវឌ្ឍ និងការកសាងសមត្ថភាពនៅក៏រិតក្រុមប្រឹក្សាឃុំត្រូវបានរៀបចំឡើងដោយកម្មវិធីសីលា និង អង្គការអន្តរជាតិសំខាន់ៗមួយចំនួន។ ប៉ុន្តែ ការងារនេះត្រូវបានដំណើរការនៅក្នុងរង្វង់នយោបាយដែល ចង្អៀត ដែលរៀបចំឡើងដោយរដ្ឋាភិបាល ជាពិសេសបំផុតដោយគណៈបក្សប្រជាជនកម្ពុជា (CPP)។ ក៏រិតសំខាន់ បំផុតគឺការអនុញ្ញាតឱ្យមានវិមជ្ឈការតែនៅថ្នាក់ក្រុមប្រឹក្សាឃុំ។

ឯកឧត្តម ព្រុំ សុខា មន្ត្រីជាន់ខ្ពស់មួយរូប ក្នុងចំណោមមន្ត្រីជាន់ខ្ពស់ពីររូបនៃរាជរដ្ឋាភិបាលកម្ពុជា ដែលផ្តល់ ភាពដឹកនាំដល់ដំណើរការ វ&វ ហាក់ដូចជា មិនច្បាស់លាស់នៅក្នុងការវាយតំលៃថ្មីៗរបស់ខ្លួន។ "ពុំមានសេវា សាធារណៈលេចធ្លោណាត្រូវបានធ្វើវិសហ មជ្ឈការទៅឱ្យក្រុមប្រឹក្សាឃុំ/សង្កាត់នោះទេ.....។ វិសហមជ្ឈការ ចំពោះក្រុមប្រឹក្សាទាំងនេះត្រូវបានក៏រិត ចំពោះសកម្មភាពជាទម្លាប់ដែលពាក់ព័ន្ធ ដូចជា ការចុះបញ្ជីអត្រា នុកូលដ្ឋាន និងការចុះឈ្មោះបោះឆ្នោត និងការប្រមូលទិន្នន័យព័តិមានសំខាន់ៗទាក់ទិន ទៅនឹងផែនការ អភិវឌ្ឍន៏។ ហេតុនេះ វិសហមជ្ឈការ ដែលមានក៏រិតទាបផ្តល់ឱ្យក្រុមប្រឹក្សាឃុំ/សង្កាត់ សព្វថ្ងៃ គឺមិនមែន បណ្តាលមកពីការខ្វះសមត្ថភាពនៅក្នុងក្រុមប្រឹក្សាឃុំនោះទេ ហើយវាក៏មិនមែនបណ្តាល មកពីក្រសួងបង្កើត ការិយាល័យសាខារបស់ខ្លួននោះទេ។ ផ្ទុយទៅវិញ វាឆ្លុះបញ្ចាំងពីភាពស្ទាក់ស្ទើរ ឬការពុំមានឆន្ទៈរបស់បណ្តា ក្រសួងជាច្រើន ដែលយ៉ាងហោចណាស់គិតមកទល់ពេលនេះចំពោះការផ្ទេរ អំណាចមួយចំនួនធំទៅឱ្យទីភ្នាក់- ងារនៅក្រោមថ្នាក់ជាតិ។ តរិយាបទរបស់បណ្តាក្រសួងត្រូវតែផ្លាស់ប្តូរ ដើម្បីបង្កើនការអភិវឌ្ឍន៍ និងកាត់ បន្ថយភាពក្រីក្រ។ (ឯកឧត្តម ព្រុំ សុខា ២០០៧: ២០-២១)។

ស្វ័យភាពដែលជាប់ពាក់ព័ន្ធនេះ បានអនុញ្ញាតឱ្យដំណើរការ វ&វ បង្កើតបាននូវ "អារ្យធម៌" ជាទ្រឹស្តី លោក ខាងលិចដ៏ធំ ដែលផ្ទុយគ្នាយ៉ាងខ្លាំង ដោយមានភាពគំរោះគំរើយ និងការជូលរលំនយោបាយបក្ស ដោយ CPP ជាអ្នកមានប្រៀប គណៈបក្សហ៊្វុនស៊ីនប៉ិច FUNCINPEC (រណសិរ្ស បង្រួបបង្រួមជាតិដើម្បីឯករាជ្យ អព្យាក្រិត្យ សន្តិភាព និងសហប្រតិបត្តិការកម្ពុជា) ដឹកនាំដោយសម្តេច ក្រុមព្រះ នរោត្តម រណរិទ្ធិ និង គណៈបក្ស សម រង្ស៊ី (SRP) ដឹកនាំដោយ លោក សម រង្ស៊ី។ FUNCINPEC បានឈ្នះឆ្នោតក្នុងឆ្នាំ ១៩៩៣ បានយល់ព្រមចែករំលែកអំណាចជាមួយ CPP ក្រោយមកក៏បានបញ្ចប់ដោយត្រូវបានបណ្តេញចេញ ពីរដ្ឋាភិបាលចំរុះដោយរដ្ឋប្រហារធ្វើឡើងដោយ CPP ក្នុងឆ្នាំ ១៩៩៧។ ចំណែក CPP ដែលជាអ្នកឈ្នះ

ឆ្នោតលំដាប់ទីពីរ ក្នុងឆ្នាំ ១៩៩៣ បានប្រើប្រាស់កំលាំងយោធា និងការិយាល័យធិបតេយ្យរបស់ខ្លួន ដោយបង្កើនអំណាចរបស់ខ្លួនបន្តិចម្តងៗ។ ក្រោមការគាបសង្កត់ពីអន្តរជាតិយ៉ាងខ្លាំង CPP បានយល់ព្រម ជាមួយនឹងមានការបោះឆ្នោតដែលបានរៀបចំឡើងក្នុងឆ្នាំ ១៩៩៨ ដែលពេលនេះបានទទួលសំលេងឆ្នោត លំដាប់លើបំផុតជាមួយនឹងសំលេងឆ្នោត ៤១%។ រដ្ឋាភិបាលចំរុះបន្ទាប់មកទៀតបានកែប្រែតួនាទីរបស់ CPP-FUNCINPEC ដែលសព្វថ្ងៃនេះ CPP មានភាពលើសលប់យ៉ាងខ្លាំង។

អំណាចរបស់ CPP បានកសាងលើគ្រឹះស្ថាប័នរបស់សាធារណៈរដ្ឋប្រជាមានិតកម្ពុជា (PRK) ដែលបង្កើតឡើង ដោយវៀតណាម។ CPP ត្រូវបានស្ថាបនាឡើងដោយវៀតណាម ដំបូងជាគណៈបក្ស កុំមុយនីស្ត ដែលលោក ហ៊ុនសែន បានក្លាយជានាយករដ្ឋមន្ត្រីនៅក្នុងឆ្នាំ ១៩៨៥ មុនពេលវៀតណាម បានចាកចេញទៅ។ "PRK ដំបូងឡើយគឺជាស្ថាប័នមិនមានរូបរាងច្បាស់លាស់ ដែលនៅពីខាងក្រោយខ្នង មានការត្រួត-ពិនិត្យដោយនយោបាយវៀតណាម និងមានកងទ័ព ព្រមទាំងកំលាំងសន្តិសុខដទៃទៀតរបស់ វៀតណាម ដែលជារឿយៗបានប្រតិបត្តិការយ៉ាងឯករាជ្យពីរដ្ឋអំណាចកម្ពុជា ដោយស្វ័យភាពនយោបាយ ពាក់ព័ន្ធរបស់កងកំលាំងទាំងនោះ។ របបនេះក៏ក្លាយជាទ្រឹស្តីនិយមក្លែងក្លាយ ដោយមានការលែងជាល្បែង មិនស្មោះត្រង់ និងឆាកល្ខោនក្លែងក្លាយ និងគ្របដណ្តប់លើបណ្តាញរបស់ការិយាល័យធិបតេយ្យ យោធា និងអំណាចសេដ្ឋកិច្ចកម្ពុជា។ បណ្តាញទាំងនេះ និងកងកំលាំងប្រដាប់អាវុធនៅក្រោមការបញ្ជារបស់ពួកគេ បានជំនួសអ្នកត្រួតពិនិត្យវៀតណាម អ្នកពង្រឹង និងកងទ័ព ដោយទទួលការគ្រប់គ្រងទៅលើកងទ័ព នគរបាល និងផ្នែកផ្សេងទៀត និងបានកែប្រែអង្គការសន្តិសុខ ទុកឱ្យរដ្ឋនេះនៅជាល្បែងទ្រឹស្តីនិយមបែបស្ថាប័ន។ (Heder, Theater, ១៧)។

CPP "បានទទួលកេរ្តិ៍ដំណែល" ការិយាល័យធិបតេយ្យ និងរចនាសម្ព័ន្ធសន្តិសុខនេះ ដែលជារចនាសម្ព័ន្ធរដ្ឋា-ភិបាលក្នុងទ្រឹស្តី ជំនួយឱ្យការពិតនៅក្នុងការបោះឆ្នោតលើកទីមួយក្នុងឆ្នាំ ១៩៩៣ ដែល FUNCINPEC ជាអ្នកឈ្នះអាសនភាគច្រើន។ ចំនុចនេះត្រូវបានកែសម្រួលដោយ UNTAC យ៉ាងចចេស ដែលពីមុនមក "..ជំនួសឱ្យការធ្វើអព្យាក្រិត្យភាព CPP អង្គការសហប្រជាជាតិពិតជាបានរៀបចំឡើងដើម្បីទប់ស្កាត់ការដួលរលំសេដ្ឋកិច្ចរបស់ខ្លួន ដែល UNTAC ខ្លាចមានភាពបះបោរ និងបានជំរុញឱ្យកងកំលាំង CPP ធ្វើការវាយប្រហារដើម្បីឱ្យខ្មែរក្រហមស្ថិតនៅផ្នែកម្ខាង។ (Heder, Theater, ២០)។ ក្រៅពីបញ្ហាសន្តិសុខ CPPក៏បាន

គ្រប់គ្រងទៅលើមេភូមិក្នុងអំឡុងពេល PRK និងរក្សារហូតមកដល់ក្រោយអំឡុងពេលបោះឆ្នោត ១៩៩៣។ គឺបណ្តាញនេះហើយដែល CPP បានប្រើប្រាស់នៅក្នុងការឃោសនាបោះឆ្នោត ដែលក្រោយមកបានគ្របដណ្តប់ទៅលើក្រុមប្រឹក្សាឃុំ។ ក្នុងពេលជាមួយគ្នានេះដែរ CPP បានប្រើប្រាស់ការត្រួតពិនិត្យផ្នែកសន្តិសុខដើម្បីវាយប្រហារ និងគំរាមកំហែងដៃគូប្រគួតប្រជែងរបស់ខ្លួន គឺ គណៈបក្ស FUNCINPEC និង សមរង្ស៊ី។

ក្នុងការបោះឆ្នោតជាបន្តបន្ទាប់ ក្នុងឆ្នាំ ២០០៣ CPP បានកើតអាសនៈរបស់ខ្លួនជាថ្មីម្តងទៀតដោយ ឈ្នះអាសនៈចំនួន ៧៣ លើអាសនៈសរុបចំនួន ១២៣។ ប៉ុន្តែខ្លួនមិនអាចបង្កើតរដ្ឋាភិបាលតែឯងបាន ដោយខ្វះអាសនៈចំនួន ៩ ដើម្បីឱ្យគ្រប់សំលេងភាគច្រើន ពីរភាគបី ដូចដែលដតម្រូវដោយរដ្ឋធម្មនុញ្ញ ដើម្បីឱ្យគណៈ-បក្ស មួយបង្កើតរដ្ឋាភិបាលតែឯងបាន។ ប្រសិនបើ CPP បានកើនអាសនៈរបស់ខ្លួននៅក្នុង រដ្ឋសភាជាមណ្តើរៗ នោះអាសនៈ FUNCINPEC ត្រូវថយចុះ។ FUNCINPEC ទទួលបានអាសនៈតែ ២៦ ដែលខុសឆ្ងាយពីចំនួនអាសនៈ ៥៣ ដែលខ្លួនទទួលបាននៅក្នុងឆ្នាំ ១៩៩៣ និង ៤៣ អាសនៈដែលខ្លួន ទទួលបានក្នុងឆ្នាំ ១៩៩៨។ SRP ដែលជាក្រុមបំបែកខ្លួនពី FUNCINPEC បានទទួលជ័យជំនះយ៉ាងល្អ ដោយទទួលបានអាសនៈចំនួន ២៤ គឺមានចំនួនអាសនៈ ៩ លើសពីចនួនអាសនៈដែលខ្លួនទទួលបានក្នុងឆ្នាំ ១៩៩៨។ គណៈបក្សទាំងពីរបានចរចារគ្នាដើម្បីទទួលបានសម្បទានពី CPP ទាំងអស់គ្នា ដោយបង្កើតឱ្យមានភាព-ទាល់ច្រក ដោយបានរារាំងចំពោះការបង្កើតរដ្ឋាភិបាលចំនួនដប់មួយខែ។ ភាពទាល់ច្រកនេះបានបាត់បង់ទៅវិញនៅពេល FUNCINPEC បានបោះបង់ SRP ហើយបានចរចារជាមួយ CPP នៅក្នុងខែកក្កដា ២០០៤។ នៅក្នុងឆ្នាំ ២០០៦ SRP បានធ្វើការចរចារជាមួយ CPP ហើយបានបានគាំទ្រដល់ការធ្វើវិសោ-ធនកម្មរដ្ឋធម្មនុញ្ញ ដែលកែប្រែសំលេង ២ ភាគ ៣ ដើម្បីបង្កើតរដ្ឋាភិបាល។

អំឡុងពេលពីឆ្នាំ ១៩៩៣ ដល់ ២០០៦ គឺមានស្ថេរភាព បើប្រៀបធៀបទៅនឹងសង្គ្រាមពីរទស្សវត្ស ដែលមានពីមុនមកនេះ។ នៅក្នុងខែ កក្កដា ១៩៩៤ មានការប៉ុនប៉ងធ្វើរដ្ឋប្រហារមួយ ធ្វើឱ្យមន្ត្រី CPP ពីររូបរត់ភៀសខ្លួនទៅក្រៅប្រទេស។ នៅក្នុងឆ្នាំ ១៩៩៥ សម្តេចក្រុមឃុន នរោត្តម សេរីវង្ស អតីតរដ្ឋមន្ត្រី ក្រសួងការបរទេស ត្រូវបានចាប់ខ្លួនពីបទប៉ុនប៉ងធ្វើឃាត លោក ហ៊ុន សែន។ គាត់ក៏បាននិរទេសខ្លួន។ នៅក្នុង ឆ្នាំ ១៩៩៧ មានការវាយប្រហារគ្នាកើតឡើងរវាងកងកំលាំង FUNCINPEC និង CPP ។ FUNCINPEC

បានចាញ់ ហើយមនុស្សរបស់ខ្លួនរាប់រយនាក់ត្រូវបានសំលាប់ និងបានបណ្តេញមេដឹកនាំ ទាំងឡាយរបស់ FUNCINPEC ទៅក្រៅប្រទេស ហើយ លោក ហ៊ុន សែន បានធ្វើនាយករដ្ឋមន្ត្រីតែឯង។ នៅមុននេះ ក្បួនបាតុកម្មរបស់គណៈបក្ស SRP ត្រូវបានបំបែកដោយការបោះគ្រាប់បែកដែលបានសំលាប់ មនុស្សចំនួន ១៥ នាក់។ នៅក្នុងឆ្នាំ ២០០៤ លោក ហ៊ុន សែន បានចាកចេញ ក្រោយពីគូបដិបក្ខដ៏សំខាន់ របស់ខ្លួននៅក្នុង CPP ដែលជាប្រធានព្រឹទ្ធសភា និងជាប្រមុខរដ្ឋស្តីទី គឺលោក ជា ស៊ីម ដែលបានបដិសេធ ចុះហត្ថលេខាលើច្បាប់ដែលមានភាពចំរោងចំរាស់ដើម្បីអនុញ្ញាតឱ្យបង្កើតរដ្ឋាភិបាលថ្មី។ លោក ជា ស៊ីម ត្រូវបាននិរទេសទៅទីក្រុងបាងកក ហើយអ្នកជំនួសគាត់បានចុះហត្ថលោខាលើច្បាប់នោះ។ សមាជិកតំណាង រាស្ត្រ SRP ដែលសង្ឃឹមថានឹងធ្វើការរារាំងដល់ដំណោះស្រាយដោយការបដិសេធចូលរួមប្រជុំរដ្ឋសភា ត្រូវបានដកចេញ។ ដោយបានគំរាមកំហែងចាប់ខ្លួន លោក សម រង្ស៊ី មេដឹកនាំគណៈបក្ស សម រង្ស៊ី ក៏បាន ចាកចេញពីប្រទេស ហើយបានត្រលប់មកវិញនៅក្នុងឆ្នាំ ២០០៦ បន្ទាប់ពីគាត់បានធ្វើការចរចារជាមួយ លោក ហ៊ុន សែន។

អ្នកវិភាគនយោបាយមួយរូបមានការធ្វើសេចក្តីសន្និដ្ឋានយ៉ាងស្រួចស្រាវពិសេសពីដំណើរការនេះ។"UNTAC មានអាណត្តិការងារមកលើប្រទេសកម្ពុជា ហើយប៉ុន្មានឆ្នាំក្រោយពីនោះមក បានធ្វើមិនឱ្យមានភាពច្បាស់-លាស់ធៀបទៅនឹង រយៈពេលមុនការប្រគួតប្រជែងដល់ការគ្រប់គ្រងរដ្ឋក្រោយអាណានិគមនៅក្នុង ប្រទេសកម្ពុជា និងកន្លែងដទៃទៀតនៅអាស៊ីអាគ្នេយ៍។ ក្នុងឆ្នាំ ២០០៤ គេបានឃើញការបញ្ចប់ទៅដោយ ជោគជ័យយ៉ាងខ្លាំងក្លារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន និងអ្នកហែហមនយោបាយ និងសេដ្ឋកិច្ចរបស់គាត់ ដែលជាក្រុមបង្កើតខ្លួនឯង កើតចេញពីរចនាសម្ព័ន្ធដែលបង្កើតឡើងដោយប្រទេសវៀតណាម និងការចាប់ផ្តើមសេរីភាវូបនីយកម្មទីផ្សារនៅចុងឆ្នាំ ១៩៨០...។ រដ្ឋដែលបង្កើតឡើងប្រទេសវៀតណាមពីមុននេះ សព្វថ្ងៃមើលទៅដូចជាមានភាពសម្បើមដូចលោកខាងលិចច្រើន ប៉ុន្តែ នៅទេជាសំបកទទេរ ជាយានមួយដែលមិនល្អសម្រាប់អភិបាលកិច្ចល្អ ប៉ុន្តែ ដើម្បីបំរើផលប្រយោជន៍ លោក ហ៊ុន សែន និងបក្ខពួករបស់ខ្លួន អំពើពុករលួយ និងការបង្ក្រាប។ ជ័យជំនះមិនរួញរារបស់ពួកគេអាចសម្រេចពីនយោបាយកម្ពុជាច្រើនឆ្នាំទៅទៀត"។ (Heder, ២០០៥: ១១៨៣-១១៤) ទោះបីជាអ្នកណាម្នាក់យល់ស្រប ឬមិនយល់ស្របជាមួយ Heder ក៏ដោយ យើងនៅតែសួរថាហេតុអ្វីបានវិមជ្ឈការ ដំណើរការដែលបញ្ចេះដោយជំនួយការអភិវឌ្ឍន៏នៅថ្នាក់ឃុំ មិនត្រូវធ្វើឱ្យកើតឡើងដូច្នោះសោះ។

ជំនួសឱ្យការក្រលេកមើលរបៀបវារៈប្រកបដោយអំណាច ដោយតួអង្គសំខាន់ៗទាំងនេះ ទោះជា គណៈបក្ស ឬបុគ្គលក៏ដោយ វាអាចជាការសំខាន់ជាងក្នុងការក្រលេកមើលសក្តានុពលនៃការកសាងរដ្ឋ។ ការលេងល្បែងអំណាចដែលអាចមើលឃើញបំផុតនោះគឺបានកើតឡើងយ៉ាងច្រើននៅក្នុងទីក្រុងភ្នំពេញ។ ប៉ុន្តែ គំរោងកសាងរដ្ឋទាំងឡាយ ត្រូវតែដោះស្រាយបញ្ហាភាពស្របច្បាប់របស់រដ្ឋ នៅស្មើរគ្រប់កំរិត និងថាតើ ប្រជាពលរដ្ឋសាមញ្ញកំពុងក្រលេកមើលរដ្ឋាភិបាលដោយរបៀបណា។ "អ្នកកាន់អំណាចថ្នាក់លើរបស់សង្គមកម្ពុជា ត្រូវបានប្រជាពលរដ្ឋជនបទមើលឃើញជាប្រវត្តិសាស្ត្រថាជាសត្រូវរបស់ខ្លួន ដោយការយកពន្ធ ការយកកំរៃសេវាតូចតាច និងអំពើពុករលួយដែលកើតមានឡើង ការកេណ្ឌប្រជាជនឱ្យចូលកងទ័ពដោយបង្ខំ ឬការទាមទារឱ្យប្រជាជនធ្វើការ"ដោយស្ម័គ្រចិត្ត"។ ការចុះធ្វើការត្រួតពិនិត្យកម្មវិធី CARERE2/Seila បានបន្សល់ទុកនូវចំណាប់អារម្មណ៍យ៉ាងយូរអង្វែងពីប្រជាជននៅជនបទ ដែលអាចពិបាកនឹងប្រមើលទៅដល់ រដ្ឋមូលដ្ឋានដែលមានមេត្តា (Eastmond & Ojendal ១៩៩៩) ។ ចំនុចនេះអាចយល់បានដូចជា របបសាធារណរដ្ឋលន់ ណុល (១៩៧០-១៩៧៥)ក្លាយជារបបមិនស្របច្បាប់យ៉ាងពិតប្រាកដ របបខ្មែរក្រហម ក្លាយជារបបប្រល័យពូជសាសន៍ (១៩៧៥-១៩៧៨) របបសាធារណរដ្ឋប្រជាមានិតកម្ពុជា/រដ្ឋកម្ពុជា ជារបបផ្តាច់ការ (១៩៧៩-១៩៩២) ហើយក្រោយមកធ្វើឱ្យមានវិបត្តិដោយអំពើពុករលួយ....។ ជាទូទៅ ប្រជាពលរដ្ឋនៅតាមទីជនបទមិនចូលរួមជាមួយរដ្ឋទេ ប្រសិនបើគេអាចជៀសវាងបាន។ នៅក្រោម កាលៈទេសៈទាំងនេះ វាពិបាកនឹងធ្វើឱ្យទៅជារដ្ឋទំនើប ដោយធ្វើការងារឱ្យសកម្ម និងមានប្រសិទ្ធិភាពទៅលើ ការកាត់បន្ថយភាព-ក្រីក្រ និងដោយមានវិធីចូលរួមនោះ"។ (Rudengren ២៣) ។

Rudengren បានផ្តល់នូវការបកស្រាយដ៏ខ្លាំងក្លាមួយថាហេតុអ្វីបានជារដ្ឋាភិបាលដែលគ្រប់គ្រងដោយ CPP ដែលការអនុវត្តន៍របស់ខ្លួនឃ្លាតឆ្ងាយពីទ្រឹស្តីនៃលទ្ធិប្រជាធិបតេយ្យដែលមានការចូលរួម ដែលបានអនុញ្ញាតដល់ខ្សែទទឹងចំពោះវិមជ្ឈការ។ "ជំនួយឱ្យប្រជាធិបតេយ្យភាវូបនីយកម្ម រួមទាំង ការបោះឆ្នោតពហុបក្សមុននេះមួយចំនួន ដែលបានបង្កើត និងរក្សារបបឱ្យមានធម្មានុភាពនោះ គឺជាការប្រឈមមុខសម្រាប់ របបក្រោយពី អ៊ុនតាក់ នៅក្នុងប្រទេសកម្ពុជា។ ការទទួលបានអំណាចតាមរយៈវិធីផ្តាច់ការ កាន់តែក្លាយជាការមិនចង់បាន ដោយសារនីតិវិធីបែបប្រជាធិបតេយ្យកំពុងរីករាលដាលនៅទូទាំងប្រព័ន្ធ។ ជាការពិត ការរីក-ចំរើននេះបានបង្កើតជាបញ្ហាសម្រាបគណៈបក្សគ្រប់គ្រងអំណាច គឺគណៈបក្សប្រជាជនកម្ពុជា។ នៅដើមឆ្នាំ ១៩៩៤ ក្រសួងមហាផ្ទៃ បានទទួលការឱ្យសញ្ញាដោយការធ្លាក់ចុះអំណាចនៃរដ្ឋបាលមូលដ្ឋាន ហើយនោះ

វាគឺជាអ្វីដែលត្រូវធ្វើ (Ojendal ២០០៣)។ ដើម្បីឱ្យរដ្ឋមានភាពសកម្ម នោះគឺវាពិបាកណាស់ ជាពិសេសនៅជនបទ ដែលខ្វះធនធានសម្រាប់ធ្វើការវិនិយោគការអភិវឌ្ឍន៍ ឬគំនិតផ្តួចផ្តើមធ្វើឱ្យប្រសើរឡើងដែលស្របច្បាប់នោះ។ វាហាក់ដូចជាថា អ្នកធ្វើសេចក្តីសំរេចសំខាន់ៗនៅថ្នាក់ជាតិត្រូវបានបែងចែក ទៅតាមផ្នែក ប៉ុន្តែ នៅចុងបញ្ចប់ ផលប្រយោជន៍នៃការវិនិយោគនៅជនបទបានផ្តល់ផលកាន់តែច្រើនដល់ ភាពគ្រោះថ្នាក់ខាងនយោបាយ។ លើសពីនេះទៅទៀត គំរោងដូចជា CARERE2/Seila ដែលប្រហែលជាអាចធ្វើឱ្យរបបមានធម្មានុភាពនោះអាចតបសងទៅដល់ភាពគ្រោះថ្នាក់នៃការធ្លាក់ចុះអំណាច ដែលអាជ្ញាធរមូលដ្ឋានជាអ្នកកាន់កាប់ពីមុនមក។ (Rudengren ២០០២: ២៤)។

ជាការពិត ការលើកទឹកចិត្តខាងហិរញ្ញវត្ថុសម្រាប់កិច្ចសហប្រតិបត្តិការគឺជាការគួរឱ្យពិចារណា។ អ្វីដែលរដ្ឋាភិបាលថ្នាក់កណ្តាលត្រូវធ្វើការគិតគូរនោះគឺមិនមែនតែការគាំទ្រដល់វិមជ្ឈការនោះទេ ប៉ុន្តែ គឺការពឹងពាក់របស់ខ្លួនទៅលើម្ចាស់ជំនួយសម្រាប់ថវិកាជាតិរបស់ខ្លួន (នៅចន្លោះ ១៩៩២-២០០៣) ការបែងចែកជំនួយពីខាងក្រៅដែលមានទឹកប្រាក់សរុបចំនួន ៥, ២ កោដិ ដុល្លាអាមេរិក។ ការអំពាវនាវរកជំនួយនៅក្នុងខែធ្នូ ឆ្នាំ ២០០៤ និងខែ មីនា ឆ្នាំ ២០០៦ នៅកិច្ចប្រជុំក្រុមអ្នកពិគ្រោះយោបល់ បានទទួលជំនួយចំនួនប្រមាណ ៥០៤ លានដុល្លាអាមេរិក និង ៦០១ លានដុល្លាអាមេរិក ដាច់ពីគ្នា"។ (ការសិក្សាឯករាជ្យ ២០០៦: ៩)។ ដើម្បីយកចំនួនទាំងនេះមកធ្វើជាការរំពឹងទុក ថវិការបស់រដ្ឋាភិបាលថ្នាក់កណ្តាលសម្រាប់ឆ្នាំ ២០០៥ មានចំនួន ៨១២ លានដុល្លាអាមេរិក ដែលក្នុងនោះថវិកាចំនួន ៦៤២ លានដុល្លាអាមេរិកគឺជាចំណូលប្រចាំឆ្នាំ ឯថវិកាចំនួន ២៧៣ លានដុល្លាអាមេរិកបានមកពីជំនួយបរទេស។ តុល្យភាពនៅក្នុងថវិកាជំនួយបរទេសបានប្រើប្រាស់សម្រាប់គំរោងអភិវឌ្ឍ។ ថវិកាភាគច្រើនត្រូវបានបែងចែកដោយរដ្ឋាភិបាល ដែលថវិកាជាតិចំនួន ២,៥ ភាគរយប៉ុណ្ណោះបានដល់ឃុំ។

ការធ្វើឱ្យឃុំជាមជ្ឈមណ្ឌលនៃ ភាពស្រួចស្រាវលើដំណើរការវិមជ្ឈការដែលកំពុងតែចាប់កំណើតឡើង ត្រូវបានជាប់ពាក់ព័ន្ធជាមួយភាពគ្រោះថ្នាក់គួរឱ្យពិចារណា។ "តួនាទីចំបងសម្រាប់រដ្ឋអំណាចឃុំនៅអំឡុង ពេលសង្គ្រាមស៊ីវិល គឺដើម្បីប្រើប្រាស់ការត្រួតពិនិត្យនយោបាយផ្ទៃក្នុង និងការរៀបចំការការពារដោយ កងឈ្លបតាមមូលដ្ឋាននៅក្នុងអំឡុងពេលលទ្ធិនយោបាយផ្តាច់ការ។ ដោយសារតែមេឃុំត្រូវបានតែងតាំងដោយអាជ្ញាធរខាងលើ ហើយតួនាទីរបស់ពួកគេរួមមានទាំងកំលាំងផងនោះ អាជ្ញាធរឃុំមិនមានប្រជាប្រិយភាព

ខ្លាំងក្លានោះទេ នៅក្នុងចំណោមប្រជាពលរដ្ឋ។ បន្ថែមលើនេះទៅទៀត មេឃុំអនុវត្តតាមយុទ្ធសាស្ត្រ និងវិធីជាមួយនឹងការអភិវឌ្ឍន៍ដែលមានការចូលរួមតិចតួច"។ (Rudengren ២០០២: ៤២-៤៣)។ "នៅក្នុងពេលដែលវាត្រូវបានគេទទួលស្គាល់ថា ថ្នាក់ស្រុកអាចបង្កើតជារដ្ឋាភិបាលហិរញ្ញវត្ថុមូលដ្ឋានកាន់តែខ្លាំងនោះ ហើយក៏ផ្តួចផ្តើមដំណើរការ "ចែករំលែកពីលើមកក្រោម" ជាជាង"ការបង្កើត" រចាំងរដ្ឋបាល រាជរដ្ឋាភិបាលជឿថាថ្នាក់ឃុំគួរបង្កើតអង្គភាពតូចៗ និងដែលមានស្ថេរភាព ក្រោយពីសង្គ្រាមស៊ីវិលច្រើនទស្សវត្សមកនេះ។ (CDRI, FORDC ២០០៣: ៣)។ នៅក្នុងពេលដែលមានការចែករំលែកអំណាចខ្លះៗរវាងគណៈបក្សធំៗទាំងបី គណៈបក្សប្រជាជនបានបញ្ចប់ការគ្រប់គ្រងរបស់ខ្លួនទៅលើនយោបាយភូមិ។

វិមជ្ឈការដែលមានការត្រួតត្រានៅថ្នាក់ទាបបំផុតនៃរដ្ឋាភិបាល គឺជាការពេញចិត្តបំផុតចំពោះ CPP ។ កេរ្តិ៍ដំណែលដែលបានមកពីអំឡុងពេលត្រួតត្រាដោយវៀតណាមយ៉ាងយូរ គឺការគ្រប់គ្រងទៅលើភូមិ។ ការគ្រប់គ្រងនេះគឺបានបង្កលក្ខណៈឡើងដោយរចនាសម្ព័ន្ធបក្សលេនីនរបស់ CPP ដែលមកទល់ពេលនេះ បានជ្រាបចូលដល់ថ្នាក់ភូមិ។ ការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់ ឆ្នាំ ២០០២ បានបង្ក លក្ខណៈឱ្យ CPP ពង្រឹងការគ្រប់គ្រងរបស់ខ្លួនដល់ថ្នាក់ឃុំភ្លាម។ CPP បានឈ្នះការបោះឆ្នោតជ្រើសរើស សមាជិកក្រុមប្រឹក្សាឃុំ/សង្កាត់យ៉ាងច្រើន ដោយទទួលបានសំលេងឆ្នោត ៦២ ភាគរយ ទទួលបានអាសនៈ ៦៨ ភាគរយនៃអាសនៈទាំងអស់ និង ៩៧ ភាគរយនៃការិយាល័យកំពូលៗ (St. John ២០០៥: ៤១៣)។ ហេតុនេះ មិនមែនជាការចៃដន្យនោះទេដែល CPP ទទួលបានអាសនៈលើសពីពាក់កណ្តាល នៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ឆ្នាំ ២០០៣។ គណៈបក្សជំទាស់បានដឹងពីបញ្ហានេះ។ "សម្ព័ន្ធអ្នកប្រជាធិបតេយ្យ គឺសម្ព័ន្ធភាពរបស់ FUNCINPEC និង SRP ឆ្នាំ ២០០៣ ក៏បានទាមទារឱ្យបង្កើតគណៈកម្មាធិការភូមិ ដោយមានតំណាងស្មើគ្នាមកពីគណៈបក្សទាំងបី។ ចំនុចនេះបានបញ្ជាក់ពីជំនឿរបស់ AD ដែលថា គណៈកម្មាធិការភូមិដែលមានស្រាប់ ដែលគណៈកម្មាធិការភូមិទាំងអស់នេះត្រួតត្រាដោយ CPP តាំងតែពីឆ្នាំ ១៩៧៩ មក បានដើរតួយ៉ាងសំខាន់នៅក្នុងការស្រូបទាញលទ្ធផលឆ្នោត ដែលជាការពេញចិត្តរបស់ CPP ។

មិនមែនគ្រប់អ្នកវិភាគទាំងអស់សុទ្ធតែមិនសប្បាយចិត្ត ចំពោះតួនាទីរបស់គណបក្សនយោបាយនោះឡើយ។ "សេចក្តីសំរេចចិត្តបែបនយោបាយរបស់ក្រសួងមហាផ្ទៃ ដើម្បីយកវា (វិមជ្ឈការ) ទៅដាក់នៅថ្នាក់ឃុំ គឺជាការពិចារណាមួយធ្វើឡើងដោយប្រុងប្រយ័ត្នបំផុតដោយរដ្ឋាភិបាល ដើម្បីអោយវា

បានចាក់ឫសចាក់គុល ដោយមើលឃើញពីពីតម្រូវការនៃការបង្កើតអង្គភាពមួយតូច មានស្ថេរភាព នៅក្រោយសង្គ្រាមស៊ីវិល ដែលនេះជាការនាំយកការធ្វើសេចក្តីសំរេចចិត្តកាន់តែកៀកទៅនឹងប្រជាពលរដ្ឋ។ ផ្នែកដ៏មានសារសំខាន់នៃការព្យាយាមបង្កើតស្ថេរភាព គឺជាតម្រូវការក្នុងការពង្រឹងលិទ្ធ-ប្រជាធិបតេយ្យ តាមរយៈការបង្កើនកិច្ចសហការរបស់គណបក្សនយោបាយនានា។ រដ្ឋាភិបាលមានគំនិតយល់ឃើញថា កិច្ចសហការរវាងគណបក្សនយោបាយនៅថ្នាក់ឃុំ នឹងបង្កើនការយោគយល់គ្នា និងកិច្ចសហការ និងកាត់បន្ថយអំពើហិង្សាដែលកើតចេញដោយសាររឿងនយោបាយ”។ (Rusten, 2005: 88) ។ ខណៈដែលលក្ខខណ្ឌតម្រូវរបស់អន្តរគណបក្សនយោបាយនៃការបង្កើតអោយមានសន្តិភាព ត្រូវបានធានាចំពោះតំណែងជាអនុប្រធានទីពីរ និងទីបីនៅក្នុងក្រុមប្រឹក្សាឃុំ របស់គណ-បក្សប្រឆាំងក៏ដោយ ក៏ការត្រួតត្រារបស់ CPP នៅតែធំធេង។ សូម្បីមនុស្សខ្លះក៏ហ៊ានប្រកែកថា ការបោះឆ្នោត និងដំណើរការរបស់ឃុំ បានផ្តល់លទ្ធភាពអោយ CPP បានធ្វើការបង្រួបបង្រួមឡើងមកដល់កំរិតនេះ។

ហេតុផលមួយផ្សេងទៀតដែលថាហេតុអ្វី បានជាវិវជននយោបាយ មកទល់ពេលនេះទៅហើយនៅតែទុកចោលអោយការងារវិមជ្ឈការអោយនៅតែម្នាក់ឯង គឺដោយសារថា ការតស៊ូដើម្បីត្រួតត្រាលើធនធានសេដ្ឋកិច្ច - ការរត់ប្រណាំងខាងដីធ្លី លទ្ធភាពទទួលបានទឹកស្រោចស្រប ការតវ៉ាក្នុងរឿងនេសាទ និងព្រៃឈើ ទាំងអស់នេះសុទ្ធតែស្ថិតនៅក្រៅគំរោងសកម្មភាពដែលអាចធ្វើបានរបស់ក្រុមប្រឹក្សាឃុំ។ “នៅទីកន្លែងផ្សេងៗទៀត ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យបានយកចិត្តទុកដាក់នៅពេលខាងមុខជុំវិញ ថាតើរដ្ឋនឹងធ្វើយ៉ាងលើបញ្ហាច្បាប់របស់មូលដ្ឋាន ការប្រណាំងប្រជែង និងការការពារសិទ្ធិដោយរបៀបណា បង្កលទ្ធភាពចំពោះ និងការពារសន្តិសុខទៅលើសិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិសំរាប់ការចិញ្ចឹមជីវិតរស់នៅ (ដីធ្លី ទឹកសំរាប់ស្រោចស្រប ធនធានធម្មជាតិ ។ល។) ដែល *ទាមទារ* តាមរយៈសកម្មភាពផ្នែកនយោបាយ ប៉ុន្តែ *ដោះស្រាយ* តាមរយៈបទដ្ឋានរដ្ឋបាល។ មានចំណាប់អារម្មណ៍មួយធ្វើឡើងដោយសមាជិកក្រុមប្រឹក្សាឃុំ នៅក្នុងឃុំឈ្មោះ គំរូ ខេត្តបន្ទាយ-មានជ័យ បង្ហាញថា គណនេយ្យភាពរបស់ថ្នាក់ក្រោមជាតិអាចនិយាយច្រើនជាងហ្នឹងទៅទៀត។ គាត់និយាយថា “វិមជ្ឈការ” គឺសំដៅទៅលើតែការធ្វើផែនការអភិវឌ្ឍន៍ប៉ុណ្ណោះ។ សំរាប់ការងារដែលខ្លួនមិនពាក់ព័ន្ធជាមួយ មានដូចជាមន្ត្រីខាងព្រៃឈើ ឬនេសាទ ឬខាងគ្រប់គ្រងដីធ្លីជាដើម កិច្ចការរបស់គេគឺធម្មតា គេធ្វើការងារតែគេទៅ”។ (ការសិក្សាឯករាជ, ២០០៦:៣៨)។

ជាងាយស្រួលទេសំរាប់អាជ្ញាធររបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីយល់ព្រមទៅលើការងារវិមជ្ឈការ ដោយសារថា វាប្រតិបត្តិការនៅក្រោមកំរិតមណ្ឌល។ ក្នុងខណៈដែលយើងមិនអាចស្មានបានជាលើកទីពីរចំពោះអ្នកនៅផ្ទាល់នឹងការងារនោះ ប៉ុន្តែបើមើលពីចម្ងាយវាហាក់ដូចជាបង្ហាញអោយឃើញថា មានការងារជាច្រើនទៀតសំរាប់ម្ចាស់ជំនួយត្រូវធ្វើ ដើម្បីជំរុញដំណើរការវិមជ្ឈការ និង វិសហមជ្ឈការ។ តាមពិត បញ្ហានេះ មិនអាចដោះស្រាយបានទេ ប្រសិនបើគេធ្វើបន្តមកដោយពឹង-ផ្អែកទៅលើឥទ្ធពលអវត្តមានខាងផ្នែកនយោបាយ។ ម្យ៉ាងវិញទៀត ម្ចាស់ជំនួយក៏ត្រូវមានគណ-នេយ្យសំរាប់ផ្នែករបស់ខ្លួន។ "បញ្ហានៃការសម្របសម្រួលរបស់ម្ចាស់ជំនួយ កើតឡើងជាញឹកញាប់នៅប្រទេសកម្ពុជា មានមិនតិចដែរទេ ដោយសារនិន្នាការជាទូទៅមួយសំរាប់ម្ចាស់ជំនួយ ក្រៅពីមិនបានធ្វើក្នុងលក្ខណៈប្រគួតប្រជែងគ្នានៅតាមផ្នែកវិស័យខ្លះៗ និង ជួយលើកទឹកចិត្តដល់រដ្ឋាភិបាលខ្លួនបែរជាដាក់កំរិតទៅលើនិន្នាការទាំងនេះទៅទៀត"។ (Rudengren, 2005: 38) ។

ការសិក្សាឯករាជបានធ្វើការកាត់សេចក្តីមានលក្ខណៈធ្វើអោយវិនាស ពាក់ព័ន្ធនឹងផលប៉ះពាល់របស់ម្ចាស់ជំនួយជាទូទៅ។ វាសំខាន់ណាស់ដើម្បីដកស្រង់អោយបានច្រើនចេញពីសេចក្តីសន្និដ្ឋានរបស់វា ពីព្រោះថា បើនិយាយពីលក្ខណៈផ្លូវការរបស់វា វាជាឯកសាររបស់រដ្ឋាភិបាល ទោះបីឯកសារនេះបានធ្វើឡើងដោយទីប្រឹក្សាបរទេសក៏ដោយ។

"*...ដោយមានការលើកលែងខ្លះៗ* "របៀបរបប" (គោលនយោបាយ ប្រព័ន្ធធ្វើផែនការ និងហិរញ្ញ-វត្ថុ) បច្ចុប្បន្នបាននឹងកំពុងធ្វើការដោយរដ្ឋាភិបាល និងម្ចាស់ជំនួយនៅថ្នាក់ក្រោមជាតិ មានប្រសិទ្ធិ-ភាពទៅលើការធ្វើអោយអន្តរាយដល់គណនេយ្យភាពជាបឋម របស់មេដឹកនាំនៅថ្នាក់មូលដ្ឋានដែលជាប់ឆ្នោតតាមការបោះឆ្នោតរបស់ប្រជាពលរដ្ឋ ហើយនឹងធ្វើអោយរដ្ឋបាលឯកភាពមានការលំបាកយ៉ាងចម្លែកខុសគេ។ ដរាបណារបៀបរបបដែលមានសព្វថ្ងៃនេះ មិនបានធ្វើការកែប្រែជាមូលដ្ឋានទេនោះ លទ្ធភាពនៃនយោបាយឆ្លើយតបទៅនឹងតម្រូវការរបស់ពលរដ្ឋនៅមូលដ្ឋាន យើងជឿថាពិតជានៅឆ្ងាយយ៉ាងដាច់សង្វែង។ ប្រព័ន្ធសព្វថ្ងៃជំរុញអោយមានវិមជ្ឈការនយោបាយ វិមជ្ឈការរដ្ឋ-បាល និងវិមជ្ឈការសារពើពន្ធ ឬអាចនិយាយតាមភាសាម្យ៉ាងទៀតថា កិច្ចការទាំងអស់នេះនឹងរួមគ្នាដើម្បីធានាថា ធនធានសំរាប់ផ្តល់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋក្រីក្រភាពច្រើននៃកម្ពុជា ពិតជា

ចាប់យកមកបាន បង្វែរ និងបើមិនដូច្នោះទេ នឹងត្រូវបានប្រើប្រាស់ដើម្បីពង្រឹងទៅលើបេតិកភ័ណ្ឌ ដែលជាញឹកញាប់ មិនត្រូវបានគេពិចារណាសំរាប់ផលប្រយោជន៍របស់ខ្លួន"។ (ការសិក្សាឯករាជ, ២០០៦: xi) ។

បន្ទាប់មកទៀត ការសិក្សាឯករាជបានពន្យល់ជាបន្ថែមទៀតអំពីបរាជ័យនៃការពង្រីកការដាក់កំរិតទៅលើការងារវិមជ្ឈការ និងវិសហមជ្ឈការ ដែលងាយនឹងទទួលអំពើពុករលួយ ដោយនិយាយថា "...ចំណែកដ៏ធំនៃ "កិច្ចការអភិបាលកិច្ច" នៅក្នុងប្រទេសកម្ពុជា កើតឡើងតាមប្រព័ន្ធបរិបាលកិច្ច ដែលមិនធ្វើប្រតិបត្តិការ "ទន្ទឹមគ្នា" ច្រើនប៉ុន្មានទេជាមួយនឹងប្រព័ន្ធផ្លូវការ ប៉ុន្តែបានបញ្ចូលយ៉ាងល្អត្រឹមត្រូវទៅក្នុងប្រព័ន្ធទាំងនេះ។ ការយល់ដឹងអំពីរបៀបរបបការងាររបស់រដ្ឋាភិបាល តាមការអនុវត្តន៍ជាក់ស្តែង ជាការសំខាន់ណាស់ ដូចគ្នានឹងការយល់ដឹងពីរបៀបរបបដែលម្ចាស់ជំនួយធ្វើការរបស់គេផងដែរ។ កំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ នៅក្នុងប្រទេសជាច្រើន ត្រូវបានតទល់ប្រឆាំងទ្រឡប់មកវិញ ដោយសារតែការងារទាំងពីរខាងលើនេះ អាចគំរាមកំហែង និងរំខានដល់ទីតាំងការពារប្រព័ន្ធបរិបាលកិច្ចរបស់គេ ចាប់ពីថ្នាក់ខ្ពស់បំផុត រហូតដល់ថ្នាក់និយោជិតផ្នែកព្រៃឈើ និងសុខភាព ចាប់ពីប្រធានគ្រូបង្រៀនរហូតដល់អធិការកិច្ចផ្នែកសុខភាពសាធារណៈ។ ប៉ុន្តែវាញឹក-ញាប់ពេកណាស់ដែលថា កំណែទំរង់វិមជ្ឈការមិនមែនប្រឆាំងដោយសារតែហេតុផលសាមញ្ញនោះទេ គឺដោយសារតែប្រព័ន្ធនេះហាក់ដូចជាមានភាពលំអៀងក្នុងការអនុវត្តន៍ អញ្ចឹងហើយបានជាកំណែទំរង់វិមជ្ឈការអាចផ្តល់នូវឱកាសជាច្រើនឱ្យមានអំពើពុករលួយនៅមូលដ្ឋាន ឬការប្រើប្រាស់ធន ធានមិនបានត្រឹមត្រូវ ដែលនេះជាសញ្ញាសំគាល់នៃប្រព័ន្ធរដ្ឋាភិបាលដែលទើបនឹងកើតថ្មី"។ (ការសិក្សាឯករាជ, ២០០៦: ទំព័រ៣)។

អត្ថប្រយោជន៍ដ៏សំខាន់របស់ម្ចាស់ជំនួយគឺធ្វើយ៉ាងណាអោយគំរោងរបស់គេត្រូវបានអនុវត្ត និងអាចរាយការណ៍អំពី ផលប៉ះពាល់ដែលអាចវាស់វែងបាន។ បញ្ហាគឺថា តាមបរិបទរបស់ប្រទេសកម្ពុជា ស្ថាប័ននយោបាយនៅទន់ខ្សោយនៅឡើយ កង្វល់នេះនាំឱ្យម្ចាស់ជំនួយចាប់យកផ្លូវកាត់បែបរដ្ឋបាលខុសៗគ្នា ដែលក្នុងនោះមានតាំងការចាត់ចែងតាម "បំណងពិសេស" នៅក្នុងការអនុវត្តគំរោង រាប់ចាប់ពីការធ្វើផែនការ រហូតដល់របៀបនៃការបែងចែកគណនេយ្យភាពនៃការអនុវត្តន៍។ នៅខណៈដែលកម្មវិធីនានារបស់ម្ចាស់ជំនួយគ្មានការប្រែប្រួលក្នុងការបាញ់ព្រួញទៅលើអំពើពុករលួយ ហើយ

និងប្រព័ន្ធបរិបាលកិច្ចជាច្រើនទៀត រចនាសម្ព័ន្ធលើកទឹកចិត្តរបស់ម្ចាស់ជំនួយដែលនាំអោយខូចដល់ការងារផ្សេងទៀត បានជួយជំរុញអោយមានទម្រង់ថ្មីនៃបរិបាលកិច្ចដោយធ្វេសប្រហែស និងកាត់បន្ថយកាន់តែតិចនូវការលើកទឹកចិត្ត ក្នុងការកែតម្រូវបេតិកភ័ណ្ឌដែលមានស្រាប់។ នៅក្នុងដំណើរ-ការវិញ ប្រព័ន្ធគាំទ្រពីខាងក្រៅបានជួយពន្លឿន*ការងាររដ្ឋបាល* ដែលមានប្រភេទនៃគណនេយ្យភាពខ្លះៗ ដែលនៅក្នុងនោះបានជួយជាមធ្យោបាយដល់ការអភិវឌ្ឍន៍គណនេយ្យភាព *ខាងនយោបាយ* ។ សមាជិកក្រុមប្រឹក្សាឃុំដែលជាប់ឆ្នោត មានកង្វល់ច្រើនជាមួយនឹងការបំពេញលក្ខខណ្ឌតម្រូវរបស់ម្ចាស់ជំនួយ ជាងការបារម្ភអំពីអ្វីដែលអ្នកបោះឆ្នោតរបស់ខ្លួនបាននឹងកំពុងគិត”។ (ការសិក្សាឯករាជ, ២០០៦:៧)។

បទពិសោធន៍របស់ក្រុមប្រឹក្សាឃុំ នៅក្នុងការងារអភិវឌ្ឍន៍ គឺជាបទពិសោធន៍នៃការអនុវត្តន៍ជាក់-ស្តែងតាមបែបប្រជាធិបតេយ្យ មិនថាអង្គភាពនេះស្ថិតក្នុងកំរិតមណ្ឌលបែបណាក៏ដោយ។ សមាគមសមាជិកក្រុមប្រឹក្សាឃុំ ដែលបាននឹងកំពុងធ្វើការបង្កើតក្នុងខណៈស្វែងរកប្រភេទនៃការធ្វើទំនាក់ទំ-នងម្យ៉ាងដែលមានលក្ខណៈជាខ្សែទទឹង ដែលទំនងទំនងបែបនេះអាចនឹងជួយដល់ពួកគេក្នុងការដាក់សម្ពាធពីខាងក្រោមទៅវិញ ហើយដែលមកទល់ពេលនេះដំណើរការបែបនេះភាគច្រើន ត្រូវបានគេធ្វើពីលើមកក្រោម។ ប៉ុន្តែការងារនេះត្រូវប្រើពេលមួយរយៈ ដើម្បីធ្វើអោយជ្រួតជ្រាបទៅដល់ថ្នាក់កំពូល ដោយសារអ្វីដែលសំខាន់នៃប្រព័ន្ធនយោបាយតាមបែបអំណាចនិយម។ នេះដោយសារលទ្ធ-ផលមួយចំណែកកើតចេញពីសេចក្តីសំរេចចិត្តរបស់ម្ចាស់ជំនួយ។ ការទម្លុះចូលនៃ វិមជ្ឈការតាម-បែបចូលរួម ត្រូវបានសម្រុះសម្រួលដើម្បីប្តូរយកឥទ្ធិពលផ្នែកគោលនយោបាយនៅថ្នាក់ជាតិ ក្នុងក្តី-សង្ឃឹមថា នៅភ្នំពេញ ឥទ្ធិពលអាចនឹងបង្កើតបាននូវលទ្ធផលនៅក្នុងការផ្លាស់ប្តូរប្រព័ន្ធ និង រចនា-សម្ព័ន្ធ។ ដំណើរការធ្វើសេចក្តីព្រាងច្បាប់រៀបចំអង្គការ ដែលបានចាប់ផ្តើមពីរឆ្នាំមកហើយជាមួយនឹងឯកសារយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ ផ្តល់នូវកាលានុវត្តភាពជាច្រើនសំរាប់ដាក់ឥទ្ធិ-ពលអោយមានការផ្លាស់ប្តូរផ្នែកប្រព័ន្ធ និងរចនាសម្ព័ន្ធ។

ជាអកុសល ការកៀរគរភាគីដែលចាប់អារម្មណ៍នៅក្នុងដំណើរការនេះ រួមទាំងអង្គការមិនមែនរដ្ឋាភិបាលផងដែរ នៅមានកំរិតនៅឡើយ។ នៅកម្ពុជា មានអង្គការមិនមែនរដ្ឋាភិបាលជាង១០០០ បានចុះបញ្ជីត្រឹមត្រូវ ហើយដែលមួយចំនួនធំត្រូវបានចាត់ចូលក្នុងប្រភេទជា អង្គការអនុវត្ត។ អង្គការ

មិនមែនរដ្ឋាភិបាលទាំងនេះ ជាទូទៅត្រូវបានបង្កើតឡើងក្រោមជំនួយរបស់ស្ថាបនិកដើម (បរទេស) ឬទីភ្នាក់ងារម្ចាស់ជំនួយ អញ្ចឹងទេ គេអាចនិយាយបានថា ជាអង្គការមិនមែនរដ្ឋាភិបាលដែលបានគេណែនាំបង្កើតឡើង ជាជាងអង្គការក្រៅរដ្ឋាភិបាលអន្តោគ្រាម។ ទស្សនៈអំពី ការស្ម័គ្រចិត្តជាប្រពៃណី របស់អង្គការមិនយកប្រាក់កំរៃ ត្រូវបានអវត្តមានជាញឹកញាប់ ហើយអាចចាប់កំណើតឡើងវិញបានប្រសិនបើប្រឹងប្រែងអោយបានខ្លាំងក្លា (Civil Soc និង Democ: 8-9)។ ការពិតដែលថា CSOs មានផលប៉ះពាល់នោះមិនគួរគេបកស្រាយថា ជាសញ្ញានៃសង្គមស៊ីវិលដ៏ខ្លាំងនោះទេ។ ផលប៉ះពាល់គឺជាសារសញ្ញាវត្តមានរបស់សហគមអន្តរជាតិដ៏ខ្លាំង និងស្ថាប័នសាធារណៈដ៏ទន់ខ្សោយ។ នៅក្នុងឆាកនយោបាយ មធ្យោបាយដ៏មានសារសំខាន់មួយដែលសង្គមស៊ីវិលមានផលប៉ះពាល់ គឺការបំរើសេវាកម្មអោយសហគមអន្តរជាតិលើវិស័យព័ត៌មាន ដែលម្ចាស់ជំនួយ និងអ្នកដទៃទៀតអាចប្រើប្រាស់ក្នុងការពិភាក្សាជាមួយរដ្ឋាភិបាល។ (Civil Soc និង Democ 17)។

ការជួសម្រួលនេះគឺជាការចាំបាច់ ពីព្រោះថា "នៅកម្ពុជា អភិបាលខេត្តជាច្រើនមានគំនិតថា អ្នកនយោបាយមូលដ្ឋានត្រូវមានគណនេយ្យភាពចំពោះគណបក្សរបស់គេ ជាជាងរដ្ឋាភិបាល ឬសាធារណៈជន។ បញ្ហានេះដោយសារតែខ្សែមិនច្បាស់លាស់នាពេលបច្ចុប្បន្នរវាងការត្រួតត្រាឯកជន និងសាធារណៈ និងដោយសារអំណាច ហើយនឹងធនធានឋិតនៅក្រោមគណបក្សនយោបាយសំខាន់ៗជាជាងនៅជាមួយនឹងរដ្ឋាភិបាលដោយខ្លួនឯង។ ជាការបន្ថែមទៅលើបញ្ហានេះ ខ្សែគណនេយ្យភាពត្រូវបានគាំទ្រតាមគំរូនៃការបង្កើតច្បាប់បោះឆ្នោត" (ជំពូក III, ទំព័រ 42-43)។ ការបង្កើតដែលមានក្នុងពេលបច្ចុប្បន្ន មិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីបំបែកការពិតទាំងនេះបានទេ។ ប៉ុន្តែ កិច្ចប្រឹងប្រែងជាបន្តបន្ទាប់ដើម្បីបង្កើតសមាគមន៍សមាជិកក្រុមប្រឹក្សាឃុំ និងដើម្បីផ្តល់មូលនិធិសំរាប់ការធ្វើផែនការអភិវឌ្ឍន៍តាមបែបចូលរួម ក្នុងចំណោមឃុំនានា អាចជាដំណើរការដ៏វែងមួយឆ្ពោះទៅរកកំណើននៃការបង្រួបបង្រួមតាមបែបវិមជ្ឈការនៅថ្នាក់ឃុំ និងបង្កើតបានជាសម្ពាធបន្ថែមទៀតសំរាប់ការធ្វើវិមជ្ឈការពិតប្រាកដនៅថ្នាក់ស្រុក និងថ្នាក់ខេត្ត។

មានការវាយតម្លៃជាច្រើនលើការងារវិមជ្ឈការនៅប្រទេសកម្ពុជាដោយបានចង្អុលបង្ហាញនូវបញ្ហាដ៏សំខាន់ៗទាំងអស់នេះ។ ជាការពិតណាស់ដែលថា ការលំបាកដ៏ធំធេង គឺស្ថិតនៅក្រោមចន្លោះប្រហោងដ៏ធំមួយរវាងការប្តូរបាច់លើការងារវិមជ្ឈការ និងការអនុវត្តន៍ជាក់ស្តែងនៃក្រុមអ្នកនយោ-

បាយដែលមានអំណាចលើគេ ជាសំខាន់បំផុតនោះគឺ CPP។ ដូចអ្នកវិភាគម្នាក់ (គឺ Heder, Theater, 12) សរសេរថា "ជាលទ្ធផល គឺជាប្រព័ន្ធនយោបាយមួយដែលយកតាមនីតិវិធីតាមបែបប្រជាធិប-តេយ្យ និងដោយមានការចូលរួមយ៉ាងរស់រវើកនៃសង្គមស៊ីវិល ប៉ុន្តែនោះគឺជាប្រព័ន្ធម្យ៉ាងដែលពុំមានផលប៉ះពាល់ ឬមានផលប៉ះពាល់តិចតួចប៉ុណ្ណោះ ដើម្បីលើកឡើងពីដំដោះស្រាយបញ្ហាអំពើ-ពុករលួយដ៏ធំធេង និងការរំលោភបំពានអំណាច។ ហើយវាក៏ជាប្រព័ន្ធដែលងាយរងគ្រោះទៅនឹងអំពើហិង្សាផ្នែកនយោបាយផងដែរ នៅពេលណាដែលបុព្វសិទ្ធិនយោបាយ និងសេដ្ឋកិច្ចរបស់វរជនត្រូវទទួលរងការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរនោះ។

នៅក្នុងប្រព័ន្ធបែបនេះ សភាមានការយកចិត្តទុកដាក់តិចតួច ហើយចំណែកច្បាប់ និងតុលាការគឺជាឧបករណ៍នៃអំណាច និងទឹកប្រាក់។ អស់ពេលជាច្រើនមកហើយ ដែលប្រព័ន្ធនេះបង្កើតនូវស្ថាប័ននៃរបបមួយដែលពឹងផ្អែកទៅលើការស្រកចុះនៃទម្រង់អំពើហិង្សាកំរិតខ្ពស់ និងដែលគេស្រគៀវត្រ-ជៀកជាយូរមកហើយ ប៉ុន្តែនៅតែមានសំរាប់ជាជំរើសចុងក្រោយបង្អស់ ដូចជាដំណើរការបោះ-ឆ្នោតត្រូវបានគំរាមកំហែងមិនចូលក្នុងអាសនៈសភាពជាដើម។ ដំណើរការនេះបានធ្វើបញ្ចប់នូវការផ្លាស់ប្តូរពី ការិយាធិបតេយ្យបែបកុម្មុយនីស្ត មកជាឱពុកធម៌នៃបណ្តាញជិតស្និតនឹងនាយទុននៃអ្នកមានថ្មីដ៏មហិមា ដែលជាសំណុំនៃអ្នកបច្ចេកាធិបតេយ្យ អ្នកអនុវត្ត អ្នកមាន ស្រីលួចលាក់ដែលបំរើអោយតម្រូវខុសៗគ្នា និងផ្គាប់ផ្គន់ផ្សេងៗទៀត។ សមាជិកនៃសំណុំមនុស្សទាំងនេះបានក្លាយជាអគ្គាគាហកដ៏ស្មោះស្ម័គ្រទៅតាមមធ្យោបាយដែលរដ្ឋស្រមោល និងបណ្តាញសេដ្ឋកិច្ចធ្វើការពង្រឹងខ្លួនឯង ដោយរក្សាការរត់គេចចេញពីកិច្ចប្រឹងប្រែងក្នុងស្រុក និងអន្តរជាតិ ក្នុងការបង្កើតប្រព័ន្ធនយោ-បាយ និងសេដ្ឋកិច្ចប្រកបគណនេយ្យភាព និងតម្លាភាព"។

ជាការពិតណាស់ដែលថា ម្ចាស់ជំនួយ និងទីប្រឹក្សាអន្តរជាតិមិនអាចធ្វើបានដោយខ្លួនឯងទេ ហើយក៏មិនចង់សាកល្បងដែរ។ ការផ្លាស់ប្តូរនយោបាយពិតប្រាកដនឹងចូលមកបាន ដរាបណាកម្លាំងនយោបាយដ៏ខ្លាំងក្លាគ្រប់គ្រាន់មួយត្រូវបានបង្កើតឡើង ដើម្បីប្រឈមជាមួយនឹងការត្រួតត្រារបស់គណ-បក្សប្រជាជនកម្ពុជា។ ជាអកុសល ការអនុវត្តន៍ជាក់ស្តែងរបស់គណបក្សប្រឆាំងមិនមែនមានលក្ខ-ណៈជាប្រជាធិបតេយ្យទៀតទេ ហើយពួកគេមានលទ្ធភាពខ្សោយជាង CPP យ៉ាងខ្លាំង។ កិច្ចការរបស់ម្ចាស់ជំនួយគឺ ជួយធ្វើអោយមានលក្ខខណ្ឌប្រសើរឡើងសំរាប់ការប្រឆាំងប្រកបដោយគោល-

ការណ៍ និងសមត្ថភាព ដើម្បីបង្កើត និងទទួលបានការគាំទ្រសំរាប់ការកែទំរង់ និងដើម្បីធ្វើការងារប្រកបដោយការសំរេចចិត្តច្រើនជាងមុន។ សំរាប់អ្នកចាប់ផ្តើម ពួកគេអាចស្តាប់ និងធ្វើអ្វីម្យ៉ាងទៅលើការរិះគន់អំពី មធ្យោបាយដែលគំរោងរបស់ខ្លួនអាចចែករំលែកទៅក្នុងទម្រង់ថ្មីនៃអំពើពុករលួយ និងនយោបាយបេតិកភ័ណ្ឌ ដូចគ្នានឹងការធ្វើចំពោះការងារកំណែទំរង់ដែរ។ មានកិច្ចការច្រើនទៀតដែលត្រូវធ្វើដើម្បីធ្វើអោយម្ចាស់ជំនួយ និងសង្គមស៊ីវិលចូលរួមជាមួយគ្នា ប្រសិនបើគ្មានអ្វីផ្សេងត្រូវបង្កើនទៅលើភាពស្របច្បាប់នៃការតស៊ូមតិរបស់ម្ចាស់ជំនួយទេនោះ។ កិច្ចគាំទ្ររបស់ម្ចាស់ជំ-នួយដើម្បីការអភិវឌ្ឍន៍សង្គមស៊ីវិល អាច និងគួរតែត្រូវបង្កើន។ ដោយរួមគ្នាជាមួយនឹងអ្នកកែទំរង់សំខាន់ៗនៅក្នុងរាជរដ្ឋាភិបាលកម្ពុជា វាគួរតែអាចជំរុញអោយបានខ្លាំងបន្ថែមទៀតទៅលើដែនកំណត់វិមជ្ឈការ ដើម្បីបង្កើនអោយបានជាអតិបរមានូវផលប៉ះពាល់នៃការធ្វើលិទ្ធិប្រជាធិបតេយ្យភាវូបនីយកម្ម និងដើម្បីជំរុញទ្វាលទ្ធិប្រជាធិបតេយ្យអោយបើកចំហរកាន់តែធំទូលាយថែមទៀត”។

## <u>សំរាប់អាន</u>


Biddulph, Robin, 2003. “Pat ការសិក្សាអំពីការផ្តល់អំណាច – របាយការណ៍ចុងក្រោយ’,

ដាក់ជូនទៅ Pierre Landell-Mills

និង Jan Rudengren of the DFID/Sida Permanent Advisory Team on the Seila Programme and
Scott Leiper of the Partnership for Local Governance Project, 15 November 2003

Biddulph, Robin, “ការបង្វែរវិមជ្ឈការមកក្នុងទឹកដីកម្ពុជា”, in Michael H. Nelson, **Thai Politics: Global and Local Perspectives**, King Prajadhipok's Institute, Bangkok, 2004.

Biddulph, Robin, 2006, “Through the Looking Glass: The Seila (2002-2005) Story As Told By Fifty-Three Consultant’s Reports, A Literature Survey”, DFID/Sida Permanent Advisory Team on the Seila Programme, 3 February 2006

CDRI (វិទ្យាស្ថានស្រាវជ្រាវការអភិវឌ្ឍន៍កម្ពុជា), “កម្មវិធីស្រាវជ្រាវតម្រង់ទិសដៅផ្នែកគោលនយោបាយ ស្តីពី ការងារវិមជ្ឈការ (PORDEC), Inception Report, June 24, 2003

ឯកសារគំរោង EU-UNDP – ផែនការសកម្មភាពប្រចាំឆ្នាំលើកទីមួយ 2006.

Heder, Steven. 2005. កម្ពុជា៖ ការបង្រួបបង្រួមរបស់លោកហ៊ុន សែន – ការបញ្ចប់ ឬ ជាការចាប់នៃកំណែទំរង់? **Southeast Asian Affairs** pp 113-130.

“មហោស្រពនយោបាយនៅកម្ពុជា៖ រដ្ឋ លទ្ធិប្រជាធិបតេយ្យ ការសម្រុះសម្រួល” ឯកសារ

ដែលបានធ្វើការត្រួតពិនិត្យឡើងវិញ ដាក់ជូនទៅសន្និសិទ្ទ៖ មហោស្រពនយោបាយនៅអាស៊ី និង

អាហ្វ្រិក ទី២៖ ”Contestation, Collusion, and Control, School of Oriental and African

Studies, London, May 2004

ការសិក្សាឯករាជ ស្តីពីការគាំទ្ររបស់ម្ចាស់ជំនួយទៅលើការងារ វិមជ្ឈការ និងវិសហមជ្ឈការ "ការចូលរួមចំណែកចំពោះការអភិវឌ្ឍន៍តាមបែបប្រជាធិបយ្យេ — ជំរើសនានាសំរាប់ការគាំទ្ររបស់ម្ចាស់ជំនួយនៅពេលអនាគត សំរាប់ការងារវិមជ្ឈការ និងវិសហមជ្ឈការ (សេចក្តីព្រាងរបាយការណ៍ចុងក្រោយ) ២៨ មេសា ២០០៦ អាចរកមើលឃើញនៅក្នុងវ៉ិបសាយ www.ardp.org.kh/documents.html.

Mansfield C. & K. Macleod, 2004. “ក្រុមប្រឹក្សាឃុំ សង្កាត់ និងសង្គមស៊ីវិលៈការជំរុញវិមជ្ឈការតាមរយៈភាពដៃគូ”។ ក្រុមការងារស្តីពីភាពជាដៃគូសំរាប់ការងារវិមជ្ឈការ, ភ្នំពេញ”។

Mathews, Verghese, 2007, “កម្ពុជាៈ ការផ្លាស់ប្តូរទិដ្ឋភាពនយោបាយ’, Online Opinion, Australia's E-Journal of Social and Political Debate,
http://www.onlineopinion.com.au
Posted 9 January 2007

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ២៥ មេសា ២០០៧, "ចំនួនសម្លេងឆ្នោតគាំទ្រគណបក្សនយោបាយសរុប សំរាប់ឆ្នាំ 2007
ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់"

_______________, "ចំនួនប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ អនុប្រធានទីមួយ និងអនុប្រធានទីពីរ និងសមាជិក សំរាប់គណបក្សនយោបាយទាំងអស់ បន្ទាប់ពីការបោះឆ្នោតនៅថ្ងៃទី១ មេសា ២០០៧"

NCSC, 2005 "ការត្រួតពិនិត្យឡើងវិញទៅលើកំណែទំរង់វិមជ្ឈការនៅកម្ពុជា: គោលនយោបាយ និងការអនុវត្តន៍ជាក់ស្តែង" at www.ncsc.gov.kh and at www.ardp.org.kh/documents.html.

NGO Forum on Cambodia, March 2004, "ឯកសារទាក់ទិនផ្នែក និងបញ្ហាផ្សេង ស្តីពី ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍នៅកម្ពុជា ២០០៣".

ទីប្រឹក្សា OPM/ SPM, 2006, PAT ការសិក្សាទៅលើការគាំទ្រ និងការប្រតិបត្តិនៃកម្មវិធី Seila/PLG

ឯកឧត្តមព្រុំ សុខា, 2007. "ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅកម្ពុជា តាមរយៈវិមជ្ឈការ និងវិសហមជ្ឈការ", មេរៀននៅសាលាភូមិន្ទរដ្ឋបាល ៣០ មករា ២០០៧ (ការបកប្រែ/សេចក្តីព្រាងក្រៅផ្លូវការ)

រាជរដ្ឋាភិបាលកម្ពុជា, "ក្របខណ្ឌយុទ្ធសាស្រ្តនៃកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ១០ មិនា ២០០៥។

Rudengren, Jan and Joakim Öjendal, 2002, "រៀនតាមការអនុវត្តផ្ទាល់: ការវិភាគទៅលើបទ-ពិសោធន៍របស់កម្មវិធីសីលានៅកម្ពុជា" SIDA, ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិនៃប្រទេស ស៊ុយអែត ផ្នែកធនធានធម្មជាតិ និងបរិស្ថាន

Rusten, Caroline, Kim Sedara, Eng Netra and Pak Kimchoeun, ការប្រឈមនៃការបង្កើតគំរូការងារវិមជ្ឈការនៅកម្ពុជា CDRI, 2005

ឯកឧត្តម ស ខេង: ចំណាប់អារម្មណ៍នៅក្នុងកិច្ចប្រជុំជាមួយម្ចាស់ជំនួយ ស្តីពី របាយការណ៍ការសិក្សាឯករាជ ២៤ ឧសភា ២០០៦ បកប្រែជាភាសាអង់គ្លេស ១១ទំព័រ

ក្រុមប្រឹក្សាផ្តល់យោបល់នៃកម្មវិធីសីលា ស្តីពី អភិបាលកិច្ចបែបប្រជាធិបតេយ្យ ២០០៣ "សង្គមស៊ីវិល និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា, ការផ្លាស់ប្តូរតួនាទី និងនិន្នាការផ្សេងៗ របាយការណ៍ទី៥"។

St John, Ronald Bruce, 2005, "លទ្ធិប្រជាធិបតេយ្យនៅកម្ពុជា- មួយទសវត្សរ៍, ៥ពាន់លានដុល្លាអាមេរិកក្រោយមក: អ្វីដែលខុស"?
**Contemporary Southeast Asia,** Volume: 27. Issue: 3, 2005, Institute of Southeast Asian Studies (ISEAS)